ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩**

**សវនាការលើកទី៥៤**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវ៉ែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

កញ្ញា ណាតាចា វីស៊ែល រីសឺ

*(Ms. Natacha Wexels-Riser)*

លោក ម៉ាតូ គ្រីស្ពារ

*(Mr. Matteo Crippa)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក យ៉េត ចរិយា

លោក អានីស អះមេដ *(Mr. Anees AHMED)*

លោក ពេជ្រ សម្បត្តិ

លោក ហ្សាឆិរី ឡាំពែល *(Mr.Zachery LAMPEL)*

**មេធាវីការពារជនជាប់ចោទ កាំង ហ្កេក អ៊ាវ ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក គង់ ពិសី

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី ស៊ីលឃើស្ទូត ហ្សីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វែនណឺ

*(Mr. Alain Werner)*

លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស

*(Ms. Fabienne Trusse-Naprous)*

**មេធាវីជំនួយរបស់សាក្សី៖**

លោក គង់ សំអុន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# ឧបសម្ព័ន្ធ

## សាក្សី

### លោក ចៀម សឿ

សួរដោយ ប្រធានអង្គជំនុំ ផ្ដើមពី ....................ទំព័រ ១
សួរដោយ ចៅក្រម យ៉ា សុខន ផ្ដើមពី ....................ទំព័រ ៦
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ....................ទំព័រ ២០
សួរដោយ លោក យ៉េត ចរិយា ផ្ដើមពី....................ទំព័រ ២៣
សួរដោយ លោក លោក អានីស អះមេដ ផ្ដើមពី ....................ទំព័រ ២៥
សួរដោយ លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស ផ្ដើមពី....................ទំព័រ ២៩
សួរដោយ លោក គង់ ពិសី ផ្ដើមពី ....................ទំព័រ ៣៤
សួរដោយ លោក ការ សាវុត្ថ ផ្ដើមពី....................ទំព័រ ៣៧
សួរដោយ លោក ហ្វ្រង់ស្វ័រ រូ ផ្ដើមពី....................ទំព័រ ៣៨

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក អានីស អះមេដ | អង់គ្លេស |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក គង់ ពិសី | ខ្មែរ |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក អាឡាំង វែរនេណឺ | អង់គ្លេស |
| លោក ចៀម សឿ | ខ្មែរ |
| លោក ឌុច ផារី | ខ្មែរ |
| លោក គង់ សំអន | ខ្មែរ |
| លោក ហ្វ្រង់ ស្វ័រ រូ | បារាំង |
| លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្ដី | អង់គ្លេស |
| លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្សូ ណាព្រូស | បារាំង |
| ចៅក្រម យ៉ា សុខន | ខ្មែរ |
| លោក យ៉េត ចរិយា | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៩:០២:០៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលថ្ងៃនេះស្តាប់សក្ខីកម្មសាក្សីមួយរូបគឺ KW-22 តាមការបរិច្ឆេទនៃកាលវិភាគកំណត់សវនាការ ។

ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលត្រូវអញ្ជើញចូលរួមនៅក្នុងដំណើរការនីតិវិធីសវនាការសម្រាប់ថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន! ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរនីតិវិធីសវនាការក្នុងថ្ងៃមានវត្តមានគ្រប់ចំនួន ចំណែកឯសាក្សី KW-22 ដែលត្រូវមកផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះដែរ មានវត្តមាន ។ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ ។ សាក្សី KW-22 មិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។ សាក្សីបានស្បថរួចហើយ ។

**ប្រធានអង្គជំនុំ៖**

បង្គាប់មន្ត្រីតុលាការធ្វើការអញ្ជើញសាក្សី KW-22 ចូលមកកាន់បន្ទប់សវនាការ ។

*[សាក្សីចូលមកកាន់បន្ទប់សវនាការ]*

**ការតាំងសំណួរដោយចៅក្រម៖**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សាក្សីតើលោកមានឈ្មោះអ្វីដែរ?

**លោក ចៀម សឿ៖**

**ឆ៖** ខ្ញុំឈ្មោះ ចៀម សឿ ។

**ស៖** ក្រៅពីឈ្មោះ សឿ តើលោកមានដែលប្រើប្រាស់ឈ្មោះអ្វីផ្សេងទៀតដែរឬទេ?

**ឆ៖** ខ្ញុំអត់មានប្រើទេ ។

**ស៖** លោក ចៀម សឿ លោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ខ្ញុំអាយុ៥២ ។

**ស៖** លោកប្រកបមុខរកស៊ីធ្វើអ្វីសព្វថ្ងៃនេះ?

**ឆ៖** ប្រកប ធ្វើស្រែ ឡើងត្នោត ។

[០៩:០៥:៣៤]

**ស៖** តាមរបាយការណ៍ក្រឡាបញ្ជីសវនាការថា លោកពុំមានចំណងលោហិត ឬក៏ញាតិពន្ធជាមួយនឹងភាគីនៃរឿងក្ដីនេះទេ ហើយក៏បានរាយការណ៍ផងដែរថា លោកបានស្បថរួចហើយមុននឹងលោកចូលមកកាន់បន្ទប់សវនាការនេះ ។ តើជាការពិតដែរឬទេ?

**ឆ៖** ការពិត ។

**ស៖** ឥឡូវនេះយើងប្រាប់អំពីសិទ្ធិនិងករណីកិច្ចដល់លោក ក្នុងនាមលោកជាសាក្សីលោក ចៀម សឿ ។ ក្នុងនាមលោកជាសាក្សី លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬក៏សុំឲ្យធ្វើអំណះអំណាងណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនលោក ។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯងមានន័យថា ដោយសារតែចម្លើយ ឬក៏សេចក្ដីអំណះអំណាងទាំងនោះ នាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់ ។

ទន្ទឹមនឹងនេះ លោក ចៀម សឿ ក្នុងនាមលោកជាសាក្សី លោកមានករណីកិច្ចនិយាយការណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញដោយផ្ទាល់ ។ ហើយលោកមិនគប្បីផ្ដល់នូវចម្លើយជាសេចក្ដីសន្និដ្ឋាននោះឡើយ ។

លោក ចៀម សឿ តើលោករស់នៅទីកន្លែងណាខ្លះ? និងធ្វើការងារអ្វីខ្លះក្នុងអំឡុងពេលចាប់ពីចន្លោះឆ្នាំ១៩៧០ រហូតដល់ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥?

**ឆ៖** ខ្ញុំធ្វើការកងទ័ព ដែលនៅទ័ព ប៉ុល ពត និងដល់វ៉ៃតា លន់ នល់ នោះ ។ ដល់រំដោះឆ្នាំ៧៥ បានចេញមកនៅទីកន្លែង គេហៅភូមិទឹកល្អក់ ដាំដំឡូងមី និងដាំដំឡូងជ្វា ។ ដល់មកឆ្នាំ៧៥ ហ្នឹងដែរ ដល់ចេញមក-- ដកគេយកមកឈ្មោះចាន់ ទៅយកខ្ញុំមកៗរៀនហាត់នៅព្រែកហូរនិងតាខ្មៅនេះ ។ ដល់រៀនរួចហ្នឹកហ្នឹន ហាត់រួច បានចេញមក មកនៅ-- យកមកកន្លែងស-២១ មកយាមកាមនៅកន្លែងស-២១ ។ ទីមួយខ្ញុំអត់មានដឹងនៅកន្លែងយាម គេរៀន ស-២១ នេះជាគុកទេ ។

**ស៖** ចុះមកទៀតគឺបានន័យថា នៅក្នុងអំឡុងពេលដែលកម្ពុជាមានសង្គ្រាម ក្នុងចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ លោកធ្វើកងទ័ពរំដោះ អ៊ីចឹងមែនទេ?

ស្តាប់ម្តងទៀត នៅក្នុងចន្លោះឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៧៥ លោកធ្វើជាកងទ័ពរំដោះ អ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំបានធ្វើកងទ័ពរំដោះមែន ។

[០៩:០៩:៣៤]

**ស៖** លោកកាលហ្នឹង លោកធ្វើកងទ័ពរំដោះនៅក្នុងអង្គភាពណា? ហើយឈរជើងនៅទីកន្លែងណាខ្លះទៅ?

**ឆ៖** ខ្ញុំកាលនោះ អត់មានកងទ័ពចេញពីស្រុក គឺកងឈ្លប ។

**ស៖** កងឈ្លបនៅមូលដ្ឋានមួយណា? ហើយនៅក្នុងតំបន់ណា?

**ឆ៖** កងឈ្លបនៅតំបន់កំពង់ឆ្នាំង ។

**ស៖** លោកបាននិយាយអំមិញថា ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ លោកត្រូវបានឈ្មោះ ចាន់ បានទៅយកលោកមក នៅឯភ្នំពេញគឺមកធ្វើនៅទឹកល្អក់ អ៊ីចឹងមែនទេ?

**ឆ៖** ត្រង់ហ្នឹងអត់ទាន់ពិត ។

**ស៖** ចុះលោកអញ្ជើញ-- ត្រូវគេជ្រើសរើសយកមកធ្វើភ្នំពេញ ជ្រើសរើសយកមកនៅថ្ងៃខែឆ្នាំណា? លោកចាំទេ? ហើយអ្នកណាទៅជ្រើសរើសលោក យកពីកំពង់ឆ្នាំងមកធ្វើការនៅភ្នំពេញ?

**ឆ៖** ឈ្មោះ ចាន់ ហ្នឹង ចាន់ សម្រែង ។

**ស៖** ទៅជ្រើសរើសលោកនៅថ្ងៃខែឆ្នាំណា លោកចាំដែរឬទេ?

**ប្រធានអង្គជំនុំ៖**

លោក ចៀម សឿ រង់ចាំនៅក្បាលមីក្រូមានភ្លើងក្រហមសិន ទើបលោកនិយាយ នោះទើបបានសំឡេងរបស់លោកចូលទៅប្រព័ន្ធផ្សព្វផ្សាយសំឡេងនៅក្នុងបន្ទប់សវនាការនេះ ។ ហើយនាំឲ្យសំឡេងរបស់លោក ដែលសម្តីរបស់លោកត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុនៃប្រតិចារឹកនៅក្នុងដំណើរប្រព្រឹត្តទៅនៃសវនាការនេះផង ហើយនិងប្រព័ន្ធនៃការបកប្រែភាសាឮដល់អ្នកបកប្រែភាសា អាចបកប្រែភាសាហ្នឹងទៅភាសាផ្សេងៗដែលអ្នកចូលរួមនៅក្នុងដំណើរការនីតិវិធី ។ នៅទីនេះ គឺប្រើភាសាបី ខ្មែរ ភាសាអង់គ្លេស ហើយនិងភាសាបារាំងផងដែរ ។ អ៊ីចឹង គឺកាលណាលោកនិយាយភ្លើងមិនទាន់សញ្ញាក្រហមទេ គឺលោកនិយាយអត់ឮសំឡេង ។ អ៊ីចឹងអត់មានប្រយោជន៍អីទេ ហើយធ្វើសវនាការហ្នឹងយឺតយ៉ាវ ហើយស្តាប់មិនបានទេ ។

**ស៖** លោកចាំទេថា លោកត្រូវបានជ្រើសរើសមកធ្វើនៅភ្នំពេញហ្នឹងនៅថ្ងៃខែឆ្នាំណា ក្រោយឆ្នាំ១៩៧៥នោះ?

**ឆ៖** ខ្ញុំអត់បានចាំដែរ ។

[០៩:១២:៥១]

**ស៖** កាលនោះជ្រើសរើសមកតែលោកម្នាក់ ឬក៏គេមានមនុស្សជាច្រើនអ្នកដែលត្រូវបានជ្រើសរើសមកធ្វើការពីកំពង់ឆ្នាំងមកធ្វើការនៅភ្នំពេញនោះ?

**ឆ៖** បាទ, មកច្រើន ។

**ស៖** ពេលមកដល់ដំបូង គេបញ្ជូនលោកទៅធ្វើការនៅកន្លែងណា?

**ឆ៖** ពីដំបូងបញ្ជូនទៅនៅតាខ្មៅ ។

**ស៖** នៅពេលដែលដល់តាខ្មៅ តើគេឲ្យលោកធ្វើការងារអ្វីទៅនៅទីនោះ? គេឲ្យលោកធ្វើអ្វីនៅទីនោះ?

**ឆ៖** បាទ, ទៅនៅទីនោះយកទៅនៅហាត់រៀន ហាត់រៀនបាញ់ រាវមីន ដោះគ្រាប់បែក ។

**ស៖** លោកហាត់រៀននៅទីនោះអស់រយៈពេលប្រហែលជាប៉ុន្មានទៅ? ហើយកន្លែងហាត់រៀនហ្នឹង គេហៅកន្លែងអីគេ?

**ឆ៖** កន្លែងហាត់រៀននោះ កន្លែងគេហៅ ព្រែកហូរ ។

**ស៖** លោកចូលសាលារៀនសូត្របច្ចេកទេស រៀនបាញ់ រៀនគប់គ្រាប់បែកអីហ្នឹង អស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំចាំមិនបាន ព្រោះអត់ដឹងខែ អត់ដឹងឆ្នាំ ។

**ស៖** ហើយក្រោយពីរៀនចប់ នៅសាលាបង្រៀនបច្ចេកទេសយោធានៅព្រែកហូរនោះ តើគេបញ្ជូនលោកទៅឲ្យធ្វើការនៅទីណាទៀត?

**ឆ៖** គេដកយកមកកន្លែងស-២១ ។

**ស៖** លោកចាំថាទេ គេដកលោកមកនៅធ្វើការនៅមន្ទីរស-២១ ហ្នឹង នៅក្នុងឆ្នាំខែថ្ងៃណាដែរ? លោកចាំដែរឬទេ?

**ឆ៖** ខ្ញុំអត់បានចាំខែនិងឆ្នាំ ។

[០៩:១៥:៤៤]

**សៈ** លោកស្គាល់ទីតាំងដែលលោកអះអាងថា គេបញ្ជូនលោកមកធ្វើការនៅមន្ទីរស-២១ បានន័យថា កាលណោះមន្ទីរស-១២ ដែលលោកនិយាយហ្នឹងមានទីតាំងនៅកន្លែងណា តាមដែលលោកចងចាំលោកអាចនិយាយប្រាប់ដល់អង្គសវនាការបានដែរឬទេ?

**ឆៈ** កន្លែងទីតាំងស-២១ ខ្ញុំបាទនៅ-- គេហៅទួលស្វាយព្រៃ គុកទួលស្លែងហ្នឹង ។

**សៈ** ពេលគេបញ្ជូនលោកមកដល់ទីកន្លែងនោះ តើគេចាត់តាំងឲ្យលោកធ្វើការងារអ្វីទៅ? ហើយការងាររបស់លោកហ្នឹងនៅក្នុងអង្គភាពណា?

**ឆៈ** នៅក្នុងអង្គភាព ស-២១ហ្នឹង របស់ក្រោម ស-២១ ។

**សៈ** គេឲ្យលោកធ្វើអ្វី? ធ្វើការងារអ្វី?

**ឆៈ** ចាត់តាំងឲ្យខ្ញុំយាមកាមខាងក្រៅ ។

**សៈ** លោកនៅជាកងការពារយាមខាងក្រៅនៃមន្ទីរស-២១ តើប្រធានអង្គភាពបានន័យថាប្រធានដែលមើលការខុសត្រូវលើលោក ដូចជាប្រធានក្រុម ឬក៏ប្រធានកងហា កងរយ ជាដើមហ្នឹង តើលោកស្គាល់អ្នកណាខ្លះ ដែលជាអ្នកមេកើយរបស់លោកផ្ទាល់នៅក្នុងការដឹកនាំក្នុងការធ្វើការងាររបស់លោកប្រចាំថ្ងៃ លោកចាំទេ?

**ឆៈ** ក្នុងក្រុមខ្ញុំអត់បានចាំ អត់ស្គាល់ឈ្មោះ ។

**សៈ** ស្គាល់មេទេ មេកងៗដែលលោកនៅថា អះអាងថាលោកធ្វើការងារនោះ ធម្មតាការធ្វើការងារជាកងទ័ព វាមានលក្ខណៈជាមានមេកង មានមេកើយ តាមលំដាប់នៃអង្គភាពទទួលខុសត្រូវដូចជាប្រធានក្រុម ឬក៏ប្រធានកងហា ប្រធានរយអីជាដើម ។ មិនឲ្យលោកនិយាយថាស្គាល់នៅបុគ្គលិកដូចគ្នា ក្រែងលោលោកភ្លេច ប៉ុន្តែជាប្រធានកងហា ប្រធានកងរយនេះ តើលោកចងចាំទេ ថាលោកស្ថិតនៅក្រោមការទទួលខុសត្រូវ និងការគ្រប់គ្រងផ្ទាល់ពីបុគ្គលណា?

**ឆៈ** ប្រធានកងរយឈ្មោះ ប៉េង ដែលគ្រប់គ្រងនៅក្នុងអង្គភាពដែលអ្នកយាមខាងក្រៅអី ។

**សៈ** ក្នុងនាមលោកដែលគេចាត់ឲ្យធ្វើការជាអ្នកកងការពារ យាមខាងក្រៅ តើលោកអាចរៀបរាប់ដល់អង្គសវនាការបានទេថា តើលោកគេចាត់ឲ្យធ្វើការងារអ្វីខ្លះ? ហើយការងាន៎ុងនៅទីកន្លែងណា? ជាធម្មតា តើលោកជាទូទៅ ឬក៏ភាគច្រើន តើលោកធ្វើការងារយាមកាមនៅចំណុចកន្លែងណានៃមន្ទីរស-២១?

**ឆៈ** នៅជ្រុងខាងលិចមន្ទីរឃុំឃាំង ។

**ស៖** ក្នុងមួយថ្ងៃហ្នឹង តើលោកគេឲ្យត្រូវឲ្យយាមកាមប៉ុន្មានម៉ោង?

**ឆ៖** ក្នុងមួយយាមយប់ មួយយប់១២ម៉ោង ។

[០៩:១៩:៥៩]

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះទេ? សូមអញ្ជើញ ។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំបាទសូមជូនការកត់សម្គាល់តូចមួយ គឺថានៅក្នុងកំណត់អះអាងរបស់កំណត់ហេតុ-- ស្តាប់ចម្លើយសាក្សី ដែលធ្វើឡើងដោយចៅក្រមស៊ើបអង្កេតនោះ ដែលមាននៅក្នុងលេខ ERN00162758 ស្ថិតនៅក្នុង D22/12 ក្នុងឯកសារនេះដោយទំព័រទី២ ដោយខ្ញុំសូមលើកជូនថាសាក្សីក្នុងចំណុចទីមួយនេះ វាមានចំណុចខ្វែង គ្នានៅក្នុងឯកសារនេះថាសាក្សីចេះ-- ប្រកាសថាខ្លួនចេះអាន ចេះសរសេរ និងយល់ភាសាខ្មែរ ។ ប៉ុន្តែ នៅក្នុងចំណុចពាក់កណ្តាលប្រហែលក្នុងបន្ទាត់ទី១៤នេះនៅមានសំណួរ ហើយចម្លើយនោះបានឆ្លើយថាអត់បានរៀនសូត្រអ្វីទេ ដោយសារក្រពេក ។

ដូច្នេះ ខ្ញុំគ្រាន់តែសុំរំឭកថា បើសិនជាអង្គសវនាការទាំងមូលដែលជាក្រុមប្រឹក្សាជំនុំជម្រះ ឬក៏ជាភាគីដែលត្រូវតាំងសំណួរដល់សាក្សីនេះ សូមមេត្តាប្រើពាក្យងាយយល់ ងាយស្តាប់ ដល់សាក្សីផង ពីព្រោះគាត់ពុំមានលទ្ធភាពអាចយល់នៅពាក្យស៊ីជម្រៅច្រើនពេកទេ ។ ហើយម្យ៉ាងទៀត ដោយជីវភាពការរស់នៅរបស់គាត់ប្រចាំថ្ងៃជាកសិករឡើងត្នោតអីអ៊ីចឹង ដូចលោកចៅក្រមបានជ្រាបអម្បាញ់មិញ ។

ដូច្នេះបើសិនជាសួរក្នុងសំណួរច្រើនក្នុងពេលតែមួយអាចធ្វើឲ្យគាត់មិនអាចឆ្លើយនឹងសំណួរហ្នឹងទាំងអស់ ហើយចួនកាលទៅធ្វើឲ្យរំខានដល់ការសាកសួររបស់លោកចៅក្រម និងអស់លោកដែលជាភាគីទៀតផង ។ ដូច្នេះ ខ្ញុំសូមមេត្តាឲ្យអស់លោក លោកស្រី មេត្តាតាំងសំណួរដែលងាយយល់ដល់សាក្សីខ្លះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម យ៉ា សាខន ។

[០៩:២២:៣៣]

**សួរដោយចៅក្រម យ៉ា សុខន៖**

សូមអរគុណលោកប្រធាន ។

**ស៖** លោកសាក្សី នៅពេលដែលគេចាត់តាំងលោកមកស-១២ តើលោកដឹងថាអ្នកណាជាដឹកនាំនៅស-២១ហ្នឹង គណៈដឹងនាគេមានប៉ុន្មាននាក់ទៅ?

**ឆ៖** គណៈដឹកនាំក្នុង ស-១២ អ្នកធំ មានបីរូប ។ មាន ហ៊ុយ, ហើយ ប៉េង, ហ៊ា ។

**ស៖** លោកបានបញ្ជាក់អម្បាញ់មិញថា ប៉េង គឺជាប្រធានកងរយ ប៉ុន្តែតុលាការចង់សួរលោកថា ស-២១ អ្នកទទួលខុសត្រូវខ្ពស់នៅទីនោះ ប្រធាននៅទីនោះនរណាគេ លោកស្គាល់ទេ?

**ឆ៖** ហ៊ុយ, ហ៊ា ។

**ស៖** លោកស្គាល់ជនជាប់ចោទឈ្មោះ ឌុច ទេ?

**ឆ៖** សូមម្តងទៀត ។

**ស៖** លោកស្គាល់ជនជាប់ចោទឈ្មោះ ឌុច ទេ?

**ឆ៖** ឈ្មោះ ឌុច ខ្ញុំស្គាល់គាត់ខ្ពស់ មេធំជាងគេនៅក្នុង ស-២១ ។

**ចៅក្រម យ៉ា សុខន៖**

ប្រធានសូមៗអនុញ្ញាតឲ្យជនជាប់ចោទឈរបង្ហាញខ្លួនតិច ដើម្បីឲ្យសាក្សីមើលទៅគាត់ស្គាល់ទេ?

**សួរដោយចៅក្រម យ៉ា សុខន៖**

**ស៖** លោកស្គាល់ជនជាប់ចោទទេ?

សូមអញ្ជើញអង្គុយចុះ!

លោកដឹងថានៅស-២១ ហ្នឹង មានអង្គភាពប៉ុន្មាននៅក្នុងនុ៎ង?

**ឆ៖** អត់ដឹងទេ ។

**ស៖** លោកគេចាត់តាំងឲ្យលោកនៅក្នុងអង្គភាពអី?

**ឆ៖** អង្គភាពក្នុងរួមនៅហ្នឹង ស-២១ ហ្នឹងតែម្តង ។

**ស៖** តើលោកគេចាត់តាំងឲ្យលោកនៅក្នុងអង្គភាពការពារមែនទេ?

**ឆ៖** នៅការពារខាងក្រៅ ។

**ស៖** មេក្រុមរបស់លោកឈ្មោះអី? លោកចាំទេ?

[០៩:២៥:៥៩]

**ឆ៖** ខ្ញុំអត់បានចាំមេក្រុម ព្រោះអីបែកអស់យូរឆ្នាំហើយ ។

**ស៖** លោកស្គាល់ឈ្មោះ ហុង ទេ?

**ឆ៖** ហុង ហ្នឹងមេក្រុមពីដើម ដល់ពេលស្លាប់ទៅ ។

**ស៖** តើ ហុង ហ្នឹង ជាមេក្រុមរបស់លោក?

**ឆ៖** បាទ, មេក្រុមរបស់ខ្ញុំពីដើម ។

**ស៖** លោកនៅយាមការពារ តើយាមការពារនៅខាងណា? ខាងនៅក្នុង ស-១២ ឬខាងក្រៅ?

**ឆ៖** បាទ, ខ្ញុំយាមខាងក្រៅ ។

**ស៖** យាមខាងក្រៅហ្នឹង ម៉េចលោកដឹងថាគេយាមប៉ុន្មានជាន់?

**ឆ៖** ខាងក្រៅយាមតែមួយជាន់ ក្រុមអង្គភាពខ្ញុំ ក្រុមខ្ញុំ ។

**ស៖** លោកមានបានធ្លាប់ឆ្លើយបញ្ជាក់នៅចៅក្រមស៊ើបអង្កេតទេថា យាមនៅស-២១ហ្នឹង មានយាមខាងក្រៅបីជាន់? មានធ្លាប់បានឆ្លើយអ៊ីចឹងទេ?

**ឆ៖** មានតែបីជ្រុង បើថាបីជ្រុងមាន បើបីជាន់អត់មានទេ ។

**ស៖** យាមបីជ្រុងខាងក្រៅនៅជ្រុងណាខ្លះ?

**ឆ៖** ខ្ញុំក្តាប់មិនបានពីរឿងនេះ ដោយឡែកក្រុមៗ ប៉ុន្តែបែងចែកវាមានបីជ្រុង ។ ជ្រុងខាងជើង ជ្រុងខាងត្បូង ជ្រុងខាងលិច ។

[០៩:២៧:៥០]

**ស៖** ចុះលោកយាមនៅជ្រុងខាងណា?

**ឆ៖** បាទ, ខ្ញុំយាមជ្រុងខាងលិច ។

**ស៖** យាមផ្លូវផ្សារទូលទំពូងបុកមកស្ពាតអូឡាំពិកហ្នឹងមែនទេ?

**ឆ៖** បាទ ។

**ស៖** គេឲ្យលោកយាមនៅទីនោះ។ តើគេឲ្យលោកមានភារកិច្ចធ្វើអីខ្លះតួនាទីអ្នកយាមនៅទីនោះ?

**ឆ៖** តួនាទីដាំបន្លែ យាម ។

**ស៖** តើយាមស្អីគេ? យាមហ្នឹង? យាមរបស់ ឬយាមមនុស្ស ឬយាមអ្នកទោស?

**ឆ៖** បាទ, គេឲ្យយាមនេះការពារខ្លាចអ្នកទោសរួច ។

**ស៖** មុនលោកគេឲ្យទៅយាមហ្នឹង គេមានបានបង្រៀនណែនាំលោកពីវិធីការពារ យាមកាមការពារជុំវិញស-១២ នោះទេ មានគេណែនាំ? ហើយអ្នកណាគេ អ្នកណែនាំហ្នឹង?

**ឆ៖** បាទ, ឈ្មោះ ប៉េង ដែលគាត់ណែនាំឲ្យយាមកាមហ្នឹង ឈ្មោះ ប៉េង ។

**ស៖** ចុះឈ្មោះ ហុង ជាមេក្រុមរបស់លោកមានណែនាំលោកទេ?

[០៩:៣០:០០]

**ឆ៖** បាទ, ឈ្មោះ ហុង ហ្នឹង បានមេក្រុមហ្នឹងណែនាំៗ ប្រជុំជីវភាពអីចឹង ប៉ុន្តែគាត់ស្លាប់ទៅ ។

**ស៖** លោកយាមនៅទីនោះ ចុះកន្លែងសម្រាករបស់ក្រុមលោក គេសម្រាកនៅកន្លែងណា?

**ឆ៖** សម្រាកកន្លែងផ្ទះនៅកន្លែងផ្លូវកន្លែងយាម ថ្នល់ តាមផ្លូវខាងក្រៅហ្នឹង ។

**ស៖** នៅក្បែរកន្លែងយាមហ្នឹងតែម្តង ឬក៏នៅកន្លែងយាមហ្នឹងតែម្តង ផ្ទះសម្រាក?

**ឆ៖** នៅក្បែរកន្លែងយាម ។

**ស៖** ប្រហែលប៉ុន្មានម៉ែត្រពីកន្លែងយាមទៅ?

**ឆ៖** កន្លែងយាមហ្នឹង ឆ្ងាយប្រហែល២០ម៉ែត្រ ពីកន្លែងយាម ។

**ស៖** ផ្ទះដែលសម្រាកហ្នឹង សម្រាកនៅទាំងអស់គ្នា ក្នុងតែក្រុមរបស់លោកតែម្តង? ឬមានលាយជាមួយក្រុមផ្សេងទៀត ផ្ទះសម្រាកហ្នឹង?

**ឆ៖** បាទ សម្រាកក្នុងមួយផ្ទះមួយក្រុម ទាំងអស់គ្នា ។

**ស៖** មួយក្រុមហ្នឹង មានគ្នាប៉ុន្មានដែរ?

**ឆ៖** បាទ, មានគ្នាដប់ពីរនាក់ ។

**ស៖** នៅក្នុងក្រុមដប់ពីរនាក់ លោកមានបានស្គាល់អ្នកណាជិតស្និទ្ធ ដែលលោកនៅចាំឈ្មោះទេ?

**ឆ៖** បាទ អត់បានចាំ ។

**ស៖** នៅពេលហូបបាយ លោកឲ្យហូបបាយនៅកន្លែងណា?

**ឆ៖** បាទ, នៅហូបបាយ សហករណ៍ឯកើតផ្លូវ ។

**ស៖** តើកន្លែងហូបបាយហ្នឹង ជាកន្លែងហូបបាយរួមទាំងបុគ្គលិកស-២១ ទៅហូបទាំងនោះ--ទីនោះ ទាំងអស់គ្នាតែម្តង ហើយក៏ជាកន្លែងហូបបាយដោយឡែកពីគេ?

**ឆ៖** បាទ, ហូបបាយទៅ រួមមួយអង្គភាពស-២១ ហ្នឹងហើយ ប៉ុន្តែខុសវេនគ្នា ។

**ស៖** លោកដឹងច្បាស់ទេថា កន្លែងហូបបាយនៅស-២១ មានតែមួយកន្លែងហ្នឹង?

**ឆ៖** បាទ, ខ្ញុំដឹងតែមួយកន្លែងហ្នឹង ។

**ស៖** ពេលលោកនៅហូបបាយ តើមានឃើញក្រុមគេផ្សេងទៀតៗ ទៅហូបជាមួយទេ?

**ឆ៖** បាទ, ហូបដោយក្រុម ។ ដាក់វេនក្រុម ។

**ស៖** ពេលលោកទៅហូបបាយហ្នឹង គឺហូបបាយតែដប់ពីរនាក់ហ្នឹងទេ នៅផ្ទះបាយហ្នឹង? ឬក៏មានក្រុមគេផ្សេង ទៅហូបនៅពេលម៉ោង ដែលលោកហូប-- ក្រុមលោកទៅហូបដែរនោះ?

**ឆ៖** អត់មានទេ ក្រុមហូបដោយក្រុម ។ ពេលក្រុមខ្ញុំចេញទៅ ក្រុមគេចូលមក ។

**ស៖** តើលោកដឹងថាក្រុមដែលចូលមក ក្រុមនៅខាងណា?

**ឆ៖** ក្រុមគេនៅតាមខាងក្រៅជ្រុង ។ ខាងជើងមិនដឹង ខាងត្បូងមិនដឹង ខ្ញុំអត់បានចាំដែរ ។

**ស៖** លោកដែលហូបបាយជួបប្រទះអ្នកយាមនៅខាងក្នុង ក្រុមអ្នកយាមនៅខាងក្នុង?

**ឆ៖** បាទ, អត់បានជួបគ្នាទេ ។

**ស៖** តើលោកមានដឹងថា មានអ្នកយាមនៅខាងក្នុងទេ មានក្រុមអ្នកយាមនៅខាងក្នុងទេ?

**ឆ៖** ដឹង គ្រាន់តែដឹង ប៉ុន្តែមិនដឹងទៅយាមខាងណាទេ គេនៅជ្រុងណា អត់ដឹងទេ ។

**ស៖** លោកដឹង តើលោកដឹងតាមរយៈអ្នកណា ដែលនិយាយប្រាប់លោកនេះ?

**ឆ៖** ដឹងដោយសារដឹងនេះ ដឹងដោយសារឃើញយាម ពួកយាមខាងក្រៅ ដូចពួកខ្ញុំ ។ គ្រាន់តែដើរមកគ្រាន់ជួបគេ ចេញមកហូបបាយ ។

**ស៖** ចុះចុងភៅមានដែលនិយាយប្រាប់លោកថា ក្រុមនេះគឺហូបមកហើយ ហើយក្រុមនោះចូលមកទៀត ។ មានដែលចុងភៅនិយាយប្រាប់លោកទេ?

**ឆ៖** បាទ, ប្រាប់ចុងភៅប្រាប់ ។ ក្រុមនេះហូបរួច ក្រុមនោះហូបទៅបាត់ ក្រុមនេះមកទៀត ។

**ស៖** ចុះដែលឮសួរចុងភៅនិយាយថា ជនជាប់ចោទ ទើបហូបហើយចេញទៅទេ ។ តើជនជាប់ចោទធ្លាប់ទៅហូបបាយនៅកន្លែងនុ៎ងទេ?

**ឆ៖** បាទ, អត់ដឹងដែរ ។

**ស៖** ពេលលោកយាមនៅខាងក្រៅហ្នឹង គេប្រគល់ភ្លើងអីឲ្យទៅលោកយាម? ហើយអ្នកទាំងអស់គ្នាហ្នឹង កាន់កាំភ្លើងគ្រប់ដៃទាំងដប់ពីរនាក់ហ្នឹង?

**ឆ៖** បាទ, អត់មានកាំភ្លើងគ្រប់ដៃទេ ។ កាំភ្លើងបានតែបីដើម ដោះដូរគ្នា ។

**ស៖** នៅពេលលោកយាម លោកដែលឃើញឡានគេបើកតាមហ្នឹង ចូលទៅខាងក្នុងទេ ចូលទៅក្នុងស-២១ទេ?

**ឆ៖** ឃើញឡានដឹកៗចូលទៅៗក្នុងស-២១ហ្នឹង គ្រាន់តែឃើញ គ្រាន់តែបានតែឃើញ ។ ប៉ុន្តែអត់បានជាក់ស្តែងនូវការដឹកមនុស្ស ដឹងមានប៉ុន្មាននាក់? ផ្នែកអីប៉ុន្មាននាក់? ខ្ញុំអត់ដឹង ។

**ស៖** រថយន្តដែលដឹកចូលទៅស-២១ រថយន្តមកពីណាមក? ឬក៏រថយន្តរបស់ស-២១ ហ្នឹងដែរ?

**ឆ៖** បាទ, នៅរឿងឡានទាំងនោះ អត់ដឹងដែរ ។

**ស៖** រថយន្តនោះដឹកមកៗហ្នឹង មានស្ថានភាពដូចម្តេច នៅឃ្លុំខាងក្រោយមានស្ទីដែលសម្គាល់ដែរថា វាមានផ្ទុកអីនៅខាងក្នុងហ្នឹង លោកមើលឃើញទេ? ឃើញនៅខាងក្នុងហ្នឹងមានស្ទីទេមានមនុស្ស? ឬក៏មានរបស់?

**ឆ៖** បាទ, គ្រាន់តែឮសន្ធឹកតែឡានទេ អត់ប៉ានទៅជិត ។ ទៅយាមទៅ មិនដឹងបានដឹកអី ឃ្លុំអីគេទេ អត់ដឹង ។

**ស៖** នៅពេលដែលរថយន្តមកដល់ តើមានត្រូវឈប់កន្លែងលោក ដើម្បីសុំអនុញ្ញាតបន្តទៀតចូលទៅនឹងក្នុងសិនទេ?

**ឆ៖** ខុសៗ ផ្លូវ ។ ផ្លូវខាងមុខឯណោះ ។

[០៩:៣៨:០០]

**ស៖** នៅក្នុងខណៈលោកយាមនោះ លោកមានបានប៉ាន់ប្រមាណមើលថា មួយថ្ងៃហ្នឹង ឃើញរថយន្តគេដឹកចូលទៅក្នុងហ្នឹងប៉ុន្មានឡាន? ហើយប៉ុន្មានថ្ងៃមានប៉ុន្មានឡាន? លោកមានអាចចាំបានច្បាស់ទេ? ឬក៏សឹងតែរាល់ថ្ងៃ?

**ឆ៖** អត់បានចាំបានច្បាស់ដែរ ។ យូរៗទៅ ឮស្ងូរសន្ធឹកចូលម្តង ។ បីបួនថ្ងៃចូលម្តង ។

**ស៖** លោកឮសន្ធឹកឡាន ឬក៏លោកឃើញឡានហ្នឹង ។ លោកមើលពីកន្លែងលោកយាមទៅឃើញឡានហ្នឹងបើកកាត់ នៅពីមុខហ្នឹងមាន?

**ឆ៖** បាទ, ឮសន្ធឹក ។

**ស៖** ចុះលោកដែលឃើញឡានដែលដឹក ដែលបើកចេញ ត្រឡប់ពីចេញពីស-២១ វិញហ្នឹង លោកដែលឃើញឡានដឹកចេញទេ?

**ឆ៖** បាទ, អត់បានចេញដឹងទេ ព្រោះដោយដេញខុសវេនគ្នា ។ ចួនកាលគេចេញយប់ទៅ ចួនកាលគេចេញថ្ងៃទៅអត់ដឹង ។

**ស៖** នៅអំឡុងពេលលោកធ្វើជាអ្នកយាមខាងក្រៅ គេមានបានចាត់តាំងលោកទៅជាមួយក្រុមគេផ្សេងទៀត ទៅចាប់អ្នកទោសពីខាងក្រៅ មកដាក់នៅស-២១ ហ្នឹងទេ?

**ឆ៖** បាទ, អត់ ។

**ស៖** នៅអំឡុងពេលលោកយាមនោះ លោកមានដែលឃើញអ្នកណា គេបណ្តើរអ្នកទោសយកទៅណាទេ?

**ឆ៖** បាទ, អត់បានឃើញទេ ។

**ស៖** លោកដែលឃើញអ្នកទោសបរទេស ស្បែកស សក់លឿង ខ្ពស់មាឌធំ ។ លោកដែលឃើញទេ?

**ឆ៖** បាទ, ខ្ញុំអត់បានឃើញទេ ។ ប៉ុន្តែខ្ញុំយាមខាងក្រៅ ឃើញគេបណ្តើរជនជាតិអី ខ្ញុំមិនស្គាល់ដែរ ។ ឃើញតែម្នាក់នុ៎ង ។

**ស៖** លោកឃើញគេបណ្តើរអ្នកទោសហ្នឹង ពីពេលថ្មើរណាដែរ?

[០៩:៤១:០៨]

**ឆ៖** ខ្ញុំអត់បានចាំមើលថ្ងៃ មើលម៉ោងពេលដែរ ។

**ស៖** តុលាការគ្រាន់តែចង់ដឹងថា ពេលថ្ងៃ ពេលល្ងាច ឬពេលព្រលប់ ឬពេលព្រឹក តែប៉ុណ្ណឹងទេ។ តុលាការមិនចង់បានពេលម៉ោងពិតប្រាកដប្រជាទេ ។ តើលោកអាចអះអាងបានទេ ថាពេលណា? ពេលព្រឹក ឬពេលថ្ងៃ?

**ឆ៖** ពេលម៉ោងប្រាំមួយ-- អឺ ថ្ងៃជិតគងភ្នំ ។

**ស៖** ពេលព្រលប់ ។ លោកនៅចម្ងាយប៉ុន្មានពីអ្នកដែលគេបណ្តើរអ្នកទោសនោះ? ប៉ាន់ប្រមាណមើលប្រហែលចម្ងាយប៉ុន្មាន?

**ឆ៖** ខ្ញុំអត់ប៉ាន សន្និដ្ឋានប៉ាន់ ព្រោះអីខ្ញុំអត់ដឹង វាឆ្ងាយដែរ ។

**ស៖** ប្រហែលរំលងប៉ុន្មានផ្ទះ?

**ឆ៖** បាទ, កាលនោះ អត់មានផ្ទះអីញាប់ញឹកអ៊ីចឹង ។ ដឹងឯណាមានផ្ទះ ផ្ទះមួយៗ ។

**ស៖** អ្នកទោសដែលត្រូវគេបណ្តើរហ្នឹង ប៉ុន្មាននាក់? ដែលបណ្តើរអ្នកទោស ដែលឃើញហ្នឹងប៉ុន្មាននាក់ ដែលគេបណ្តើរ?

[០៩:៤២:៣៣]

**ឆ៖** បាទ, គេបណ្ដើរបីនាក់ ។

**ស៖** អ្នកទោសហ្នឹង ចំនួនប៉ុន្មាននាក់?

**ឆ៖** អ្នកទោសតែម្នាក់ ។

**ស៖** អ្នកទោសហ្នឹង នៅៗដៃអ្នកទោស នៅមុខអ្នកទោស មានគេធ្វើអីទេ លើអ្នកទោសហ្នឹង?

**ឆ៖** ខ្ញុំអត់ដឹង អត់ទាន់បានដឹង មានមែនមានអត់-- អត់បានមើលនូវការដាក់ស្លែង គ្រាន់តែឃើញគេបណ្ដើរហ្នឹង ដើរចេញពីផុតពីកន្លែងគេ ភារកិច្ចរបស់គេ ។

**ស៖** អ្នកទោសហ្នឹង ឃើញមានដាក់ខ្នោះដៃ ហើយចងមុខ មានឃើញអ៊ីចឹងទេ?

**ឆ៖** បាទ, អត់បានមើលដឹង ។

**ស៖** គេបណ្ដើរចេញពីណា ទៅណា?

**ឆ៖** មិនដឹងបណ្ដើរចេញពីណាទេ ប៉ុន្តែខ្ញុំឃើញនៅមុខសញ្ញារបស់ខ្ញុំ យាមនៅតាមផ្លូវ ខាងក្រោយ ។

**ស៖** តើខាងណាកន្លែងលោកយាម? ខាងជើង? ហើយខាងត្បូង? ខាងកើត? ដែលលោកឃើញនោះ ។

**ឆ៖** គេបណ្ដើរពីទៅត្បូង ពីកន្លែងយាម ។

**ស៖** នៅពេលនោះលោកឈរយាមនៅហ្នឹង ឬក៏គ្រាន់តែលោកដើរយាម?

**ឆ៖** បាទ, ដើរចុះដើរឡើង ។

**ស៖** បន្ទាប់មក គេឲ្យអ្នកទោសហ្នឹងធ្វើអី ?

**ឆ៖** ខ្ញុំអត់បានដឹងដែរ ។

**ស៖** អ្នកបណ្ដើរបីនាក់ហ្នឹង មានឃើញគេកាន់កង់ឡានទេ?

[០៩:៤៥:00]

**ឆ៖** បាទ, ដល់ពេលខ្ញុំត្រឡប់មកវិញបានឃើញគេលើកកង់ឡានដាក់លើអ្នកទោសហ្នឹង បានគេដុត ។

**ស៖** លោកបានបញ្ជាក់អម្បាញ់មិញថា ឃើញបណ្ដើរអ្នកទោស ។ អ្នកបណ្ដើរហ្នឹងមានកាន់កង់ឡាន ឬទេ? ឬក៏ទៅដល់កន្លែងនុ៎ងមានកង់ឡានស្រេចតែម្ដង?

**ឆ៖** ដែលបណ្ដើរនុ៎ងអត់មានឃើញកង់ឡានទេ ។

**ស៖** នៅពេលនោះលោកមានបានឃើញគេឲ្យគាត់-- អ្នកទោសនោះអង្គុយ ឲ្យអ្នកអ្នកទោសនោះអង្គុយសិនទេ?

**ផ៖** បាទ, ឲ្យអង្គុយ ។

**ស៖** បន្ទាប់ពីអ្នកទោសអង្គុយហើយ គេធ្វើម៉េចទៀតដាក់អ្នកទោស?

**ផ៖** គេយកកង់ឡានហ្នឹងស៊កទៅក្នុងលើក្បាលអ្នកទោសហ្នឹង ។

**ស៖** អ៊ីចឹងបញ្ជាក់ថា អ្នកទោសហ្នឹងនៅមានជីវិតទេ គាត់អង្គុយៗ គាត់នៅមានជីវិត?

**ផ៖** នៅមានជីវិតរស់ ។

**ស៖** គេស៊កកង់ឡានចូលទៅខ្លួនគាត់ គេស៊កកង់ឡានប៉ុន្មានកង់? ប៉ុន្មានកង់ឡានទៅចូលក្នុងខ្លួនគាត់? គេស៊កតាមក្បាល?

**ផ៖** បាទ ។

**ស៖** ស៊កសំបកកង់ឡាន ប៉ុន្មានកង់ឡាន?

**ផ៖** ខ្ញុំអត់បានពិតដែរ ដែលរឿងប៉ុន្មានៗ ខ្ញុំប៉ិាននៅជិតដែរ ព្រោះចេញដើរពីនោះទៀត ។

**ស៖** នៅពេលស៊កកង់ឡានហ្នឹង អ្នកបណ្ដើរបីនាក់នៅទីនោះទាំងអស់គ្នា?

**ផ៖** ពួកគេចេញមកបាត់មក គេដុតចោលទៅ ។

**ស៖** អ្នកបណ្ដើរទាំងបីនាក់ហ្នឹង មានកាន់កាំភ្លើងទេ?

**ផ៖** អត់មានកាន់កាំភ្លើងផង ។

**ស៖** អ្នកណានៅក្នុងចំណោមអ្នកបីហ្នឹង អ្នកណាគេយកភ្លើងទៅដុតនៅលើកង់ឡានហ្នឹង?

[០៩:៤៨:១៤]

**ផ៖** គេអ្នកបណ្ដើរទាំងបីនុ៎ងហើយ ។

**ស៖** លោកបានមានលួចមើលសភាពយ៉ាងម៉េចដែរ នៅពេលដែលកង់ឡានឆេះឡើង? ហើយអ្នកទោសនោះយ៉ាងម៉េច?

**ផ៖** ខ្ញុំអត់បានមើល ដឹងតែឆេះ អត់បានចូលទៅមើល ។

**ស៖** តើនៅពេលណាដែលឆេះអស់ សំបកកង់នោះឆេះអស់?

**ផ៖** បាទ, នេះអត់ពិត ព្រោះដោះដូរគ្នាទៅវិញទៅមកសម្រាក ។

**ស៖** ប្រហែលជាប៉ុន្មានម៉ោងទៅបានឆេះកង់ឡានហ្នឹងអស់?

**ឆ៖** បាទ, អត់ដឹងម៉ោងទេ ព្រោះអត់មាននាឡិកាអីពាក់ ។

**ស៖** ពេលនោះលោកយាមពីម៉ោងប៉ុន្មានទៅម៉ោងប៉ុន្មាន?

**ឆ៖** ពីម៉ោងប្រាំមួយទល់ម៉ោងដប់ពីរ ។

**ស៖** ពីម៉ោងប្រាំមួយព្រលប់ដល់ម៉ោងដប់ពីរ ។ ពេលលោកឃើញ គេបណ្ដើរហ្នឹង លោកបានបញ្ជាក់អំមិញព្រលប់ៗ ។ ដូច្នេះ ក្នុងរយៈពេលប្រាំមួយម៉ោង លោកមើលទាំងប្រាំមួយម៉ោងនៅឧប្បត្តិហេតុ ដែលកើតឡើងហ្នឹង?

**ឆ៖** អត់មានទៅដល់-- ភ្លើងនោះក៏មិនទាន់ឆេះអស់ដែរ ប៉ុន្តែដូរម៉ោងគ្នា ។

**ស៖** នៅពេលដែលលោកដូរម៉ោងហ្នឹង លោកឃើញយ៉ាងម៉េចដែរអ្នកទោសហ្នឹង? ឆេះអស់ពាក់ ឬក៏ឆេះទាំងអស់ទៅហើយ?

**ឆ៖** បាទ, ដែលខ្ញុំនៅយាមនោះ ភ្លើងមិនទាន់ឆេះសុសសពឡើយទេ ។ ត្រូវវេនគេមកបានគេយាមទៀត មិនដឹងសុស ដឹងចំវេនគេក៏មិនដឹង ។

**ស៖** ពេលស្អែកឡើង លោកយាមនៅម៉ោងប៉ុន្មាន?

**ឆ៖** ស្អែកឡើងយាមម៉ោងប្រាំមួយ ចាប់ពីម៉ោងប្រាំមួយល្ងាចអីចឹងដែរ ។

**ស៖** លោកមានក្រឡេកទៅមើលកន្លែងគេដុតនុ៎ងទេ? មានឃើញសំណល់សាកសពនៅទីនោះទេ?

**ឆ៖** បាទ, ឃើញ ឆេះអត់អស់ផង ។

**ស៖** នៅសល់ចំណែកណាខ្លះទៅ?

[០៩:៥១:៥៥]

**ឆ៖** នៅចំណែក នៅខ្លួនខ្មៅ ជើងខ្មៅ រោលដូចរោលផ្សែងអីចឹង ។

**ស៖** គេអត់មានបន្ថែមកង់កៅស៊ូដុតបន្ថែមទៀត ដើម្បីឱ្យសុសទេ?

**ឆ៖** បាទ, អត់មានថែមទៀត ដុតចោល ។

**ស៖** លោកបញ្ជាក់អម្បាញ់មិញថានៅសល់ រោលខ្មៅ ហើយលោកបញ្ជាក់អម្បាញ់មិញថាដុតចោល ។ តើសំណល់ហ្នឹងគេយកទៅចោល ឬក៏ដុតឱ្យសុសឱ្យទៅជាផេះតែម្តង?

**ឆ៖** ដែលដុតហ្នឹង គេដុត ដាក់ដុតចោល ប៉ុន្តែឆេះអត់ឆេះ រលត់អស់ ។ អ្នកដុតហ្នឹង វាដើរចេញ គេចេញទៅបាត់ទៅ ខ្មោចហ្នឹងវាអត់យកកៅស៊ូមកថែមដុតថែមទៀតទេ ។

**ស៖** អ៊ីចឹងបានសេចក្តីថា ពេលព្រឹកឡើង ពេលលោកយាមម្តងទៀតហ្នឹង លោកក្រឡេកឃើញទៅ ឃើញមនុស្ស-- សាកសពនោះនៅទីកន្លែងហ្នឹងមែនទេ?

**ឆ៖** បាទ, គឺនៅកន្លែងហ្នឹង ។

**ស៖** លោកយាមបន្តប្រាំមួយម៉ោងទៀត ដល់ម៉ោងដប់ពីរយប់ ។ តើសាកសពនៅទីហ្នឹងកន្លែងទៀតទេ? ឬក៏មានអ្នកណាគេយកចេញទៅហើយ?

**ឆ៖** បាទ, អត់មានអ្នកណាយកទៅណាទេ នៅទីហ្នឹង ។

**ស៖** រហូតដល់លោកត្រូវគេប្តូរយាមនៅម៉ោងដប់ពីរទៀត ។ នៅពេលនោះសាកសពនៅទីហ្នឹងដដែល? ឬក៏យកគេចេញទៅហើយ?

**ឆ៖** បាទ, ក្នុងក្រុមខ្ញុំយាមហ្នឹង មុខសញ្ញាហ្នឹង ខ្មោចនៅហ្នឹងដដែល អត់មានអ្នកណាយកទៅណា ដែលនៅសល់ហ្នឹង ។

**ស៖** ពេលណាដែលលោកលែងឃើញសពហ្នឹង នៅទីកន្លែងហ្នឹង? ប៉ុន្មានថ្ងៃក្រោយមក?

**ឆ៖** បាត់ ខ្ញុំអត់ដឹងដែរ ស្រាប់តែបាត់ទៅ ។

**ស៖** ប្រហែលវេលវេនយាមរបស់លោកប៉ុន្មានវេន ដែលលោកក្រឡេកទៅលែងឃើញមាន?

**ឆ៖** ដែលបានយាមហ្នឹងវាចេះ មិនបានក្រឡេកមើលថែមទៀតរឿងខ្មោចហ្នឹង ។

**ស៖** លោកបានឃើញ តើនៅក្នុងមិត្តភក្តិលោក ដែលយាមជាមួយគ្នាហ្នឹង គេមានបានឃើញដូចលោកទេ?

**ឆ៖** ក្នុងក្រុមហ្នឹង គេលែងអីទៅប្រាប់គ្នាហើយថា មានគេដុតខ្មោច ដុតអី អ៊ីចឹងទៅ ដើរមកគ្នាចេះតែមើលទៅ ។

[០៩:៥៥:៣០]

**ស៖** លោកមានបានមើលច្បាស់ទេ អ្នកបីនាក់ដែលនាំអ្នកទោសយកទៅដុតហ្នឹង នៅក្រុមណា? ក្នុងចំណោមបីនាក់ លោកមានប្រហាក់ប្រហែលអ្នកណាម្នាក់ទេ? នៅក្នុងក្រុមណា?

**ឆ៖** បាទ, អត់ដឹងគេនៅក្នុងក្រុមណាទេ ។

**ស៖** លោកមានបានដឹងទេថា មានគេចាប់បុគ្គលិកស-២១ យកទៅដាក់នៅ ស-២១ នោះដែរ?

**ឆ៖** បាទ, អត់ដឹង ។

**ស៖** អ៊ីចឹង លោកអម្បាញ់មិញបញ្ជាក់ថា ឈ្មោះ ហុង មេក្រុមលោក ឥឡូវគាត់ស្លាប់បាត់ហើយ ។ តើ ហុង ហ្នឹង គេចាប់យ៉ាងដូចម្ដេច?

**ឆ៖** គេចាប់ក្នុងមេក្រុមហ្នឹង ចាប់យកទៅដាក់នៅក្នុងកន្លែងស-២១ ហ្នឹងដដែល ។

**ស៖** មេក្រុម ហុង ហ្នឹង គាត់ដេកនៅនឹងផ្ទះជាមួយលោក?

**ឆ៖** បាទ, ដេកជាមួយគ្នា ។

**ស៖** នៅពេលគេចាប់មេក្រុមហ្នឹង ប្រហែលថ្ងៃរណា? ហើយគេចាប់របៀបម៉េចទៅ? គេមានយកភ្ជួយមកគ្រប់ទេ?

**ឆ៖** បាទ, អត់មានភ្ជួយអត់អី ។ ចាប់នេះដោយសារនយោបាយថាឲ្យគ្នាទៅប្រជុំពេញភារកិច្ច។

**ស៖** លោកដឹងមូលហេតុអី បានគេចាប់ឈ្មោះ ហុង ហ្នឹង? គាត់មានធ្វើអីខុស?

**ឆ៖** បាទ, អត់ដឹងដែរ ។

**ស៖** មិនមែនបណ្ដាលមកពីគាត់យាមងោកទេ?

**ឆ៖** បាទ, អត់ដឹងទេ ដឹងខុសរឿងអី ។

**ស៖** គេឲ្យគាត់ទៅប្រជុំ ថាទៅប្រជុំនៅពេលណា?

**ឆ៖** ខ្ញុំសូមជម្រាប អត់មានដឹងម៉ោង ដឹងពេល ប៉ុន្តែម៉ោងពេលយប់បន្តិចហើយ ប៉ុន្តែមិនដឹងម៉ោងប៉ុន្មាន ។

**ស៖** លោកមានចាំ តើអ្នកគេមកហៅលោក ហុង ហ្នឹង ឲ្យទៅប្រជុំ? ក្រុមលោកដែរ ក្នុងក្រុមដប់ពីរនាក់ហ្នឹង? ឬក៏មានក្រុមគេផ្សេង គេមកហៅគាត់ទៅប្រជុំ?

[០៩:៥៨:៤៦]

**ឆ៖** មានក្រុមគេផ្សេង មានក្រុមគេខាងក្នុងផ្សេង ។

**ស៖** គេមកប៉ុន្មាននាក់ហ្នឹង?

**ឆ៖** គេមកបីនាក់ ។

**ស៖** ហើយគេនិយាយយ៉ាងម៉េចជាមួយនឹង ហុង? តាមសម្ដីរបស់អ្នកណា? អ្នកណាគេប្រាប់មកឲ្យគាត់ទៅប្រជុំ? លោកឮថាដូចម្ដេចខ្លះទៅ?

**ឆ៖** បាទ, កាលនោះខ្ញុំភ្លេចដែរ មិនដឹងនិយាយថាម៉េច អីថាម៉េចដែរ ។

**ស៖** នៅពេល ដែលគេទាំងបីនាក់មកប្រាប់លោក ហុង ភ្លាម ហុង ទៅភ្លាម? ឬក៏រង់ចាំពេលព្រឹកបានទៅ?

**ឆ៖** បាទ, ទៅភ្លាម ។

**ស៖** គេនាំគាត់ទៅ ឬក៏គេយកមកស៊្លឹមកដឹកគាត់ទៅប្រជុំ?

**ឆ៖** ដើរទៅទាំងអស់គ្នាហ្នឹង ដើរធម្មតា ។

**ស៖** មានឃើញគាត់ត្រឡប់មកវិញទេ?

**ឆ៖** បាទ, ដល់តែបាត់ទៅ បានអត់ដឹងថា បើទៅប្រជុំ ទៅមានផែនការហ្នឹង ច្បាស់ជាងាប់ហើយ ។

**ស៖** លោកដឹងថា គាត់ស្លាប់ហ្នឹង នរណាគេប្រាប់លោក?

**ឆ៖** ប្អូនរបស់ ហុង ហ្នឹង នៅយាមខាងក្នុងយាមបងហ្នឹងដដែលហ្នឹង ។

**ស៖** ប្អូនរបស់បង ហុង ឈ្មោះអីទេ?

**ឆ៖** *(អត់ឮសូរសំឡេង)* ។

**ស៖** សូមលោកចាំភ្លើងក្រហមឆេះ ហើយឆ្លើយមកវិញ ។ ប្អូន ហុង ហ្នឹងឈ្មោះអី? សូមលោកបញ្ជាក់ម្តងទៀត ។

**ឆ៖** ឈ្មោះ ខៀវ ពៅ ។

**ស៖** គាត់ជាអ្នកយាមខាងក្នុង?

**ឆ៖** បាទ, គាត់យាមខាងក្នុងហ្នឹង បានជួបបងហ្នឹង ។

**ស៖** លោកមានបានសួរប្អូន ហុង ហ្នឹង មានដឹងថាគេយកគាត់ទៅសួរចម្លើយទេ?

**ឆ៖** បាទ, អត់ទាន់សួរផង ។

**ស៖** លោកដឹងថា គេឃុំ ហុង ហ្នឹងនៅទីណាទេ?

**ឆ៖** បាទ, អត់ដឹង ។

**ស៖** លោកមានដឹងថាគេយក ហុង ទៅណាបាត់លែងត្រឡប់មកវិញ?

**ឆ៖** បាទ, អត់ដឹង ។

**ស៖** លោកធ្លាប់ដែលឃើញគេបណ្តើរអ្នកទោសស្រីចេញពីស-២១ ឬក៏ចូលទៅស-២១ លោកដែលឃើញទេ?

**ឆ៖** បាទ, អត់ឃើញ ។

[១០:០៣:៣៣]

**ស៖** លោកដែលដឹងមានគេប្រាប់ថា នៅខាងក្នុងហ្នឹងមានបន្ទប់ឃុំឃាំង ឃុំរួម ឃុំដោយឡែក? ដាក់ខ្នោះអ្នកទោសរបៀបម៉េច? ឲ្យបាយអ្នកទោសរបៀបម៉េច? ឲ្យអ្នកទោសងូតទឹករបៀបម៉េច? លោកដឹងទេរឿងហ្នឹង?

**ឆ៖** បាទ, អត់ដឹងទេ ។

**ស៖** លោកមានតួនាទីយាមខាងក្រៅហ្នឹងរហូតដល់ពេលណា លោកប្តូរតំណែងទៅកន្លែងផ្សេងទៀត?

**ឆ៖** ខ្ញុំអត់បានចាំដែរ ជិតៗឃ្លូនចូលហ្នឹង ខ្ញុំទៅនៅធ្វើស្រែបាត់ទៅ មិនដឹងខែប៉ុន្មានឆ្នាំប៉ុន្មាន ។

**ស៖** អ៊ីចឹងបានសេចក្តីថា លោកមានតួនាទីជាអ្នកយាមខាងក្រៅហ្នឹងរហូតទាល់តែគេបញ្ជូនឲ្យលោកទៅធ្វើស្រែ ។ ដូច្នេះមែនទេ?

**ឆ៖** បាទ ។

**ស៖** នៅក្នុងអំឡុងពេល ដែលលោកធ្វើការនៅទីនោះ លោកមានបានគេតម្រូវឲ្យទៅរៀនសូត្ររៀននយោបាយ រៀនបច្ចេកទេសយាមកាម នៅកន្លែងណាដែរ? ហើយអ្នកណាជាអ្នកបង្រៀន?

**ឆ៖** បាទ, អត់មានអ្នកណាបង្ហាត់ ប៉ុន្តែគ្រាន់តែដើរប្រាប់យាមអ៊ីចេះមួយ អ៊ីចេះពីរ ។

**ស៖** លោកដែលគេហៅទៅរៀននយោបាយទេ?

**ឆ៖** បាទ, អត់ដែលទៅរៀននយោបាយម៉េច ព្រោះខ្ញុំអត់ចេះនឹងគេ អ្នកអត់ចេះអក្សរ អត់ដែលទៅរៀន ។

**ស៖** ចុះលោកមានកំណត់ចំណាំថា នៅក្នុងក្រុមរបស់លោកដប់ពីរនាក់ហ្នឹង មានអ្នកណាគេទៅរៀននយោបាយ ហើយទុកអ្នកអត់ចេះអក្សរនៅកន្លែង យាមកន្លែង អ៊ីចឹងមែនទេ?

**ឆ៖** អត់ដែលឃើញផងហ្នឹងនុ៎ង អត់ដែលឃើញទៅរៀននយោបាយណាផង ក្នុងក្រុមរបស់ខ្ញុំគ្រប់ មិនដឹងក្រុមរបស់គេដកក៏មិនដឹង ក្រុមខ្ញុំអត់ដែលទៅរៀនឯណាផង ។

**ស៖** លោកដែលបានចូលទៅក្នុងមន្ទីរស-២១ ហ្នឹងទេ?

**ឆ៖** បាទ, អត់ដែលទេ ។

**ស៖** លោកមានដឹងថា នៅក្នុងមន្ទីរនោះ គេមានឃុំឈ្លើយសឹកវៀតណាមនៅក្នុងនោះទេ?

**ឆ៖** បាទ, អត់ដឹង ។

[១០:០៧:១៤]

**ស៖** លោកមានដែលដឹងថា អ្នកទោសត្រូវគេយកទៅសួរចម្លើយ ហើយមានគេប្រើអំពើហិង្សាលើអ្នកទោសនោះ ។ លោកធ្លាប់ឮគេនិយាយទេក្នុងចំណោមមិត្តភក្តិរបស់លោកដែលអ្នកយាមខាងក្រៅហ្នឹង?

**ឆ៖** បាទ, អត់ឮនិយាយដែរ អត់ដឹងទាំងអស់គ្នា ។

**ស៖** នៅពេលណា លោកគេឲ្យទៅលោកធ្វើស្រែ? ហើយធ្វើស្រែនៅឯណា?

**ឆ៖** បាទ, អត់ដឹងខែណា ថ្ងៃណាផង ។

**ស៖** ប្រហែលជាប៉ុន្មានខែមុនថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ហ្នឹង?

**ឆ៖** បាទ, អត់ដឹង ដឹងពីខែប៉ុន្មាន ថ្ងៃប៉ុន្មាន ជំនាន់នុ៎ងដឹងតែពីធ្វើ ។

**ស៖** មានដឹងថាគេនាំអ្នកទោសយកទៅសម្លាប់នៅជើងឯកទេ?

**ឆ៖** បាទ, អត់ដឹងទេ ។

**ចៅក្រម យ៉ា សុខន៖**

សូមជម្រាបលោកប្រធាន! ខ្ញុំអស់សំណួរ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម មានសំណួរអ្វីសួរដល់សាក្សីរូបនេះដែរឬទេ?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោក តើលោកចាំទេ តើលោកអាយុប៉ុន្មានពេលដែលលោកទៅដល់ស-២១?

**ឆ៖** ខ្ញុំអត់បានចាំដែរ ។

**ស៖** តើរយៈពេលប៉ុនណា ដែលលោកធ្វើជាអ្នកយាមនៅស-២១?

**ឆ៖** ខ្ញុំអត់ដឹងភ្លេចដែរ ។

**ស៖** តើនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ លោកនៅឯណា? នៅពេលដែលកងទ័ពវៀតណាមចូលមកនោះ?

**ឆ៖** បាទ, ខ្ញុំទៅផ្ទះ រត់ទៅផ្ទះ ទៅស្រុក ។

[១០:១០:៥៣]

**ស៖** មុនពេលដែលលោករត់ តើលោកនៅឯណា? តើលោកនៅស-២១ ឬក៏លោកនៅកន្លែងណាផ្សេងពីហ្នឹង?

**ឆ៖** បាទ, នៅកន្លែងធ្វើស្រែ ។

**ស៖** តើរយៈប៉ុន្មានដែលលោកនៅកន្លែងធ្វើស្រែនោះ?

**ឆ៖** រយៈពេលនោះខ្ញុំអត់ដឹង ។

**ស៖** តើកន្លែងធ្វើស្រែនោះគេហៅឈ្មោះអ្វីដែរ?

**ឆ៖** កន្លែងព្រៃស ។

**ស៖** តើលោកទៅទីនោះដើម្បីធ្វើការលត់ដំ? ឬក៏គ្រាន់តែលោកទៅទីនោះដើម្បីធ្វើស្រែដាំដុះ? តើអ្នកណាជាអ្នកបញ្ជូនលោកទៅទីនោះ?

**ឆ៖** បាទ, ទៅធ្វើស្រែនោះ ធ្វើលត់ដំ ហើយនិងអ្នកដែលបញ្ជូនទៅ ខ្ញុំអត់បានស្គាល់ ។

**ស៖** តើលោកបានធ្វើអ្វីខុសទេដែលនាំឲ្យគេបញ្ជូនលោកទៅព្រៃស?

**ឆ៖** បាទ, បញ្ជូនហ្នឹង ដកទាំងក្រុម ដកទាំងក្រុមៗទៅស្ទូងតែម្តង ទៅធ្វើស្រែ ។

**ស៖** តើលោកបានទទួលការសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេតដែរទេ នៅក្នុងឯកសារ D22 នៅក្នុងសំណុំរឿងដែលយើងបានលើកឡើងពីមុន ។ នៅក្នុងការសម្ភាសន៍នោះលោកបានបញ្ជាក់ថា ហើយទីកន្លែងនោះដែលលោកធ្វើការ គឺជាកន្លែងអ្នកយាមធ្វើការដែលថា មានខុសវិន័យ ហើយខ្ញុំចង់ឲ្យលោកប្រាប់យើងថា តើលោកមានការភ័យខ្លាចអំពីអ្វី? នៅពេលដែលលោកនៅស-២១ តើលោកមានការភ័យខ្លាចអំពីអ្វី?

**ឆ៖** បាទ, ខ្ញុំអត់ខ្លាច ។

**ស៖** តើលោកអាចប្រាប់ខ្ញុំបានទេ តើលោកនៅមានការភ័យខ្លាចទេថ្ងៃនេះ? នៅពេលដែលលោកនិយាយអំពីស-២១ តើលោកនៅមានការភ័យខ្លាចអ្វីដែរឬទេ?

**ឆ៖** បាទ, អត់មានភ័យខ្លាចអីទេ ។

**ស៖** ហើយថ្ងៃនេះ តើលោកមានការភ័យខ្លាចជនជាប់ចោទដែរឬទេ?

**ឆ៖** បាទ, អត់ខ្លាចទេ ។

**ស៖** តើលោកមានការភ័យខ្លាចចៅក្រមដែរឬទេ?

[១០:១៥:00]

**ឆ៖** បានខ្លាចបន្តិចៗដែរ ខ្លាច ។

**ស៖** ខ្ញុំជឿថា លោកមានឱកាសជួបជាមួយមេធាវីរបស់លោកដែលបានពន្យល់រឿងមួយចំនួនដល់លោកដែលថា លោកមិនអាចឆ្លើយនូវសំណួរណាដែលអាចនឹងដាក់បន្ទុកលើខ្លួនឯង ។ ប៉ុន្តែ ខ្ញុំសូមប្រាប់លោកថា លោកត្រូវតែឆ្លើយនូវសំណួរដើម្បីស្វែងរកការពិត ។ អ៊ីចឹង តើលោកអាចប្រាប់យើងបានដែរឬទេ អំពីវិន័យ ហើយនិងការណែនាំដែលលោកត្រូវតែធ្វើតាមនៅពេលនោះ? តើមានការងាយស្រួលទេ ដែលធ្វើជាអ្នកយាមនៅ ស-២១ ឬក៏ជាការលំបាកធ្វើជាអ្នកយាមនោះ?

**ឆ៖** ការពិបាកយ៉ាប់ និងភ័យខ្លាច បានខំយាមកាម ។

**ស៖** តើលោកមានការទាក់ទងជាមួយមនុស្សនៅខាងក្រៅទេ ឬក៏លោកនៅតែក្នុងកន្លែងយាមនោះ មិនអាចទាក់ទងអ្នកខាងក្រៅបាន? តើលោកអាចទាក់ទងជាមួយក្រុមគ្រួសារ ឬមិត្តភក្តិខាងក្រៅ? តើមានឱកាសអ្វីអាចនឹងទៅភ្នំពេញបានដែរឬទេ?

**ឆ៖** សូមម្តងទៀត ខ្ញុំអត់យល់ ។

**ស៖** តើលោកមានការទាក់ទងជាមួយក្រុមគ្រួសារឬទេ នៅក្នុងពេលដែលលោកនៅស-២១ កាលនោះ?

**ឆ៖** បាទ, អត់មានទាក់ទង ។

**ស៖** តើលោកអាចប្រាប់យើងបានដូចម្តេចអំពី ឌុច? តើលោកបានចូលរួមក្នុងវគ្គសិក្សារៀនសូត្រជាមួយគាត់ឬទេ?

**ឆ៖** បាទ, អត់បានចូលសិក្សាជាមួយគាត់នោះដែរ មានតែគេអ្នកក្រុមៗមាន គេនៅក្នុងៗ ។

**ស៖** តើលោកបានដឹងថា តើ ឌុច និយាយពីអ្វីខ្លះទេនៅក្នុងវគ្គរៀនសូត្រទាំងនោះនោះ?

**ឆ៖** បាទ, ខ្ញុំអត់បានដឹង អត់បានទៅរៀន អត់ដឹងថាណែនាំយ៉ាងម៉េច ម៉េចៗអត់ដឹងទេ ។

**ស៖** ក្នុងពេលដែលលោកផ្តល់បទសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត ជាអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ហើយលោកបាននិយាយថា ខ្ញុំយោងទៅរកអត្ថបទហ្នឹង ទំព័រទី១២ ក្នុងជាភាសាបារាំង D22/12 លេខ ERN លេខ 00162753 ។ គេបានសួរសំណួរលោកថា៖

តើលោកមានការភ័យខ្លាចទេ? លោកឆ្លើយថា "ខ្ញុំខ្លាចគ្រប់ពេលវេលា ហើយខ្ញុំព្យាយាមមិនឲ្យងោកទេនៅពេលដេក នៅពេលណាយើងងោក គេនឹងច្បាស់ជានឹងសម្លាប់យើង" ។ សំណួរសួរថា

"តើលោកមិនដែលបានឃើញគេសម្លាប់មនុស្ស ថាតើលោកខ្លាចពីរឿងអី?" លោកឆ្លើយថា "ខ្ញុំមានការភ័យខ្លាច ពីព្រោះមិនដឹងថា ខ្ញុំខុស ឬមិនខុសទេ ខ្ញុំខ្លាចគេចាប់ខ្លួនខ្ញុំដូចអ្នកដទៃ" ។ គេសួរទៀត "តើលោកបានទទួលការគំរាមកំហែងដែរឬទេ?" លោកឆ្លើយថា "គេនិយាយថា ឌុច បានបង្កើតផែនការ បើសិនជាខ្លាំងចេញ ឬក៏រត់ អ្នកយាមនឹងត្រូវចាប់ខ្លួន ហើយដាក់គុកភ្លាម" ។ តើលោកចាំថា លោកបាននិយាយបែបនេះដែរឬទេ?

**ឆ៖** ដូចមិនដឹងបាននិយាយប្រាប់ច្រើនពេកហើយ ខ្ញុំភ្លេចកន្លែងហ្នឹង ចងចាំហ្នឹងឯង ។

**ស៖** តើលោកបានជួប ឌុច ប៉ុន្មានដងដែរ? តើលោកបានដឹងថាគាត់ធ្វើអីដែរនៅស-២១ កាលនោះ?

**ឆ៖** គាត់កាលនៅ ស-២១ គាត់ធ្វើប្រធានធំកាន់ក្ដាប់ក្នុងរួមអង្គភាពស-២១ ។

**ស៖** លោកក៏បាននិយាយថាដែរថា ម្នាក់ៗមានការភ័យខ្លាច ឌុច ណាស់ តើជាការពិតដែរឬទេ?

**ឆ៖** បាទ, គឺភ័យខ្លាច ពិត ។

**ស៖** ដូច្នេះថ្ងៃនេះ តើលោកអាចប្រាប់យើងបានទេ លោកមិនខ្លាច ឌុច ទៀតទេថ្ងៃនេះ ប៉ុន្តែលោកមានការភ័យខ្លាចថៅក្រមវិញ តើអ៊ីចឹងទេ?

**ឆ៖** បាទ, ខ្លាចខុសគេវ៉ៃ ខ្លាចនិយាយទៅខុស សូមអភ័យទោស ។

**ថៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំមិនមានសំណួរអ្វីទៀតទេ ចំពោះសាក្សីនេះលោកប្រធាន សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីអាចសួរសំណួរដល់សាក្សីរូបនេះ ប្រសិនបើមានសូមអញ្ជើញ ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា៖**

**សួរដោយ លោក យ៉េត ចរិយា៖**

**ស៖** អរគុណលោកប្រធាន ។ លោក ចៀម សឿ លោកបានអះអាងថា មុនឆ្នាំ១៩៧៥ លោកចូលឈ្លប តើពេលនោះលោកមានអាយុប៉ុន្មាន?

[១០:២៣:០៣]

**ឆ៖** កាលនោះគឺខ្ញុំអាយុ១២ឆ្នាំ ចូលឈ្លប ។

**សៈ** ពេលចូលកងឈ្លបនោះ តើលោកមានភារកិច្ចធ្វើអ្វីខ្លះ?

**ឆៈ** ភារកិច្ចទៅឆ្មក់ទាហាន លន់ នល់ ។

**សៈ** គេឱ្យកាន់អាវុធដែរឬទេ?

**ឆៈ** បាទឱ្យកាន់ ។

**សៈ** អាវុធដែលលោកកាន់ គឺអាវុធម៉ាកអី?

**ឆៈ** អាប្រាំបីណាត់ គេហៅ ប្រាំបីណាត់ នោះណា ។

**សៈ** ពេលនោះមានដែលបានបាញ់ជាមួយទ័ពរបស់ លន់ នល់ ដែរឬទេ?

**ឆៈ** បាទ, បាញ់ បានបាញ់ ។

**សៈ** អ៊ីចឹងលោកអះអាងថា លោកអាយុ១២ឆ្នាំ ត្រូវបានគេបំពាក់កាំភ្លើងឱ្យប្រយុទ្ធជាមួយទ័ព លន់ នល់ ។ លោកបញ្ជាក់ថា ក្រោយបែកភ្នំពេញឆ្នាំ១៩៧៥ រូបលោកទទួលការបណ្តុះបណ្តាលជំនាញទាហាន ។ តើពេលនោះគេមានប្រាប់លោកថា បណ្តុះបណ្តាលជំនាញទាហានហ្នឹងដើម្បីច្បាំងជាមួយអ្នកណា?

**ឆៈ** សូមម្តងទៀត ។

**សៈ** ពេលបែកភ្នំពេញ លោកត្រូវទទួលការបណ្តុះបណ្តាលផ្នែកទាហាន តើពេលនោះគេមានប្រាប់លោកថា គេបណ្តុះបណ្តាលនុ៎ង ដើម្បីយកទៅច្បាំងជាមួយអ្នកណាដែរឬទេ?

**ឆៈ** បណ្តុះបណ្តាលឱ្យទៅវ៉ៃយួន ។

**សៈ** លោកដែលបានទៅវ៉ៃជាមួយយួនដែរឬទេ?

**ឆៈ** អត់បានទៅផង ។

**សៈ** ពេលលោកចូលទៅបាយ ក្រុមលោក តើពេលនោះលោកមានជួបកូនក្មេងដែរឬទេនៅ ស-២១?

**ឆៈ** បាទ, អត់ដែលឃើញជួបកូនក្មេងណាមួយទេ ។

**សៈ** ពេលលោកនៅស-២១ តើមានដែលចូលរួមប្រជុំ ធ្វើការទិតៀន ស្វ័យទិតៀនតាមក្រុមដែរឬទេ?

**ឆៈ** បាទ, មានប្រជុំជីវភាព ទិតៀន ស្វ័យទិតៀន ។ ទិតៀនដើម្បីការពារខ្លួនកុំឱ្យអ្នកទោសរត់ រួចខំប្រឹងយាមកុំឱ្យងុយងោក ។

**ស៖** ប៉ុន្មានថ្ងៃធ្វើការទិតៀនម្តង?

**ឆ៖** បាទសូមជម្រាបមិនទៀង មួយអាទិត្យម្តង ចួនកាលបីថ្ងៃម្តង ។

**ស៖** ពេលនោះអ្នកណាដឹកនាំ?

**ឆ៖** អង្គាល់នុំងដឹកនាំគាត់ មេក្រុម ប៉ុន្តែខ្ញុំអត់ស្គាល់ ភ្លេចឈ្មោះទៅ ។

**ស៖** ពេលលោកយាមនៅស-២១ នោះតើដែលឮសម្រែករបស់អ្នកទោសដែរឬទេ?

**ឆ៖** បាទ, ឮមិនចំជាមនុស្សស្រែកទេ ប៉ុន្តែឮសូរឮ ខ្ញុំនៅឆ្ងាយ ការពារឆ្ងាយ ឮសូររអ៊ូៗ ប៉ុន្តែធម្មតាមនុស្សស្រែកបែបនេះឮសូរហើយ ប៉ុន្តែឮសូរហ្នឹង គឺប្រហែលជាសូរមនុស្សហើយ ។ បើនៅឆ្ងាយស្តាប់មិនបាន ព្រោះខ្ញុំយាមក្រៅ ។

**ស៖** តើសម្រែកនោះលោកគិតថាជាសម្រែកអ្វី?

**ឆ៖** ពិតជាសម្រែកមនុស្ស ។ មនុស្សស្រែកហ្នឹងឈឺដើម្បី គេវ៉ៃក៏មិនដឹង គេទាត់ក៏មិនដឹង ។ ព្រោះសូរ ។

**ស៖** លោកប្រធានខ្ញុំអស់សំណួរ ហើយសូមប្រគល់វេទិកានេះទៅឲ្យសហការីរបស់ខ្ញុំសួរបន្ត។

**សួរដោយលោក អានីស អះមេដ៖**

លោកប្រធានខ្ញុំមានសំណួរតែមួយចំនួនតិចប៉ុណ្ណោះចំពោះសាក្សីរូបនេះ ។

**ស៖** តើលោកធ្លាប់ទទួលការដាក់ពិន័យដែរឬទេ នៅពេលដែលលោកធ្វើការនៅស-២១ នោះ?

**ឆ៖** បាទ, អត់ដែលដាក់ពិន័យ-- សូមម្តងទៀត ខ្ញុំស្តាប់មិនបានវិន័យអ្នកទោស ឬវិន័យគ្នាឯង សូមមានយោបល់ម្តងទៀត ។

**ស៖** ប្រធានរបស់លោក ហុង គេចាប់គាត់ ដោយសារតែគាត់ប្រព្រឹត្តខុស ។ តើគេដែលប្រាប់លោកដែរឬទេថា លោកធ្លាប់ធ្វើខុស ដូច្នេះហើយគេថាកុំឲ្យលោកធ្វើខុសហ្នឹងតទៅទៀត ។ តើគេធ្លាប់ប្រាប់លោកអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ, បានប្រាប់អ៊ីចឹង ណែនាំអ៊ីចឹង ខំកសាងខ្លួនរាល់គ្នា ។

[១០:២៩:៣៦]

**ស៖** តើលោកបានធ្វើខុសយ៉ាងម៉េចនូវអ្វីដែលគេណែនាំលោកហ្នឹង គេប្រាប់ថាលោកធ្វើខុសអី?

**ឆ៖** បាទ, អត់មានការខុស ខំប្រឹងដែរ ខំប្រឹងដោយឃើញខុសហើយ អត់ឲ្យខុសច្រើនថែមទៀត ។

**ស៖** នៅពេលដែលលោកឃើញជនបរទេសម្នាក់ដែលត្រូវបានគេដុតរហូតដល់ស្លាប់ តើលោកធ្លាប់ឃើញគេយកសាកសពទៅកប់នៅជុំវិញទីតាំងដែរឬទេ នៅពេលដែលលោកយាមនៅទីនោះ?

**ឆ៖** បាទ, អត់ឃើញទេ អត់ឃើញយកទៅកប់ ។

**ស៖** សំណួរនេះបានសួរហើយ ប៉ុន្តែលោកធ្លាប់បានឃើញជនជាប់ចោទដែរឬទេ នៅពេលដែលលោកធ្វើការនៅជាអ្នកយាមនៅស-២១ ក្នុងរយៈពេល២ឆ្នាំជាងនោះ ធ្លាប់ឃើញគាត់ដែរឬទេ?

**ឆ៖** សូមទោស មានយោបល់ជូនម្តងទៀត ស្តាប់មិនសូវបាន ចុងអំមិញ ។

**ស៖** តើលោកធ្លាប់ឃើញជនជាប់ដែរឬទេ ក្នុងពេលដែលលោកធ្វើជាអ្នកយាមនៅស-២១នោះ?

**ឆ៖** បាទ, អត់ដែលឃើញអ្នកទោសជាប់នៅកន្លែងនោះអត់ដែលឃើញទេ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញៗ មេធាវីប្រឹក្សា ។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឲ្យលោកសហព្រះរាជអាជ្ញាមេត្តាសួរបញ្ជាក់ឲ្យច្បាស់ពាក្យថាជនជាប់ចោទហ្នឹង ពីព្រោះសាក្សីគាត់យល់ច្រឡំថា ជនជាប់ចោទហ្នឹងគឺអ្នកទោសដែលនៅក្នុងមន្ទីរឃុំឃាំងស-២១ មិនមែនលោក ឌុច ដែលមានវត្តមាននៅទីនេះទេ ។ ដូច្នេះសូមបញ្ជាក់ ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាជាបន្តទៀត ។

[១០:៣២:១១]

**លោក អានីស អះមេដ៖**

**ស៖** តើលោកធ្លាប់បានឃើញ ឌុច ដែរឬទេ ក្នុងពេលដែលលោកធ្វើជាអ្នកយាមនៅស-២១?

**ឆ៖** បាទ, បានឃើញ ។ បានឃើញ បានស្គាល់ទៀត ។

**ស៖** តើលោកបានឃើញគាត់នៅកន្លែងណា នៅពេលដែលលោកធ្វើការនៅស-២១ នោះ?

**ឆ៖** បាទ, ពីកន្លែងនៅ ខ្ញុំអត់បានប៊ាននៅចូលក្នុង ព្រោះខ្ញុំអត់ដែលចូលទៅកន្លែងប្រធាន ចូលកន្លែងទៅខាងក្នុង ខ្ញុំស្គាល់កន្លែងអ្នកទោសអស់ហើយ ។

**ស៖** នៅពេលលោកឃើញ ឌុច នោះ ថាតើលោកបានឃើញគាត់កំពុងតែធ្វើអ្វីដែរនៅពេលនុ៎ង?

**ឆ៖** ឃើញគាត់នោះ គាត់ដើរចេញមកខាងក្រៅ កន្លែងបាយ មកមើលបាយ ។

**ស៖** ថាតើគាត់ទៅប្រាប់គេ ទៅប្រាប់អ្នកដទៃ ឬបុគ្គលិកឲ្យធ្វើអ្វីមួយ ឬកុំឲ្យធ្វើអ្វីមួយ ឬក៏យ៉ាងម៉េច?

**ឆ៖** ជួប ខ្ញុំអត់ដឹងដែរ ប៉ុន្តែរឿងថាម៉េចមួយ និយាយប្រដែប្រដៅម៉េច ខ្ញុំអត់សូវប៊ាននៅដែរ។

**លោក អានីស អះមេដ៖**

ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ខ្ញុំសូមឲ្យធ្វើការបញ្ចាំងនូវរូបភាព ពី 00005247 បន្ទាប់មកគឺខ្ញុំនឹងសួរសំណួរចុងក្រោយរបស់ខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងសោតទស្សន៍ បង្ហាញនូវឯកសារនៅដែលដូចសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

**សួរដោយលោក អានីស អះមេដ៖**

**ស៖** លោក ចៀម សឿ តើលោកឃើញរូបភាពនេះដែរឬទេ? ថាតើលោកចាំទេ ថាកន្លែងដែលលោកដែលលោកហូបបាយនោះ គឺវាជាកន្លែងស្រដៀងនៅនឹងកន្លែងហ្នឹង? អ៊ីចឹងមែនទេ?

**ឆ៖** អត់ស្គាល់ត្រង់ហ្នឹង ។

**ស៖** តើលោកឃើញរូបភាពដែលមានបុរសម្នាក់ឈរនៅខាងឆ្វេងចុងនេះ តើលោកស្គាល់ទេហើយចាំទេ ថាជាអ្នកណាដែរ?

**ឆ៖** បាទ, មើលអត់ច្បាស់ អត់ដឹងទេ ។ អត់ស្គាល់ ។

**ស៖** សូមឲ្យខាងសោតទស្សន៍ផ្តោតចាប់យករូបភាពលើបុគ្គលដែលឈរនៅខាងឆ្វេងដៃនៅក្នុងរូបភាពនេះ ។

ប្រហែលជាសូមឲ្យធ្វើការភ្ជាប់រូបភាពមកកាន់រូបភាពអេក្រង់របស់ខាងសហព្រះរាជអាជ្ញាវិញដើម្បីឲ្យយើងអាចបញ្ចាំងរូបភាពហ្នឹងបានឃើញច្បាស់ជាង ។

លោក ចៀម សឿ តើលោកពេលនេះស្គាល់ទេ ឃើញទេ ឃើញរូបភាពនៅខាងឆ្វេងហ្នឹង ហើយស្គាល់ទេ ថាជាអ្នកណាគេដែរ?

**ឆ៖** ខិនមុខអ៊ីចឹងមើលអត់ឃើញ មុខនេះឃើញតាឈ្មោះ ឌុច ។ ខិនមុខពេក មើលអត់បានឃើញ ។

**ស៖** នៅពេលដែលលោកឃើញ ឌុច ថាតើគាត់នៅបន្ទប់ហូបបាយ ហើយប្រាប់គេអំពីការហូបបាយ ឬក៏យ៉ាងម៉េច?

**ឆ៖** មិនដឹងយ៉ាងម៉េច អត់មានដឹងផងកន្លែងហ្នឹង ខ្ញុំអត់-- បែបក្នុងកន្លែងគាត់ក៏មិនដឹង ។

**ស៖** ខ្ញុំមានសំណួរពីរចុងក្រោយលើបញ្ហាពីរផ្សេង ។ លោក ចៀម សឿ នៅពេលដែលលោកយាម តើលោកយាមច្រកចូលស-២១ ឬក៏លោកធ្វើការយាមបរិវេណទាំងមូលតែម្តង ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងសោតទស្សន៍ដករូបភាពនេះចេញ ហើយបង្វែរទៅរូបភាពធម្មតាឡើងវិញ ហើយសាក្សីឆ្លើយនឹងសំណួររបស់សហព្រះរាជអាជ្ញា ។

**សួរដោយលោក អានីស អះមេដ៖**

**ស៖** ខ្ញុំចង់សួរលោក ចៀម សឿ នៅពេលដែលលោកយាម ស-២១ តើលោកយាមច្រកចូល ស-២១ ឬក៏លោកយាមទៅលើបរិវេណស-២១?

**ឆ៖** បាទ, ខ្ញុំយាមបរិវេណក្រៅផ្លូវច្រកចូលស-២១ ទេ ខ្ញុំយាមខ្សែក្រវាត់ក្រៅ ។

**ស៖** ថាតើវាជាជញ្ជាំងនៅពេលដែលលោកយាមនោះ យាមទៅតាមកន្លែងដែលវាមានជញ្ជាំងជុំវិញ ដែលជាជញ្ជាំងស័ង្កសីនោះ មែនអ៊ីចឹងមែនទេ?

**ឆ៖** បាទ, យាមក្រៅ កៀនរបងក្រៅស័ង្កសី ។

**លោក អានីស អះមេដ៖**

លោកប្រធានខ្ញុំពុំមានសំណួរសម្រាប់សាក្សីរូបនេះទៀតទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវហ្នឹងដល់ពេលត្រូវសម្រាក ។ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី គឺចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តនីតិវិធីសវនាការ ។

មន្ត្រីតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យសម្រាប់សាក្សីរូបនេះផង ហើយឱ្យនាំ

គាត់មកកាន់បន្ទប់សវនាការមុនម៉ោងកំណត់ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកនៅម៉ោង១០:៣៩នាទី ដល់ម៉ោង ១១:០១នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្ត កិច្ចដំណើរការនីតិវិធីសវនាការ ហើយជាបន្តនេះ ផ្តល់វេទិកាទៅមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការសួរដល់សាក្សីរូបនេះ ។ ហើយក្នុងបួនក្រុម គឺមានពេលសម្រាប់សួរសាក្សីរូបនេះសែសិបនាទី ។ សូមអញ្ជើញ។

**ការតាំងសំណួរដោយក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

**សួរដោយលោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស៖**

សូមអរគុណលោកប្រធាន ដែលបានផ្តល់ឱកាសឲ្យខ្ញុំបានសួរ ហើយជាបឋមក្នុងនាមក្រុម--មេធាវីក្រុមដើមបណ្តឹងរដ្ឋប្បវេណីទីបី ខ្ញុំនឹងនិយាយក្នុងនាមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីបួន ហើយនិងបន្តសួរសំណួរទៅសាក្សី ។ ដូច្នេះ ខ្ញុំសុំអនុញ្ញាតសួរសំណួរទីមួយ ទៅសាក្សី ខ្ញុំចង់ឲ្យលោកឆ្លើយសំណួរខ្ញុំ ហើយខ្ញុំសូមស្វាគមន៍ ហើយប្រហែលជាការលំបាកសម្រាប់ឲ្យលោកឆ្លើយសំណួរច្រើននោះ ។

**ស៖** លោកបាននិយាយថា និយាយប្រាប់ទៅអ្នកស៊ើបអង្កេតថា នៅពេលដែលលោកចូលកងយោធា ប៉ុល ពត ក្នុងឆ្នាំ១៩៧៣នោះ គេបានបង្ខំលោកគឺគ្រូរបស់លោក ជាអ្នកបង្ខំលោកឲ្យចូល ។ តើលោកអាចប្រាប់ឲ្យបានពិស្តារជាងហ្នឹងបានឬទេ អំពីការបង្ខំឲ្យលោកចូលថាតើលោកចូលកងទ័ព ប៉ុល ពត ដោយស្ម័គ្រចិត្ត ឬដោយគេបង្ខំ?

**ឆ៖** បាទ, ដោយសារគេបង្ខំ ។

**ស៖** តើលោកអាចពន្យល់ឲ្យបានច្រើនជាងហ្នឹងបន្តិចទេ ថាតើមានរឿងអ្វីកើតឡើងខ្លះ?

**ឆ៖** ខ្ញុំមិនដឹងគេ *(ឮមិនច្បាស់)* ។ សុំម្តងទៀត ។

**ស៖** តើលោកអាចនិយាយឲ្យយើងបានពិស្តារ ឬក៏ច្បាស់លាស់ជាងហ្នឹងបានឬទេ? ថាតើគ្រូរបស់លោកបាននាំលោកទៅចូលយោធា ហើយលោកបានទៅចូលយោធានោះ មិនបានជួបឪពុកម្តាយទេ។ តើលោកអាចនិយាយឲ្យបានលម្អិតបានឬទេ?

**ឆ៖** ដែលគេចាប់បង្ខំទៅចូល ប៉ុល ពត ហ្នឹង ទ្រាំនឹកម្ដាយឪពុកអីចឹងដែរ ប៉ុន្តែមិនប៊ានការ ប៊ានតែនឹងរត់ច្បាប់របស់វាកាលនុំង ខ្ញុំអត់ប៊ានប្រកែក ម្ល៉ោះហើយចេះតែទៅតាមគេទៅ ។

**ស៖** សូមអរគុណលោក ចៀម សឿ ។ ដូច្នេះ បន្ទាប់មកទៀត លោកបានទៅហាត់រៀន ទទួលការហាត់រៀនបាញ់ ហើយនិងដោះមីន ហើយគេប្រាប់លោកថា ការបណ្ដុះ ការរៀនហ្វឹកហាត់នោះ គឺដើម្បីច្បាំងជាមួយវៀតណាម ឬយួន ដែលលោកបានឆ្លើយទៅប្រាប់អ្នកស៊ើបអង្កេតកាលពីមុននោះ ។ តើលោកអាចប្រាប់បន្ថែមបានទេ តើគេបានពន្យល់អ្វីបន្ថែមថា មានជម្លោះជាមួយវៀតណាម ឬជាមួយយួននោះ?

[១១:០៦:១៤]

**ឆ៖** បាទ, ដែលទៅរៀនហ្វឹកហ្វឺនដោះមីន រៀនបាញ់ គេប្រកាសថា យើងរៀនដើម្បីឲ្យចេះទៅវ៉ៃយួន ដល់រួចរៀនចប់មិនបានទៅវ៉ៃយួន ដកមកស-២១ មកវិញ ។

**ស៖** តើលោកបានដឹងទេថា ប្រសិនបើអ្នកណាម្នាក់ក្នុងក្រុមរបស់លោក បានទៅច្បាំងជាមួយវៀតណាមទេ?

**ឆ៖** បាទ, រៀនអង្គភាពទាំងអស់គ្នា គេមានដកដោយឡែក ខ្លះគេទៅវ៉ៃយួន ចំណែកខ្ញុំតូចៗមកស-២១ មកវិញ ។

**ស៖** នៅពេលដែលគេបញ្ជូនលោកទៅស-២១ លោកបាននិយាយថា លោកបានយាមនៅខ្សែខាងក្រៅ ហើយក៏គេប្រាប់លោកថា គឺឲ្យយាមការពារស-២១ ប្រឆាំងនឹងខ្មាំង តើនៅពេលនោះគេថាខ្មាំងហ្នឹងជាអ្នកណា?

**ឆ៖** បាទ, គេថា គេថាយាមខ្មាំងយួន ប៉ុនមិនមែនយួន ទៅជាខ្មែរទាំងអស់ ។

**ស៖** សូមអរគុណលោកចំពោះលោកសាក្សី នេះជាពាក្យសម្ដីដែលលោកបានិយាយទៅអ្នកស៊ើបអង្កេត ថ្ងៃនេះកាលពីមុននោះលោកបាននិយាយអំពីស្ថានភាពដែលលោកបានធ្វើការ ដែលលោកត្រូវធ្វើការយាម ហើយដើរល្បាត ហើយក៏គេឲ្យដាំបន្លែ ដាំបង្កាអ្វីដើម្បីផ្គត់ផ្គង់អង្គភាពខ្លួនឯង ។ តើដាំសម្រាប់តែអ្នកយាម ឬក៏សម្រាប់អ្នកទោសដែលជាប់នៅទីនោះផងដែរ? តើលោកដឹងអ្វីទៀតអំពីរឿងហ្នឹងដែរឬទេ?

**ឆ៖** បាទ, ដែលយាមការខាងក្រៅ ដែលដាំបន្លែបង្កានេះ យកដាក់កំណត់នៅក្នុងអង្គភាព ។

**ស៖** សូមអរគុណច្រើន ។ តើលោកអាចប្រាប់ខ្ញុំបានទេ តើមានការទំនាក់ទំនងរវាងអ្នកយាមខាងក្រៅ ហើយនិងអ្នកដែលនៅខាងក្នុងដែរឬទេ? តើលោកអាចពន្យល់បន្ថែមបានទេពីរឿងហ្នឹង?

**ឆ៖** បាទ, ខាងយាមខាងក្រៅ មិនអាចទាក់ទងទីខាងក្នុងបានទេ ។

[១១:១០:២០]

**ស៖** លោកបានបញ្ជាក់ថា លោកបានឃើញឡាន ហើយឡានទាំងអស់នោះ បានចូលមកស-២១ តើលោកធ្លាប់ឆ្ងល់ទេ តើមនុស្សដែលគេដឹកក្នុងឡាននោះគេយកទៅណា? តើគេដឹងអ្នកទោស ឬក៏គេដឹករបស់អ្វីផ្សេងនៅក្នុងឡាននោះ?

**ឆ៖** បាទ, ខ្ញុំអត់បាន ត្រង់ហ្នឹងអត់បានដឹង អត់បានឃើញ ។ ក្នុងឡាននោះដឹងដឹកមនុស្ស ឬដឹកបន្លែ ឬដឹកបង្កា ដឹកត្រី ដឹកសាច់ ក៏គ្មានដែរ ។ គឺឃើញឡានតែចូលទៅហ៊ុមជិត មានតែដឹកមនុស្សទេ ។

**ស៖** អ៊ីចឹងលោកជឿថា មានមនុស្សនៅក្នុងឡានន៎ុង ដោយហេតុថានៅពេលនោះលោកដឹងថាលោកជាអ្នកយាមនោះ គឺយាមអ្នកទោស តើអ៊ីចឹងមែនឬទេ?

**ឆ៖** បាទ, ខ្ញុំយាមខ្សែក្រវាត់ខាងក្រៅ ដើម្បីឲ្យការពារអ្នកទោសកុំឲ្យរត់ចេញទៅក្រៅរួច ។

**ស៖** សូមអរគុណ ។ លោកនិយាយថា លោកមិនបានចូលរួមនៅក្នុងការវគ្គរៀនសូត្រជាមួយ ឌុច ទេ ប៉ុន្តែនៅពេលនេះខ្ញុំបានពាក្យសម្តី ដែលលោកបញ្ជាក់ទៅអ្នកស៊ើបអង្កេតនៅក្នុង D22/12 ដែលមានលេខ ERN លេខ 0062749 ក្នុងភាសាបារាំង ។

ហើយខ្ញុំសូមរំឭកនូវអ្វីដែលលោកបាននិយាយនោះ គេបានសួរលោកថា "នៅពេលដែលលោកយាមនៅខាងក្រៅគុក តើមានអ្នកណាមកបង្រៀននយោបាយដល់លោកទេ?" លោកឆ្លើយនៅកាលនោះថា "មានតែ ឌុច ហើយនិង ហ៊ ទេ ដែលកោះហៅអ្នកយាមទៅប្រជុំគេបង្រៀនយើងនយោបាយ ហើយគេណែនាំឲ្យយើងយល់អំពីខ្លាំងកុំឲ្យគេរត់រួចខ្លួន" ។ ហើយអ្នកអង្កេតនោះសួរលោកទៀតថា "តើលោកបានជួប ឌុច ផ្ទាល់ទេ?" លោកឆ្លើយថា "បាទ, នៅគ្រប់ការប្រជុំវគ្គរៀនសូត្រនោះទាំងអស់" ។ គេសួរថា "តើ ឌុច និយាយពីអ្វីខ្លះ?" លោកឆ្លើយថា "គេនិយាយអំពីវៀតណាម ឬយួន ពេលដែលខ្ញុំនៅយាមធ្វើម៉េចកុំឲ្យងោក ត្រូវតែប្រឹងប្រែងកសាងខ្លួន ប្រសិនជាមិនអាចកសាងខ្លួនបានទេគេនឹងយកលោកទៅដាក់គុក" ។ "តើគេមានបង្រៀនអ្វីទៀតទេ?" លោកឆ្លើយថា "ទេ" ។

តើលោកអាចបញ្ជាក់ប្រាប់ថា តើលោកពិតជាបាននិយាយបែបនោះឬទេ?

**ឆ៖** បាទ, ដែលកាលទទួលការសិក្សារៀនសូត្រនយោបាយពី ឌុច មកហ្នឹងក៏ខ្ញុំអត់បានទៅចូលរៀន ចូលរួម និងប្រជុំ ឌុច និង ហ៊ី ហ្នឹងដែរ ។ ប៉ុន្តែ មានដាក់បានរៀនពី ប៉េង ទៅចុះបង្រៀនតាមក្រុមនៅខាងក្រៅហ្នឹង គាត់ប្រាប់ពីនយោបាយអ៊ីចឹងមែន ។ ប៉ុន្តែ នយោបាយគាត់ប្រាប់ថា ប៉េង ហ្នឹងគាត់ថានយោបាយមួយកុំឲ្យខ្លាំង អ្នកទោសរត់រួចចេញផុតពីក្នុងមកក្រៅ តែចេញផុតខ្លាំងរត់រួច គឺមិត្តឯងរាល់គ្នានេះគឺជាប់គុកជំនួសអ្នកទោស ។

[១១:១៤:៥៥]

**ស៖** ឥឡូវនេះ ខ្ញុំចង់ចូលទៅដល់អង្គហេតុ ទៅដល់រឿងមួយដែលលោកបានឃើញពាក់ព័ន្ធទៅនឹងអ្នកទោសបរទេសដែលលោកបានឃើញថា គេដុតទាំងរស់ ។ ខ្ញុំសូមអភ័យទោសដោយខ្ញុំត្រឡប់មកចំណុចនេះឡើងវិញ ។ ប៉ុន្តែ ខ្ញុំយល់ថាធ្វើឲ្យលោកឈឺចាប់ក្នុងអារម្មណ៍ ពេលដែលរំឭករឿងហ្នឹង ប៉ុន្តែចង់ឲ្យ លោកផ្តល់ការបំភ្លឺមួយចំនួនលោកបានជម្រាបទៅសហចៅក្រមស៊ើបអង្កេតថា ហេតុការណ៍នោះបានកើតឡើងនៅម៉ោងដប់មួយព្រឹក លោកបាននិយាយថ្ងៃនេះថា បានកើតឡើងនៅម៉ោងប្រាំមួយល្ងាចវិញដើម្បីព្យាយាមឲ្យលោកចាំនៅពេលវេលាហ្នឹងឡើងវិញ ថាតើហេតុការណ៍នោះកើតនៅពេលណានោះ តើលោកអាចរំឭកឡើងវិញពីខណៈពេល ដែលថាតើលោកនៅពេលដែលលោកយាម ប្រចាំការដើរទៅមក ឬក៏នៅពេលណា? អ៊ីចឹងខ្ញុំពិនិត្យមើលទៅឃើញថាមានភាពខុសគ្នារវាងពេលដែលលោកយាម ហើយពេលមួយទៀតដែលលោកអាចយាម អាចដើរយាមពីកន្លែងមួយទៅកន្លែងមួយនៅពេលដែលដើរយាមល្បាត ។

តើពេលដែលយាមល្បាត ឬដែលលោកបានឃើញ ឬក៏ពេលដែលលោកយាមតែមួយកន្លែង? តើពេលយាមហ្នឹងពីម៉ោងប៉ុន្មាន ទៅម៉ោងប៉ុន្មានដែលលោកបានឃើញនោះ?

**ឆ៖** បាទ, ខ្ញុំជម្រាបថា យាមនោះអត់មានបានដឹងម៉ោងដឹងពេលទេ ដូចខ្ញុំជម្រាបខាងលើអម្បាញ់មិញ ។ ខ្ញុំមើលពេលម៉ោង មើលតែថ្ងៃទេ អត់មាននាឡិកាអីពាក់ទេ ដែលទោសអ្នកបរទេះហ្នឹងយាមដើរចុះដើរឡើងអត់មានមកអង្គុយនៅកន្លែងទេ ។

**ស៖** ដូច្នេះតើលោកបានឃើញនោះ លោកនៅចម្ងាយប៉ុន្មានពីកន្លែងដែលឃើញ? តើលោកយាមល្បាតហ្នឹង គឺយាមល្បាតក្នុងចម្ងាយពីកន្លែងហ្នឹងប៉ុន្មានដែរ?

**ឆ៖** បាទ យាមនោះឆ្ងាយដែរ ដើរមកជិតទីដៅកន្លែងយាម ប៉ុន្តែគេដុត បើទីនោះឆ្ងាយចម្ងាយព្រោះខ្ញុំ មិនដឹងម៉ែត្រដឹងតឹក ដឹងហ៊ុនដែរ ប៉ុន្តែឆ្ងាយវាយតម្លៃទៅប្រហែលម្ភៃម៉ែត្រ ពីខ្ញុំនៅឈរនេះ ។

**ស៖** ព្រឹកមិញនេះលោកបាននិយាយថា លោកបាន តើលោកអាចកំណត់ពីបរិវេណដែលលោកដើរធ្វើការនុ៎ង ថាតើទីកន្លែងដែលលោកបានឃើញគេដុតហ្នឹងនៅក្នុងចំណុចណាដែរ?

**ឆ៖** រឿងចំណុចនោះខ្ញុំអត់សូវស្គាល់ចំណុចទេ ប៉ុន្តែផ្លូវមកពីទួលទំពូងហ្នឹង អាផ្លូវទួលទំពូងទៅស្តាតហ្នឹង ព្រោះខ្ញុំស្គាល់ផ្លូវហ្នឹង តែឥឡូវខ្ញុំអត់មានដឹងស្គាល់ ប៉ុន្តែនៅចំណាំផ្លូវហ្នឹងមកទួលទំពូង ។

**ស៖** លោកបាននិយាយថា ចំពោះរូបលោក អ្នកទោសដែលគេយកទៅដុតនឹងកង់ឡាននោះគេដុត ទាំងរស់ តើលោកអាចបញ្ជាក់បានទេ ដែលថាហេតុអីបានជាដឹងថាគេដុតទាំងរស់នោះ?

**ឆ៖** បាទ, ខ្ញុំសូមបញ្ជាក់ ដែលឃើញបណ្តើរទាំងរស់នោះ គឺមនុស្សនោះខ្ញុំឃើញដើរមកអង្គុយទាំងរស់ពិតមែន ។ គេឲ្យអង្គុយទាំងរស់ បានខ្ញុំដើរចេញទៅគេលើកកង់ឡាន ដាក់លើមនុស្សរស់អង្គុយហ្នឹង បានខ្ញុំដើរទៅវិញ ។

[១១:២០:៣៥]

**ស៖** តើលោកបានឮសំឡេងស្រែកអ្វីដែរឬទេ?

**ឆ៖** បាទ, អត់មានឮសូរសំឡេងស្រែក ។

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់ ថាតើលោកយល់ដូចម្តេចដែរ ក្រោយពីបានឃើញហេតុការណ៍នោះនៅពេលនោះ?

**ឆ៖** ខ្ញុំជម្រាប គ្មានយល់គ្មានគិតគូរផលវិបាក ព្រោះអីនឹកឃើញកាលនោះនយោបាយថាឆ្កែតនឹកឃើញដុតគ្នាទាំងរស់មួយ ប៉ុន្តែភាសាមួយអត់ចេះក៏មិនដឹង ចេះតែយកគ្នាមក គួរអាណិតអាសូរដល់រូបអ៊ីចឹងដែរ ។

**ស៖** ឥឡូវនេះ តើលោកយល់ថាដូចម្តេចដែរ នៅពេលគិតដល់រឿងនោះដែលលោកបានឃើញពីពេលនោះ?

**ឆ៖** បាទ, គិតឃើញរូបដុតទាំងរស់ប៉ុននុ៎ងហើយ ទម្រាំរូបខ្លួនខ្ញុំដែលខុសឆ្គងទៅ បែបដុតទាំងរស់ ឬកប់ វ៉ៃទាំងរស់អ៊ីចឹងដែរ គិតដល់ខ្លួនរបស់ឯង ។

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្ស ណាព្រូស៖**

សូមអរគុណ លោក ចៀម សឿ ខ្ញុំមិនមានសំណួរអ្វីទៀតទេ ។ ដូច្នេះ ខ្ញុំអនុញ្ញាតឲ្យមេធាវី ដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីបួន បន្តសួរលោក ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ បាទ ។

**សួរដោយលោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំបាទឈ្មោះ គង់ ពិសី ជាមេធាវីតំណាងឲ្យក្រុមប្ដូនដែរ ។ ជាបឋមសូមគោរពលោក លោកស្រីចៅក្រមដែលជាចៅក្រមជាតិ ហើយនិងចៅក្រមអន្តរជាតិ ។

សួស្ដី លោក ចៀម សឿ ។ ខ្ញុំបាទសុំសួរលោកតែចំនួនបីសំណួរទេ ដើម្បីបញ្ជាក់ឲ្យច្បាស់បន្តិច ព្រោះលោកមិនទាន់បានបំភ្លឺ ក្រោយពីចៅក្រមបានសួររួចហើយ ។

[១១:២៣:៣៥]

**ស៖** លោកបានបញ្ជាក់ជូនអង្គសវនាការថាឈ្មោះ ចាន់ ហៅ សម្រែងបានទៅយកលោកមក។ ខ្ញុំចង់ជម្រាបសួរលោកថា តើ ចាន់ ហ្នឹងមានឈ្មោះក្រៅអីដែរ? លោកមានដឹងទេ?

**ឆ៖** បាទ, ខ្ញុំអត់ដឹងឈ្មោះអីទៀតដែរ គ្រាន់តែឮសូរតែឈ្មោះ ចាន់ ហ្នឹង ។

**ស៖** សូមអរគុណ ។ ចុះលោកមានដឹងថា តួនាទី ឬក៏តំណែងអីរបស់គាត់ទេ? បើសិនជាយើងរាប់ពីឈ្មោះលោក ឌុច ចុះមកក្រោម?

**ឆ៖** ចុះមកក្រោមមានតែ ចាន់ ហ្នឹង ហើយនិង ប៉េង ហ្នឹងដែលរាប់ចុះពីក្រោម ឌុច ហ្នឹងមក។

**ស៖** សូមអរគុណ ។ សំណួរមួយទៀតទាក់ទងទៅនឹងប្រធានរបស់លោកឈ្មោះ ហុង ដែលត្រូវចាប់ខ្លួន ហើយឃុំក្នុងមន្ទីរឃុំឃាំងស-២១ នោះដែរ ហើយលោកបានជម្រាបអង្គសវនាការ ហើយថាឈ្មោះ ខៀវ ពៅ គឺជាប្អូនរបស់ឈ្មោះ ហុង ។ ហើយឈ្មោះ ហុង ហ្នឹងហើយលោកដឹងថា ឈ្មោះ ហុង ហ្នឹងត្រូវចាប់ខ្លួនឃុំនៅទីនោះ ដោយសារតែឈ្មោះ ខៀវ ពៅ ហ្នឹងប្រាប់លោក ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើគាត់ប្រាប់លោកយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំស្ដាប់អត់បាន ។ សូមអញ្ជើញនិយាយម្ដងទៀត ។

**ស៖** សូមអភ័យទោស ។ ឈ្មោះ ហុង គឺជាប្រធានក្រុមរបស់លោក ហើយ ហុង ហ្នឹងត្រូវបានចាប់ខ្លួនឃុំនៅមន្ទីរស-២១ ដែរ ហើយឃុំនៅខាងក្នុងនោះ ។ ហុង មានប្អូនឈ្មោះ ខៀវ ពៅ ។ ហើយ ខៀវ ពៅ នោះបានឃើញបងរបស់គាត់ឃុំខ្លួននៅទីនោះ ហើយលោកដឹងតាមរយៈគាត់ ។ អ៊ីចឹង ខ្ញុំចង់ដឹងថាតើ ហុង ហ្នឹងបានប្រាប់លោកថាម៉េចដែរ?

**ឆ៖** បាទ, ដែលប្រធានក្រុម ហុង ហ្នឹងដែលនៅរស់នៅកាន់ក្តាប់ ដែលគេមិនទាន់ចាប់នៅចូលក្នុងគុកស-២១ ហ្នឹងប្រាប់ណែនាំដូចខ្ញុំនិយាយខាងដើមថា ណែនាំខំប្រឹងកសាងខ្លួនកុំឲ្យដូចគាត់ការពារខ្លួនឲ្យ កសាងខ្លួនឲ្យម៉ឺងម៉ាត់ ខំយាមកាមឲ្យម៉ឺងម៉ាត់ កុំឲ្យខ្មាំងរួចកុំឲ្យដូចគាត់ ។ ពេលនោះ ខ្ញុំរ៉ាយរ៉ាប់ប្រាប់អស់បាន ខៀវ ពៅ ជាប្អូនចេញមកជួបខ្ញុំនៅកន្លែងបាយមួយភ្លែតប្រាប់ថា ខ្ញុំ អញបងអញគេចាប់ថ្ងៃនុ៎ង មិនមែនចាប់យកទៅរៀនសូត្រទេ ចាប់យកដាក់គុក ។ អញឃាមបងអញនុ៎ងស្រេចហើយ ។ បានខ្ញុំបានដឹងថា ប្រធានក្រុម ហុង គឺជាប់គុកហើយ ។

[១១:២៧:០៧]

**ស៖** សូមអរគុណ ។ អ៊ីចឹងខ្ញុំចង់សួរលោកបន្តទៀត តើបន្ទាប់មកវាសនារបស់ ខៀវ ពៅ ដែលជាប្អូន ហុង ត្រូវបានគេចាប់ខ្លួនទេ?

**ឆ៖** បាទ, ខៀវ ពៅ អត់បានចាប់ខ្លួនទេ ព្រោះអីអត់ដឹងនៅឃាមខាងក្នុងក៏ខ្ញុំអត់បានដឹងដែរ ព្រោះអីមិនបាច់តែចាំឆ្លើយរកបង ហុង ហ្នឹង អត់ប៉ានឆ្លើយថាបងប្អូនសាច់ឈាមលោហិត បើឆ្លើយថាសាច់ឈាមលោហិតជាប់ជាបងប្អូន ត្រូវ ខៀវ ពៅ ហ្នឹងក៏ជាប់គុកទៀតដែរ ។ ដូចពាក្យគាត់ថា កាប់ស្មៅទើសកកាយទាំងឫសហើយ ទោះបីបងប្អូនបង្កើតក៏អត់ស្គាល់គ្នាដែរ ។ ទើសតែធ្វើមុខដាក់គ្នាធ្វើមនុស្សអ្នកក្រៅ បានអាចរស់ កន្លែងនេះ ។

**ស៖** សូមអរគុណ ។ អ៊ីចឹងក្រោយមកទៀតនៅពេលដែលលោកទៅជួប-- (សូមអភ័យទោស) អ៊ីចឹងក្រោយមកទៀតនៅពេលដែលលោកទៅហូបបាយ លោកដែលជួបឈ្មោះ ខៀវ ពៅ ទៀតទេ?

**ឆ៖** បាទ, អត់បានជួបទៀតទេ ជួបតែម្តងនោះ ជួបដែលជាប់ប្រាប់ថា បងជាប់គុក ។

**ស៖** សូមអរគុណ ។ សំណួរមួយទៀតទាក់ទងទៅនឹងការលត់ដំនៅព្រៃស លោកបានជម្រាបជូនអង្គសវនការហើយថា ការលត់ដំនៅព្រៃសនោះ លោកទៅហ្នឹងគឺថាទៅទាំងក្រុម ។ អ៊ីចឹង សួរថាតើលោកមានដឹងថាក្រុមរបស់លោកហ្នឹងខុសអីទេ?

**ឆ៖** បាទ, អត់ដឹងខុស ដឹងត្រូវអីទេ ស្រេចអង្គការគេបញ្ជូនទៅ ។ គេថាដកមួយក្រុមហ្នឹងទៅធ្វើ ស្រែតែម្តងអត់មានថាខុស អ្នកណាខុស អ្នកណាត្រូវ ។

**ស៖** អ៊ីចឹងនៅពេលដែលដកលោកទៅខាងព្រៃស គេមានបានប្រាប់លោកថាតើទោសរបស់លោកគឺជាប់ទោសអីទេទៅដល់ព្រៃស?

**ឆ៖** បាទ, ទៅដល់ព្រៃសហ្នឹងថា គេមានភារកិច្ចអីទេ មានតែឲ្យធ្វើស្រែ ហើយនិងស្ទូងដក លើកទំនប់ ។ នៅទំនប់នុ៎ងខ្ញុំអត់ស្គាល់ដែរ ។

**ស៖** សូមអរគុណ ។ ខ្ញុំសូមបន្តសំណួរបន្តិចទៀតថា តើនៅពេលដែលយើងធ្វើការ មានការយាមកាមអីទេក្រុមរបស់លោក?

**ឆ៖** សូមជម្រាបម្តងទៀត អត់ច្បាស់ ។

**ស៖** នៅពេលដែលលោកចុះទៅធ្វើការនៅឯស្រែ តើមានអ្នកយាមដើរយាមក្រុមលោកពេលកំពុងធ្វើការទេ?

**ឆ៖** បាទ, ឡើងពីធ្វើស្រែមានអ្នកយាមយប់ យាមតែគ្នាឯងដេក អត់មានយាមអីទៀត ការពារខ្លួនឯង គ្នាឯង ។

[១១:៣១:១៦]

**ស៖** សូមអរគុណ ។ លោកថា ការពារគ្នាឯង អ៊ីចឹងលោកចង់មានន័យថា ក្រុមរបស់លោកការពារក្រុមលោកអ៊ីចឹង ឬមួយយ៉ាងម៉េច?

**ឆ៖** បាទ, យាមការពារក្នុងក្រុមរបស់ខ្លួនហ្នឹង យាមម្តងម្នាក់ យាមទាំងកន្លែងដេកគ្នាឯង កុំឲ្យមានការបាត់សម្ភារៈ ដូចជាឆ្នាំង ដូចជាចាន ការពារកុំឲ្យស្អីៗ ស្ទូងដកអី ស្ទូងដេកនឹងស្រែ ។

**ស៖** សូមអរគុណ ។ ចុះពេលដែលលោកស្នាក់នៅពេលយប់ តើលោកស្នាក់នៅកន្លែងណានៅព្រៃសនោះ? បន្ទប់យ៉ាងម៉េចដែរ?

**ឆ៖** បាទ, ស្នាក់ក្នុងរោង ដើមឈើ-- សរសរឈើ ធ្វើរោងវែងនៅនឹងស្រែ ។

**ស៖** អ៊ីចឹងនៅក្នុងបន្ទប់ហ្នឹង ពេលយប់គេមានចាក់សោទេ? ហើយមានអ្នកយាមនៅខាងក្រៅទេ?

**ឆ៖** សុំម្តងទៀត ។

**ស៖** នៅក្នុងផ្ទះនៅឯព្រៃស ដែលលោកស្នាក់នៅពេលយប់ ។ មានចាក់សោពីក្រៅទេ? ហើយមានអ្នកយាមនៅខាងក្រៅទេ យាមលោក?

**ឆ៖** បាទ អត់មានសោ អត់មានជញ្ជាំងទេ វាលល្វឹងទេ ចងអង្រឹងតាមបង្គោលក្នុងរោង ។

**លោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមអស់សំណួរ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ សូមប្រគល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការសួរដល់សាក្សីរូបនេះ ប្រសិនបើមានសំណួរ ។ សូមអញ្ជើញបាទ ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី៖**

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ។ សូមគោរពលោកប្រធាន និងសូមគោរពចៅក្រមជាតិ និងអន្តរ-ជាតិ និងសូមគោរពអង្គសវនាការទាំងមូល ។

**ស៖** លោក សឿ លោកធ្វើការនៅស-២១ តើលោកដែលដឹងទេ តើអ្នកធំណានៅសម័យនោះដែលមានសិទ្ធិបញ្ជាពីលើ ស-២១ គឺមានសិទ្ធិបញ្ជាទៅលើ តាឌុច ?

[១១:៣៣:៤៧]

**ឆ៖** បាទ, ពីខាងលើៗតាឌុច នេះ ខ្ញុំអត់បានដឹងទេ ។ ដឹងប្រធានគាត់ គាត់ទទួលពីច្បាប់ពីលើប្រធានគាត់ ខ្ញុំបាទអត់បានដឹង ។

**ស៖** សូមអរគុណ ។ លោកធ្វើការនៅស-២១ ដដែល តើលោកដែលឃើញ ឬក៏ដែលឮថា តាឌុច ធ្វើទារុណកម្ម ឬសម្លាប់អ្នកទោសឬទេ?

**ឆ៖** បាទ, ច្បាប់ពីតាឌុច ហ្នឹងហើយបាន-- ច្បាប់ចេញពីតាឌុច បានចេញជាសម្លាប់មនុស្សនៅក្នុងគុកទួលស្លែង ។

**ស៖** សូមអរគុណ ។ ខ្ញុំសូមបញ្ជាក់លោកម្តងទៀត លោកធ្វើការ លោកយាមនៅទីនោះ តើលោកដែលឃើញ ឬក៏ដែលឮគេថា តាឌុច ហ្នឹងធ្វើទារុណកម្ម ឬក៏សម្លាប់អ្នកទោសឬទេ? សូមលោកបញ្ជាក់ បើលោកដែលឃើញ លោកដែលឮ សូមលោកបញ្ជាក់ ។

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! ច្បាប់នៅ តាឌុច គាត់ដាក់ផែនការមកក្រោមៗ។ ប៉ុន្តែ ដូចកាលគាត់ទទួលពីផែនលើមក ខ្ញុំអត់ដឹង ប៉ុន្តែឃើញគាត់ដាក់បញ្ជាឲ្យកូនចៅក្រោមៗហ្នឹង សម្លាប់គេ។ ក៏ចំណែកគាត់អត់មានឃើញថា សម្លាប់គេដែរទេ ។ ប៉ុន្តែ ច្បាប់នេះ គាត់ដាក់ក្រោមបទបញ្ជាថា យប់ៗ ថ្ងៃៗ ។ ហ្នឹងដូចពាក្យថា បញ្ជាដូចជាសម្លាប់អីចឹង ។

**ស៖** សូមអរគុណដែលលោកឆ្លើយថាមិនដែលឃើញ តាឌុចសម្លាប់ដោយផ្ទាល់ភ្នែកលោកទេ។ ពេលនៅស-២១ដដែល លោកទទួលភារកិច្ចយាមកុំឲ្យអ្នកទោសរត់រួច តើពេលនោះលោកពេញ

ចិត្តទេ លោកសប្បាយចិត្តនឹងការងាររបស់លោកឬទេ?

**ឆ៖** បាទ, សូមជម្រាបអស់លោកថាពេញចិត្តយាមដើម្បីការពារខ្លួន ខ្លាចផែនការតា គាត់ដាក់ទៅក្រោមទៅទៀត ក៏ខ្លួនខ្ញុំសម្រាប់កសាងខ្លួន ដើម្បីរស់សព្វថ្ងៃនេះ ។ បើខ្ញុំមិនកសាងខ្លួនត្រូវតែទៅទៀត ។

**ស៖** សូមអរគុណ ។ អ៊ីចឹង លោកពេញចិត្តនឹងការងារនុ៎ង ដោយគោរពទៅតាមការងារដែលថ្នាក់លើបានដាក់ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន សូមបង្វែងឲ្យលោកចៅក្រមអន្តរជាតិមេត្តាសួរបន្តទៅទៀត ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ស្រ្វង់ស្វ័រ រូ ។

[១១:៣៧:០៥]

**សួរដោយ លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។

អរុណសួស្តីលោកសាក្សី ។ ខ្ញុំជាមេធាវីទីពីរសម្រាប់ជនជាប់ចោទ ឌុច ហើយខ្ញុំចង់សួរសំណួរមួយចំនួនជូនលោក គឺខ្ញុំមិនសួរច្រើនទេ ។

**ស៖** តើលោកស្គាល់ ហ៊ីម ហ៊ុយ ដែរឬទេ?

**ឆ៖** បាទ, ខ្ញុំអត់បានស្គាល់ទេ ហ៊ីម ហ៊ុយ ហ្នឹង គឺហ៊ុយហ្នឹង នៅខាងក្នុងដៃខាង-- នៅក្នុងជាមួយដឹកជញ្ជូនសម្រាប់យកទៅសម្លាប់តែម្តង ។ ខ្ញុំទើបជួបហ្នឹងហើយ ជួបដែលមកសម្ភាសទាំងអស់គ្នាហ្នឹងហើយ ។

**ស៖** លោកបាននិយាយថា លោកជួបគាត់នៅពេលក្រោយមក តើលោកជួបគាត់នៅកន្លែងណាដែលក្រោយមកហ្នឹង?

**ឆ៖** បាទ, ជួបកន្លែងសម្ភាស នៅកន្លែងគុកទួលស្លែង ។

**ស៖** ថាតើលោកនិយាយថា ជួបកន្លែងសម្ភាសហ្នឹង លោកចង់បានន័យយ៉ាងម៉េចដែរ?

**ឆ៖** ដែលជួបហ្នឹង ស្គាល់ ហ៊ុយ ហ្នឹងទើបជួបគ្នា ក៏បែកគ្នាអត់បែក-- អត់ពេលនៅក្នុងគុក ខ្ញុំអត់បានស្គាល់ ហ៊ឹម ហ៊ុយ នេះទេ ព្រោះនៅក្នុង-- ប៉ុន្តែដែលជួប គេហៅមកសួរដឹងចេញជាច្បាប់មកសួរចម្លើយនៅក្នុងគុកទួលស្លែងនេះ គឺគាត់បានឃើញមែន ។ បានដឹងថា ហ៊ឹម ហ៊ុយ អ្នកដឹកឡានសម្លាប់វត្តជើងឯក ។

**ស៖** សូមអរគុណដែលលោកបានឆ្លើយបញ្ជាក់លើចំណុចនេះ ។ ខ្ញុំសូមនិយាយទៅលើការងាររបស់លោក ដែលលោកបានធ្វើនៅស-២១ វិញ ។ នៅពេលដែលលោកដើរយាម--
លោកចង់និយាយអ្វីបន្ថែមទៀត ឬក៏យ៉ាងម៉េច? ប្រសិនបើចង់នោះ សូមបើកមីក្រូហ្វូនផង ។

**ឆ៖** ខ្ញុំចង់-- អត់ចង់និយាយទៀតទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញៗមេធាវីប្រឹក្សាសាក្សី ។

**លោក គង់ សំអុន៖**

ខ្ញុំបាទសូមជួបសាក្សីមួយភ្លែត ។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតៗតុលាការអនុញ្ញាត ។

*[មេធាវីជួបប្រឹក្សាជាមួយសាក្សី]*

[១១:៤២:១៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ ។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន សាក្សីគាត់មិនអាចស្តាប់ភាសា ដោយសារនិយាយញាប់ពេក ធ្វើឱ្យគាត់មានអារម្មណ៍មិនស្រួលក្នុងខ្លួន ។ ហើយបើសិនជាលោកមេធាវីគាត់សួរបន្តទៀត សូមឱ្យនិយាយមួយៗ ខ្លីៗឱ្យគាត់បានស្តាប់បាន ។ បើអ៊ីចឹងគាត់មិនអាចឆ្លើយសំណួរតទៀតបានទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ អង្គជំនុំជម្រះសូមរំឭកថា សាក្សីសុំសម្រួលអារម្មណ៍ឱ្យបានល្អ មិនជាបញ្ហាអ្វីទេ ។ ហើយស្តាប់សំណួរឱ្យបានច្បាស់ ហើយបើមិនច្បាស់លោកដូចធ្វើដូចពីព្រឹកអ៊ីចឹង ថាបើមិនច្បាស់លាស់

ទេសូមឲ្យសួរសំណួរម្តងទៀត ។ ហើយបើសួរទៅមិនច្បាស់ គឺលោកអាចនិយាយដូច្នេះ សំណូមពរដល់អ្នកដែលសួរឲ្យច្បាស់ ហើយស្តាប់ឲ្យច្បាស់ហើយសឹមលោកឆ្លើយ ។ លោកដឹង គឺឆ្លើយថាដឹងយ៉ាងម៉េច បើលោកមិនដឹង លោកឆ្លើយថា មិនដឹងទៅវាជាការស្រេចហើយ ។ លោកបានធ្វើព្រឹកមិញបានល្អច្រើនហើយ អង្គជំនុំជម្រះសង្ឃឹមថាលោកនឹងធ្វើកិច្ចការល្អ ហើយដូចជាជិតដល់ទីបញ្ចប់ហើយ។

សូមអញ្ជើញលោកមេធាវី ហើយសម្រួលនិងមានការយល់អំពីស្ថានភាពនៃសាក្សី ដែលមានកម្រិតយល់ដឹងទាបដូច្នេះ គឺថាសូមសម្រួលធ្វើម៉េចឲ្យបានគាត់យល់នូវសំណួរ ហើយនិងគាត់អាចមានលទ្ធភាពឆ្លើយតបនឹងសំណួរបានត្រឹមត្រូវ ។

សូមអញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ លោកសាក្សី យើងនឹងបន្តទៀត ដោយខ្ញុំសួរខ្លីៗ ។

**ស៖** នៅពេលដែលលោកដើរយាមនៅស-២១ តើលោកដើរយាមតែម្នាក់ឯង តើលោកដើរយាមមានមនុស្សមួយទៀតដើរជាមួយលោក ឬក៏លោកយាមបីនាក់? តើលោកយល់សំណួរខ្ញុំដែរឬទេ? ថានៅពេលដែលលោកដើរយាមៗម្នាក់ឯង? ឬក៏លោកដើរយាមជាមួយនឹងអ្នកយាមផ្សេងទៀត ដែលដើរយាមជាមួយលោក?

[១១:៤៥:00]

**ឆ៖** បាទ, ដើរយាមធម្មតា ដើរយាម-- ខ្ញុំជម្រាបដើរយាមក្នុងមួយពេលពីរនាក់ ចុះឡើង ឬបីនាក់តាមពេលវេលាម៉ោង ។

**ស៖** ខ្ញុំសូមអរគុណ ។ នៅពេលដែលលោកឃើញអ្នកទោសបរទេសត្រូវគេដុតសម្លាប់ចោលនោះ តើលោកនៅយាមម្នាក់ឯងទេ ឬក៏មានអ្នកយាមមួយទៀតដើរយាមជាមួយលោកនៅពេលដែលលោកឃើញគេដុតអ្នកទោសបរទេសនុ៎ង?

**ឆ៖** បាទ, សូមស្នើម្តងទៀត ។

**ប្រធានអង្គជំនុំ៖**

គាត់សុំឲ្យលោកមេធាវីតាំងសំណួរអម្បាញ់មិញនេះម្តងទៀត ព្រោះគាត់ស្តាប់អត់យល់សំណួរ។

**សួរដោយលោក ហ្វ្រង់ស្វ័រ រូ៖**

**ស៖** លោកសាក្សី ខ្ញុំចង់សួរថា នៅពេលដែលលោកឃើញហេតុការណ៍ដែលលោកបានជម្រាប

យើងខ្ញុំនោះ គឺទាក់ទងទៅនឹងដុតអ្នកទោសបរទេសនោះ ។ នៅពេលដែលលោកឃើញទ្នុំង តើលោកដើរយាមម្នាក់ឯង? ឬក៏ពេលដែលលោកឃើញហ្នឹង លោកដើរយាមជាមួយអ្នកយាមពីរនាក់ បីនាក់ទៀតជាមួយលោក?

**ឆ៖** បាទ, ដើរយាមនេះ ដើរយាមម្តងបីនាក់ ពីរនាក់តាមកម្លាំង ។

**ស៖** តើលោកបានចាំដែរឬទេថា តើអ្នកដើរយាមជាមួយលោកនោះឈ្មោះអីដែរ?

**ឆ៖** បាទ, យូរឆ្នាំហើយមិនបានចាំទេ ។

**ស៖** លោកបាននិយាយថា លោកអត់មានពាក់នាឡិកានោះទេ ។ ខ្ញុំចង់ឲ្យលោកជម្រាបយើងខ្ញុំតាមការចងចាំរបស់លោក លោកយាមនៅវេនណា? នៅពេលណា? ដោយសារតែពេលមុននោះ គឺខ្ញុំហាក់ដូចជាមិនយល់ ប្រហែលជាបញ្ហាបកប្រែឬក៏យ៉ាងម៉េច? ដូច្នេះ ខ្ញុំចង់សួរថា តើនៅពេលដែលលោកយាមហ្នឹង លោកយាមពីពេលណា? បានន័យថាចាប់ពីម៉ោងប៉ុន្មានទៅម៉ោងប៉ុន្មាន? ហើយនៅពេលណាមួយ?

[១១:៤៨:៥៨]

**ឆ៖** បាទ, ខ្ញុំយាមចាប់ពីម៉ោងប្រាំមួយទាល់តែម៉ោង១២ ។

**ស៖** សូមអរគុណលោកបានឆ្លើយយ៉ាងច្បាស់ ។ សូមអរគុណច្រើន ។ លោកបាននិយាយថា លោកមិនបានឃើញហេតុការណ៍គេដុតនោះរហូតដល់ចប់នោះទេ ដោយសារតែនៅពេលនោះលោកបញ្ចប់វេនយាមរបស់លោក តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, ឃើញនោះមិនទាន់ចប់ជាការត្រឹមត្រូវផុតវេនយាមរបស់ខ្ញុំ ។

**ស៖** ដូច្នេះខ្ញុំអាចយល់ថា ហេតុការណ៍ដែលគេដុត គឺកើតឡើងនៅពេលយប់ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ដុតនោះម៉ោងប្រាំមួយ ចាប់គេបណ្តើរទៅម៉ោង ប៉ុន្តែរឿងដុតនោះឆេះដល់យប់ ប៉ុន្តែខ្មោចមិនទាន់សុះ ដូចខ្ញុំជម្រាបខាងដើមលើ ។

**ស៖** ដូច្នេះ លោកបានឃើញការដុតសាកសពនោះនៅពេលដែលលោកចាប់ផ្តើមធ្វើការងារយាមរបស់លោក តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, ត្រឹមត្រូវដោយខ្ញុំឃើញនោះ ឃើញបណ្តើរទៅចាក់ដុតនោះ គឺវេនរបស់ខ្ញុំយាម ។

**ស៖** ខ្ញុំសូមអរគុណលោក ។ អម្បាញ់មិញលោកបាននិយាយថា គឺវាការដុតនោះ គឺវានៅកន្លែងផ្លូវទៅទួលទំពូង តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, ត្រឹមត្រូវ ។

**ស៖** អ៊ីចឹង គឺអាផ្លូវហ្នឹងជាផ្លូវជាតិហ្នឹងមែនទេ? ផ្លូវធំយើងមែនទេ?

**ឆ៖** ពីជំនាន់នុំងមិនដឹងផ្លូវធំ មិនដឹងផ្លូវតូចទេ ប៉ុន្តែឃើញតែដាច់ផ្លូវថ្នល់ជាតិតែម្តង ផ្លូវមកទួលទំពូង ។

**ស៖** ហើយលោកបានប្រាប់អម្បាញ់មិញដែរថា លោកបានប្រាប់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីអម្បាញ់មិញនោះថា នៅពេលដែលគេដុតសាកសពនោះ ឬដុតជនបរទេសនោះលោកប្រហែលជានៅចម្ងាយម្ភៃម៉ែត្រពីកន្លែងដុត តើត្រឹមត្រូវដែរឬទេ?

[១១:៥៣:០៦]

**ឆ៖** បាទ, ខ្ញុំនិយាយត្រឹមត្រូវ ។

**ស៖** លោកក៏បានប្រាប់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីអម្បាញ់មិញផងដែរថា លោកមិនធ្លាប់បានឮសំឡេងស្រែកទេ អ៊ីចឹងមែនដែរឬទេ?

**ឆ៖** ត្រឹមត្រូវ ។

**ស៖** សូមអរគុណលោកសាក្សី ។

**លោក ហ្វេង់ស្វ័រ រូ៖**

ខ្ញុំពុំមានសំណួរបន្ថែមទៀតសួរសាក្សីនោះទេ លោកប្រធានសូមអរគុណច្រើន ។

**ប្រធានអង្គជំនុំ៖**

ជាចុងក្រោយនេះ អង្គជំនុំជម្រះផ្តល់វេទិកាទៅជនជាប់ចោទដើម្បីធ្វើការកត់សម្គាល់អំពីសក្ខីកម្មរបស់សាក្សីរូបនេះ ប្រសិនបើជនជាប់ចោទមានបំណង ។ សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ខ្ញុំនៅរង់ចាំសាក្សីនេះយូរហើយ ក្នុងការអធិប្បាយឆ្លើយតបនឹងបណ្តឹងរដ្ឋប្បវេណីរបស់លោកតា អាល់មីល ក៏ខ្ញុំអត់ប៉ានទាន់និយាយពីបញ្ហានេះ ព្រោះខ្ញុំមិនដឹងច្បាស់ ។

បទបញ្ជារបស់ខ្ញុំ គឺឲ្យគេដុតខ្មោចដែលសម្លាប់ហើយ ក៏ប៉ុន្តែដល់ក្រោយមកលេចថា គេដុតទាំង

រស់ ។ បញ្ហានេះឆ្លងកាត់ការតទល់ (សូមទោស) ការជជែកវែកនៅក្នុងអង្គសវនាការយើងនេះ ខ្ញុំឃើញសក្ខីកម្មទីមួយរបស់មិត្តហ៊ុយ ។ សង្កេតទៅឃើញដូចសក្ខីកម្មនេះច្បាស់លាស់ជាងគេ ព្រោះពួកនេះទទួលភារកិច្ចខាងរឿងកម្ទេចនេះឯង គ្រាន់តគេមិននិយាយឲ្យជ្រៅ ព្រោះបើគេនិយាយឲ្យជ្រៅទៅវាចូលទៅក្នុងការដែលថា ដាក់បន្ទុកលើខ្លួនឯង ។

រំពឹងហេតុផលផ្ទុយដែលថា ដុតទាំងរស់ មិត្តខន និយាយថា ហ៊ឺ! សឿប្រាប់ ។ ចង់ដឹងរឿងច្បាស់ឲ្យទៅសួរ សឿ ។ ប្រាក់ ខន ខ្លួនឯង មិត្តខន ខ្លួនឯងអត់បានិយាយថា ឃើញផ្ទាល់អីៗទេ ។ ហើយដល់មកលោក ចៀម សឿ ឲ្យសក្ខីកម្ម លោកឆ្លើយជូនសហចៅក្រមថា ប្រាក់ ខន ក៏ដោយ បង ម៉ម ណៃ ហៅ ចាន់ ក៏ដោយ លោកទើបនឹងស្គាល់នៅពេលថតកុននេះទេ ។ ហើយអំមិញទៀត ឆ្លើយនឹងសំណួររបស់មេធាវី ហ្វ្រង់ស្វ័រ រូ លោកឆ្លើយថា ហ៊ឹម ហ៊ុយ ក៏ទើបតែនឹងស្គាល់ក្រោយដែរ ។

ដូច្នេះ សក្ខីកម្មអស់នេះវាធ្វើឲ្យអំណះអំណាងគាត់ដែលថា ឃើញគេដុតខ្មោចទាំងរស់-- មនុស្សទាំងរស់វាបែរជារឿងមួយដែលមិនសូវមានទម្ងន់ មិនធ្វើឲ្យអ្នកផងជឿ ។ ដូច្នេះ សក្ខីកម្មទាំងប៉ុន្មានដែលលើកមកនេះ ខ្ញុំមិនទាន់ដាច់ស្រេចថា មិនជឿថា គេដុតមនុស្សទាំងរស់ទេ នៅតែជឿសក្ខីកម្មរបស់មិត្តហ៊ុយ ច្រើនជាង ។ នៅតែជឿថា គ្មានអ្នកណាបានល្មើសនឹងបទបញ្ជារបស់ខ្ញុំទេ បទបញ្ជារបស់ខ្ញុំដាច់ខាតណាស់ ត្រូវតែយកទៅទាំងពីរ ។ ហើយសម្លាប់ហើយ ដុតឲ្យខ្ទេច មិនមែនដុតហើយនៅសល់ខ្មោចទាំងននលគកនៅលើផ្លូវ១៤៣ អត់ទេ ។

[១១:៥៧:២៨]

**ប្រធានអង្គជំនុំ៖**

សូមៗលោករំឮកម្តងទៀតថា លោកជនជាប់ចោទត្រូវការវិភាគ ឬក៏កត់សម្គាល់ហ្នឹង គឺនិយាយជម្រាបមកដល់អង្គសវនាការ ។ មិននិយាយទៅប្រាប់ដល់សាក្សីទេ គឺវិភាគអំពីចម្លើយឬក៏សម្តីរបស់សាក្សីហ្នឹងមកប្រាប់ដល់អង្គសវនាការ ។

**ជនជាប់ចោទ៖**

ខ្ញុំនិយាយនេះ គឺសំដៅអង្គសវនាការមែន តែគ្រាន់តែបែរមុខទៅខាងនោះ ។

សរុបមក ខ្ញុំនៅអត់ទាន់ជឿថា បទបញ្ជាខ្ញុំត្រូវមិត្តហ៊ី រំលោភ ល្មើសទេ បទបញ្ជាខ្ញុំ តាមខ្ញុំដឹងមួយប្រវត្តិមកដូចមិនទាន់មាននរណាល្មើសនឹងបទបញ្ជាខ្ញុំបាទទេ ។ ជនបស្ចិមប្រទេសមកម្តងពីរនាក់ពេលយកឯកសារទៅជូនពូនួន គឺ នួន ជា គាត់ថា “ហ៊ឺ! ពួកអាច្រមុះវែងល្មមយកចេញទៅ” ខ្ញុំថា

"បាទ" ។ "ហ៊ឺ! ដុតផងណ៎ា" ខ្ញុំថា "បាទ" ។ "ហើយកុំទុកឲ្យសល់ឆ្អឹងណ៎ា! យកកង់ឡានដុតឲ្យសុះឲ្យអស់ យើងមិនមែនយកឆ្អឹងទៅដូរយកប៊ុលដូស្សឺ ដូចពួកគុយបាទេ" ខ្ញុំថា "បាទ" ។ មកដល់ខ្ញុំចេញបញ្ជាឲ្យមិត្តហ៊ី ដូច្នេះ ម្ដងពីរ មិនមែនម្ដងតែមួយទេ ។ ហើយគោលបំណងដុតឲ្យសុះ មិនមែនដុតឲ្យនៅសល់សាកសពកណ្ដាលផ្លូវលេខ១៤៣ នោះទេ ។

[១១:៥៩:០៥]

ដូច្នេះ ខ្ញុំនៅតែជឿថាសក្ខីកម្មរបស់មិត្តហ៊ុយ ច្បាស់លាស់ជាង ហើយខ្ញុំនៅមិនទាន់ជឿថា មានអ្នកណាហ៊ានល្មើសនឹងបទបញ្ជាខ្ញុំ ។ នេះគឺសូមគោរពសូមរាយការណ៍ជូនប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណដល់សាក្សី ចៀម សឿ ដែលលោកបានអញ្ជើញមកផ្ដល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាមការកោះហៅរបស់អង្គជំនុំជម្រះ ។ ហើយការធ្វើសក្ខីកម្មរបស់លោកចំពោះសវនាការនេះឃើញថា ដល់ទីបញ្ចប់ហើយ ហើយអង្គជំនុំជម្រះក៏គិតនិងបានយល់ផងដែរ អំពីភាពលំបាករបស់លោកក្នុងការប្រឈមក្នុងការផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ដោយឆ្លើយតបទៅនឹងសំណួរពីភាគីជាច្រើនមានទាំងអង្គចៅក្រមនៃអង្គជំនុំជម្រះ ហើយនិងភាគីដទៃទៀតដែលពាក់ព័ន្ធ ។ ហើយហេតុផលមួយទៀត គឺដោយសាររឿងហេតុដែលបានកើតឡើងនេះ វារំលងជាងសាមសិបឆ្នាំមកហើយ ទើបយើងមកធ្វើសវនាការអង្គហេតុដែលកើតឡើងឃ្លាតឆ្ងាយយ៉ាងនេះ គឺជាការលំបាកមួយចំពោះមនុស្សជាតិទូទៅ គឺតែងតែមានការភ្លេចភ្លាំងនូវហេតុការណ៍នោះហើយ ឬក៏ភ្លេចភ្លាំងខ្លះ ។ ហើយបញ្ហាមួយទៀត ក៏អង្គហេតុ ឬក៏ព្រឹត្តិហេតុណាមួយដែលកើតឡើងនៅក្នុងសង្គមវាអាស្រ័យទៅលើទិដ្ឋភាព ឬស្ថានភាពនៃបុគ្គលដែរ បើមានបុគ្គលមានកម្រិតយល់ដឹងជ្រៅជ្រះ មានការពិចារណាជ្រៅ គឺក៏ងាយយល់ក្នុងការចង្អុលបង្ហាញដែរ ប៉ុន្តែបើមានការយល់ដឹងហ្នឹងគឺមានកម្រិតកាន់តែទាប ការលំបាកក្នុងការវាយតម្លៃ ឬក៏ក្នុងការចង្អុលបង្ហាញនូវហេតុការណ៍ដែលកើតមានឡើងក៏មានបញ្ហា ។ នេះក៏អង្គជំនុំជម្រះយល់ដែរ ។

អ៊ីចឹងសវនាការចំពោះលោក គឺចប់ហើយ ហើយមន្ត្រីតុលាការ ក្រោយពេលសម្រាកនេះ គឺលោកត្រូវរៀបចំជូនគាត់ សាក្សីទៅពាក់ព័ន្ធជាមួយនឹងអង្គភាពគាំពារ និងសាក្សី និងអ្នកជំនាញដើម្បីឲ្យអង្គភាពនោះរៀបចំជូនគាត់ត្រឡប់ទៅលំនៅដ្ឋានរបស់លោកវិញ ។

ហើយសវនាការល្ងាចនេះ គឺអង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគីនិងសាធារណជនថា អង្គជំនុំ

ជម្រះនឹងបន្តនូវដំណើរការសវនាការនៅរសៀលនេះចាប់ពីម៉ោងមួយ និងសាមសិបនាទីទៅ ដោយហេតុផលនៃកាលវិភាគនៃការគ្រោងទុកថ្ងៃនេះ យើងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះពេញមួយថ្ងៃ ។ ប៉ុន្តែ ឥឡូវនេះ ដោយសាររឿងហេតុដែលត្រូវបង្ហាញដោយសាក្សីរូបនេះមានតិច អ៊ីចឹងយើងបានចប់តាមមុនកាលវេលាដែលបានគ្រោងទុក ។

[១២:០២:១៤]

ដូច្នេះ នៅរសៀលនេះ អង្គជំនុំជម្រះនឹងរៀបចំនូវអ្វីដែលមានការសេសសល់ពីម្សិលមិញ គឺដំណើរការសវនាការអាននូវសក្ខីកម្មចំពោះសាក្សីចំនួនប្រាំរូប ដែលអង្គជំនុំជម្រះបានសម្រេចមិនយកគាត់មកធ្វើសក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ ដោយឲ្យក្រឡាបញ្ជីសវនាការអាននូវសក្ខីកម្មនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដែលយើងធ្វើបន្តពីការសេសសល់ពីម្សិលមិញ ហើយនិងមានបន្ថែមពីរនាក់ទៀត គឺបន្ថែមការអានកំណត់ហេតុឈ្មោះសាក្សី សោម សំអុល ហើយ ជ័យ សុភារ៉ា ។ នេះសូមជ្រាប ។

មន្ត្រីអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់សាលសវនាការនេះឲ្យបានមុខម៉ោងមួយសាមសិបនាទី ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១២:០៤ នាទី ដល់ម៉ោង ១៣:៣០នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាកិច្ចបន្តនេះ គឺចាត់ក្រឡាបញ្ជីលោក ឌុច ផារី ឡើងអាននូវកំណត់ហេតុស្តាប់ចម្លើយសាក្សី ញ៉េប ហូ ដែលឯកសារមានលេខ D22/10 ឯកសារជាភាសាខ្មែរ ERN00162681 ដល់ 00162692 ។

**លោក ឌុច ផារី៖**

“ការិយាល័យសហចៅក្រមស៊ើបអង្កេត ។ សំណុំរឿងព្រហ្មទណ្ឌលេខ ០០១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ។ លេខស៊ើបសួរ លេខ០០១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ។

ឆ្នាំពីរពាន់ប្រាំពីរ ខែតុលា ថ្ងៃទីដប់ប្រាំបួន នៅវេលាម៉ោងប្រាំបួន និងដប់នាទីព្រឹក នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

[១៣:៣៤:១៤]

យើង ងួន អ៊ឹម អក្សរកាត់ ង.អ, គ្រីស្ទៀន ប៊ូឌីសុន (Christian Baudesson) អក្សរកាត់ ស៊ី.ប៊ី ជាអ្នកស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ ដែលត្រូវបានចាត់ដោយដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ ។

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ។

បានឃើញវិធាន២៤ ២៨ និង ៦០ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ។

ដោយមានវត្តមានរបស់លោក តាន់ ប៉ាងដាវណ្ណ ជាអ្នកបកប្រែភាសារបស់អង្គជំនុំជម្រះវិសាមញ្ញ ដែលបានស្បថរួចហើយ ។

បានកត់ត្រាយកចម្លើយពីឈ្មោះ ញ៉ែប ហូ ជាសាក្សីដែលបានផ្តល់ព័ត៌មានស្តីពីអត្តសញ្ញាណដូចខាងក្រោម៖

ឈ្មោះ ញ៉ែប ហូ ឈ្មោះបដិវត្តន៍ ញ៉ែប សុវណ្ណ កើតឆ្នាំ១៩៥៣ ។

ជននេះបានប្រកាសថា ខ្លួនចេះអាន សរសេរ និងយល់ភាសាខ្មែរ ។

ជននេះបានប្រកាសថា ខ្លួនមិនចេះអាន និងសរសេរភាសាដទៃ ។

ហេតុដូច្នេះច្បាប់ដើមនៃកំណត់នៃហេតុនេះ ត្រូវបានសរសេរជាភាសាខ្មែរ ។

យើងបានជូនព័ត៌មានរួចហើយដល់ជននេះថា ការស្តាប់យកចម្លើយនេះនឹងត្រូវថតយកចម្លេង និងរូបភាព ។

ជននេះបានប្រាប់យើងពីទំនាក់ទំនងរបស់គេជាមួយនឹងជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណីថា មិនទាក់ទង ។

ជននេះបានស្បថស្របតាមបញ្ញត្តិនៃវិធាន២៤ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ។

យើងបានប្រាប់ដល់ជននេះអំពីសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ស្របតាមបញ្ញត្តិនៃវិធាន២៨ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ។

សួរ-ឆ្លើយ៖

ង.អ (ជាអក្សរកាត់របស់ឈ្មោះ ងួន អ៊ឹម)៖ ខ្ញុំចង់ឲ្យលោករៀបរាប់ពីប្រវត្តិរបស់លោកដោយ

សង្ខេបបន្តិចនៅឆ្នាំ១៩៧០?

ញ.ហ (ជាអក្សរកាត់របស់ឈ្មោះ ញ៉េប ហូ)៖ មុនឆ្នាំ១៩៧០ ខ្ញុំរៀននៅសាលាសំប៉ានក្រោម ហើយរៀនបានថ្នាក់ទី៨ ដោយឃើញឪពុកម្តាយត្រដាប់ត្រដួស ក៏ឈប់រៀន ។ ខ្ញុំជួយធ្វើការឪពុកម្តាយ រហូតដល់ឆ្នាំ១៩៧០ ។

ង.អ៖ ហើយក្រោយពីរដ្ឋប្រហារមក តើលោកធ្វើអ្វីទៀត?

ញ.ហ៖ កាលហ្នឹង ចូលរួមជាសហករណ៍រួមគ្នាជាក្រុមៗធ្វើចម្ការ ។

ង.អ៖ ក្រោយមកទៀត លោកធ្វើអ្វីដែរ?

ញ.ហ៖ ក្រោយមកទៀត ធ្វើរហូតដល់ឆ្នាំ៧៤ និងឆ្នាំ៧៥ គេបង្ខំឲ្យខ្ញុំធ្វើបដិវត្តន៍ ។ ប៉ុល ពត ហើយពួកគេល្លួបឃុំដេញព័ទ្ធខ្ញុំ ។ ខ្ញុំរត់គេចមកត្រើយខាងកើត ។ បន្តទៀត គេចាប់ខ្ញុំបានគេដាក់គុកខ្ញុំ នៅព្រែកតូច ។

ង.អ៖ គេដាក់គុកលោកប៉ុន្មានឆ្នាំ?

ញ.ហ៖ គេដាក់គុកខ្ញុំប្រាំខែ ។ រួចហើយបានប្អូនខ្ញុំ ដែលជាកងទ័ពរបស់តា ណាត មករំដោះខ្ញុំ ចេញពីគុក ហើយមកខ្ញុំនាំទៅភូមិព្រៃស្វាយកណ្តាលស្ទឹង ។

ង.អ៖ ប្អូនរបស់លោកចូលធ្វើទ័ពមុនលោក?

ញ.ហ៖ បាទ ។

ស៊ី.ប៊ី (ជាឈ្មោះអក្សរកាត់របស់ គ្រីស្មៀន ប៊ូឌីសុន)៖ ប្អូនលោក ឈ្មោះអ្វី?

ញ.ហ៖ ឈ្មោះ ញ៉េប ប៉េង ។

ង.អ៖ បន្ទាប់ពីចូលមកនៅជាមួយ ញ៉េប ប៉េង តើលោកនៅអង្គភាពអ្វី?

ញ.ហ៖ មុនដំបូង ខ្ញុំនៅខាងសេដ្ឋកិច្ច វរសេនាតូចលេខ១១២ វរសេនាធំ៧៣ កងពល១២ ។

ង.អ៖ សូមលោកបន្តទៀត ។

ញ.ហ៖ ខ្ញុំធ្វើការពីជំនាន់ ប៉ុល ពត នៅអង្គភាព១១២ ខាងសេដ្ឋកិច្ច ។

ង.អ៖ លោកបានផ្លាស់ប្តូរអង្គភាព ទៅណាផ្សេងទេ?

ញ.ហ៖ អត់មានទេ ។ នៅតែអង្គភាពសេដ្ឋកិច្ច១១២ ។

ង.អ៖ រហូតដល់ឆ្នាំទើបលោកមកបម្រើការងារនៅ ស-២១?

ញ.ហ៖ ដល់ឆ្នាំ១៩៧៧ ខែ៣, វន ជាអ្នកនាំខ្ញុំមកធ្វើការនៅ ស-២១ នេះ ។

ស៊ី.ប៊ី៖ តើ វន ហ្នឹង ជានរណា?

ញ.ហ៖ គាត់ជាប្រធានកងហា ខាងសេដ្ឋកិច្ច ។

ង.អ៖ វន គាត់ជាកងហានៅខាងសេដ្ឋកិច្ចនៅកន្លែងណា?

ញ.ហ៖ វន គាត់ជាប្រធានកងហា ខាងសេដ្ឋកិច្ច នៅវរសេនាតូច១១២ ។

ង.អ៖ ពេលគេហៅលោកមក ស-២១ តើគេប្រាប់លោកថា គេនាំមកកន្លែងហ្នឹងដែរឬទេ?

ញ.ហ៖ វន ហ្នឹង មុននាំខ្ញុំមក ខ្ញុំសួរ វន ថា មិត្តឯងនាំខ្ញុំទៅណា? វន ហ្នឹង ក៏និយាយថា មិត្តឯងចង់ដឹងម្ល៉េះ ពេលទៅដល់គង់តែដឹងទេ ។ ហើយ វន ហ្នឹង ក៏ឌុបកង់ខ្ញុំមក ។ ខ្ញុំចេះតែសួរគាត់តាមផ្លូវថា ជិតដល់ហើយឬនៅ? វន ថា ជិតដល់ហើយ ។ ដល់ពេលនេះ វន ហ្នឹង នាំខ្ញុំមក ស-២១ ហ្នឹង ហើយពួកអ្នកយាមក៏ស្ដោះទឹកមាត់ថា ពួកមិត្តឯងមក គឺជាប់គុកទៀតហើយ ។

[១៣:៤១:០៧]

ស៊ី.ប៊ី៖ អ្នកណាជាអ្នកនិយាយ?

ញ.ហ៖ អ្នកយាមការពារនៅស-២១ ។

ង.អ៖ តើលោកស្គាល់គ្នា ទើបអ្នកយាមហ្នឹង និយាយដូច្នេះ?

ញ.ហ៖ អត់ដែលស្គាល់ទេ ។

ស៊ី.ប៊ី៖ អ៊ីចឹងលោកចាំ វន នៅខាងក្រៅ?

ញ.ហ៖ ខ្ញុំចាំនៅខាងក្រៅ ។

ង.អ៖ លោកបន្តទៅទៀត ។

ញ.ហ៖ ក្រោយមក វន ចេញមក ហើយថាមិត្តឯងចូលទៅក្នុងទៅ ព្រោះខ្ញុំនិយាយជាមួយ ហ៊ី រួចហើយ ហើយខ្ញុំក៏ចូលទៅក្នុងទៅ ។

ង.អ៖ ពេលដំបូងគេប្រគល់ភារកិច្ចឲ្យលោកធ្វើអ្វី?

ញ.ហ៖ ខ្ញុំនៅខាងយាមការពារអ្នកទោស ។

ង.អ៖ យាមនៅខាងក្នុង ឬខាងក្រៅ?

ញ.ហ៖ យាមខាងក្នុងអគារខាងលើ ។

ង.អ៖ អ្នកយាមខាងក្នុង តើគេបែងចែកជាប៉ុន្មានក្រុម?

ញ.ហ៖ បែងចែកជាដប់ក្រុម ។

ង.អ៖ ហើយក្រុមរបស់លោកទទួលយាមអគារមួយណា?

ញ.ហ៖ ខ្ញុំ គេឲ្យដូរគ្នាប្រាំក្រុម យាមពីម៉ោងប្រាំមួយ ដល់ម៉ោងដប់មួយ ហើយបានប្រាំក្រុមទៀតយាមបន្តទៀតទល់ពេលល្ងាច ។

ស៊ី.ប៊ី៖ តើក្រុមរបស់លោកទទួលបន្ទុកយាមនៅកន្លែងណា? មិនមែនទាក់ទងនឹងពេលវេលាយាមម៉ោងប៉ុន្មានៗទេ ។

ញ.ហ៖ អគារខាងជើង មកខាងស្តាំដៃ អគារ “C” ។

ង.អ៖ ក្រុមនីមួយៗ គេឲ្យទទួលខុសត្រូវតាមអគារនីមួយៗ?

ញ.ហ៖ គេចែកដូចជា ដប់ក្រុម ។ ប្រាំក្រុមយាមមួយពេល ហើយប្រាំក្រុមទៀត ដូរមួយពេលទៅ គឺដូរគ្នារហូត ។

[១៣:៤៣:៣២]

ង.អ៖ លោកបញ្ជាក់ពីកិច្ចការរបស់អ្នកយាម តើធ្វើអ្វីខ្លះ?

ញ.ហ៖ អ្នកយាមហ្នឹង គឺថែរក្សាអ្នកទោស ការពារ ហើយនិងរែកបាយ និងអាចម៍យកទៅលាង ។

ង.អ៖ តើសិទ្ធិរបស់អ្នកយាម ចំពោះអ្នកទោស តើគេណែនាំយ៉ាងម្តេចខ្លះ?

ញ.ហ៖ ថ្នាក់លើណែនាំអត់ឲ្យមាត់ធំ មាត់តូច ដាក់អ្នកទោស ហើយក៏អត់ឲ្យវាយអ្នកទោសដែរ ហើយថ្នាក់លើណែនាំថា ពេលដល់ម៉ោងមិត្តឯងចុះទៅរែកបបរ ហើយនិងបាយយកមកឲ្យអ្នកទោសហូប ។

ស៊ី.ប៊ី៖ ប្រសិនបើអ្នកទោសចង់ចេញទៅបត់ជើង តើអ្នកណាជាអ្នកទទួលបន្ទុកលើកិច្ចការនេះ?

ញ.ហ៖ គេអត់ឲ្យទទួលទេ ដូចយើងយាមអគារជាន់ទីមួយហ្នឹង ។ គេមានប្រដាប់គេ មួយទុកឲ្យអ្នកទោសបត់ជើងនៅនឹងតែម្តង ។

ង.អ៖ សូមលោកបញ្ជាក់ឲ្យច្បាស់ ពីការអ្នកទោសត្រូវការបត់ជើងបត់ដៃ តើលោកឲ្យអ្វីដើម្បីបត់ជើងបត់ដៃ?

[១៣:៤៥:០៧]

ញ.ហ៖ អាកែសគ្រាប់ហ្នឹង គេទុកសម្រាប់ឲ្យអ្នកទោសបត់ជើងបត់ដៃ ។

ង.អ៖ ចុះចំពោះអ្នកទោសដែលជាប់ខ្នោះ តើគេបត់ជើងយ៉ាងដូចម្តេច? សូមលោកបញ្ជាក់ ។

ញ.ហ៖ អ្នកទោសគេបត់ជើង គឺនៅក្នុងហ្វឹង គេអត់មានដាក់ខ្នោះទេ ។ គេយកែសគ្រាប់ឱ្យអ្នកទោសបត់ជើងធំ ហើយអ្នកទោសបត់ជើងហើយ ក៏យើងអ្នកយាមបិទអាកែសគ្រាប់ហ្វឹង យួរចេញមកក្រៅវិញ ។

ស៊ី.ប៊ី៖ លោកមានប្រសាសន៍ថា អ្នកទោសអត់មានដាក់ខ្នោះទេ តើអ្នកទោសមានសិទ្ធិដើរដោយសេរី?

ញ.ហ៖ កន្លែងខ្ញុំយាម កន្លែងជាន់លើហ្វឹង អ្នកទោសអត់មានដាក់ខ្នោះដៃទេ ។

ង.អ៖ លោកយាមនៅតែកន្លែងជាន់ខាងលើហ្វឹងមួយទេ?

ញ.ហ៖ ខ្ញុំចូលយាមតែជាន់លើហ្វឹងរហូតមក អាកន្លែងជាន់ផ្ទាល់ដី និងទីពីរ អាហ្វឹងគេផ្សេងទៀត ។

ង.អ៖ នៅជាន់ខាងលើហ្វឹង តើអ្នកទោសជាបន្ទប់ធំ ឬក៏បន្ទប់តូច?

ញ.ហ៖ ខាងលើជាបន្ទប់ធំ ។

ង.អ៖ តើអ្នកទោសទាំងអស់ហ្វឹងអត់មានដាក់ខ្នោះអ្វីទាំងអស់?

ញ.ហ៖ អត់មានទេ មានតែជាន់ផ្ទាល់ដី និងទីមួយ អាខាងលើហ្វឹង គេសួរចម្លើយហើយ អត់ហើយទើបគេដាក់ទៅខាងលើ ។ ខ្ញុំសូមបញ្ជាក់ជាន់ផ្ទាល់ដីទីមួយ រួចជាក់ទីពីរ ហើយខ្ញុំនៅជាន់ទីបី ។

ស៊ី.ប៊ី៖ ដូច្នេះអ្នកទោស ដែលមិនទាន់បានសួរចម្លើយ គេដាក់នៅជាន់ផ្ទាល់ដី?

ញ.ហ៖ ដាក់នៅជាន់ទីមួយ បន្ទាប់ពីផ្ទាល់ដី ។

ង.អ៖ សូមលោកបញ្ជាក់ តើបន្ទប់អ្នកទោស ដែលលោកយាមហ្វឹង មានប្រុស មានស្រី កូនក្មេងអី ចម្រុះគ្នា ឬយ៉ាងម៉េច?

ញ.ហ៖ បន្ទប់កន្លែងខ្ញុំយាមហ្វឹង មួយបន្ទប់សម្រាប់មនុស្សស្រី និងកូនក្មេង និងបន្ទប់ផ្សេងទៀតសម្រាប់មនុស្សប្រុស ។ កន្លែងហ្វឹងសម្រាប់អ្នកទោសសួររួចហើយ ។ កន្លែងអគារនោះមានបីបន្ទប់ធំៗ ។

[១៣:៤៨:០៨]

ង.អ៖ សូមលោកបញ្ជាក់ពីបន្ទប់ ដែលមានស្រី និងកូនក្មេង ។ តើក្មេងមានច្រើនទេ?

ញ.ហ៖ បន្ទប់ដែលមានម៉ែ ហើយនិងកូនមានប្រហែលជាប្រាំពីរនាក់ ហើយក្រៅពីហ្វឹងមាននារីខ្លះ ហើយនិងមនុស្សចាស់ខ្លះទៅ ។

ង.អ៖ តើលោកបានដឹងទេ ក្រោយមកម្ដាយនិងកូនក្មេងហ្នឹង គេយកទៅណា?

ញ.ហ៖ ម្ដាយ និងកូនក្មេង ក្រោយមកក្រុម ហ៊ុយ មកយក តែម៉ោងប្រាំពីរហ្នឹង គេយកឡានមកយកហើយ ។ គេមិនមែនមកយកទាំងអស់ទេ គេយកតាមបន្ទប់ផ្សេងៗទៀត ។

ង.អ៖ ម៉ោងប្រាំពីរយប់ ឬព្រឹក?

ញ.ហ៖ ម៉ោងប្រាំពីរយប់ ក្រុម ហ៊ុយ មកយក ។

ង.អ៖ តាមលោកដឹងយកទៅខាងណាវិញ?

ញ.ហ៖ រឿងច្បាប់គេ គេថាយក ហ៊ុយ មកយក ។ គេឡើងមកខ្លួនឯង ក្រុមគេហ្នឹង ។ យើងមិនសួរគេបានទេ តែកាលណាយើងសួរគេ ថាយើងខ្លាំងបដិវត្តន៍ហើយ ។

ង.អ៖ ពេលដែលក្រុម ហ៊ុយ មកយកអ្នកទោសហ្នឹង តើគេមានទាក់ទងជាមួយអ្នកយាមយ៉ាងដូចម្ដេចខ្លះ?

ញ.ហ៖ ហ៊ុយ ចូលមក ដែលខ្ញុំមើលពីលើអគារមក គេច្រើនតែទាក់ទងជាមួយ ហ៊ា ហើយ ធី ជាអ្នកកាន់ក្បាលបញ្ជី ។ បន្ទាប់ពី ឌុច មក មានតែ ហ៊ា ទេ ។

ង.អ៖ ចុះលោកជាអ្នកយាម ក្រែងសោបន្ទប់អ្វីនៅលើលោកទាំងអស់?

ញ.ហ៖ ដូចខ្ញុំអ្នកយាមហ្នឹង ខ្ញុំមានគ្នាបីនាក់នៅជាន់លើហ្នឹង ។ សោ កាលណាទៅរែកបបរ ខ្ញុំឱ្យពួកអ្នកយាមពីរនាក់ទៀតជាអ្នកកាន់ហើយ ដូចគ្នា ។

ង.អ៖ ដូច្នេះសិទ្ធិលោកទាក់ទងជាមួយក្រុមអ្នកយាម អ្នកទោសទៅក្រៅហ្នឹង លោកមានសិទ្ធិត្រឹមតែចាក់សោឱ្យទេ?

ញ.ហ៖ បានត្រឹមតែចាក់សោឱ្យគេទេ ។

[១៣:៥០:៥៨]

ង.អ៖ ក្នុងតួនាទីជាអ្នកយាមអ្នកទោស តើលោកសង្កេតឃើញសភាពអ្នកទោសយ៉ាងម្ដេចខ្លះ?

ញ.ហ៖ ដែលខ្ញុំយាមអ្នកទោសនៅជាន់លើហ្នឹង គឺសភាពអ្នកទោសទ្រុឌទ្រោមមកពីការធ្វើទារុណកម្ម វាយដំ ហើយខ្ញុំឃើញហ្នឹង អ្នកទោសមួយនោះហៅថា បង ជួយលាបខ្នងឱ្យខ្ញុំបន្តិច ឈឺណាស់ ហើយខ្ញុំក៏ហៅពេទ្យមកលាងរបួសឱ្យទៅ ។

ង.អ៖ មានករណីអ្វីផ្សេងទៀតទេ ដែលលោកបានឃើញ?

ញ.ហ៖ ដែលខ្ញុំធ្លាប់យាមនៅហ្នឹង ដូចមិនមានអ្វីច្រើនទេ ឃើញថាគេសួរចប់ចម្លើយអស់ហើយ

គេទុកនៅកន្លែងហ្នឹង ។ ប៉ុន្តែ អ្នកទោសស្គមស្គាំងច្រើនហើយដែរ មកពីការធ្វើទារុណកម្មខ្លាំង ។

ង.អ៖ លោកសម្គាល់ឃើញយ៉ាងណាថា អ្នកទោសត្រូវទទួលរងទារុណកម្មខ្លាំងក្លា?

ញ.ហ៖ អ្នកទោសហ្នឹង គេយកឡើងទៅលើ គេសួរចម្លើយចប់ហើយ អ្នកទោសអត់ដែលប្រាប់ខ្ញុំទេ មានអ្នកទោសខ្លះប្រាប់ខ្ញុំថា បងអើយ គេវាយខ្ញុំខ្លាំងដល់ហើយ តែខ្ញុំក៏មិនហ៊ានថាអ្វីដែរ ព្រោះខ្លាចពេលគេយកអ្នកទោសហ្នឹងទៅសួរម្តងទៅ ខ្លាចគេធ្វើដាក់ខ្ញុំ ។

ស៊ី.ប៊ី៖ លោកបញ្ជាក់ថា នៅជាន់ខាងលើមានបន្ទប់ដាក់កូនក្មេងនិងមនុស្សស្រី ។ តើលោកធ្លាប់ឃើញគេសម្លាប់កូនក្មេងក្នុងបន្ទប់ហ្នឹងដែរឬទេ?

ញ.ហ៖ នេះបើខ្ញុំនិយាយ ដែលខ្ញុំធ្លាប់យាម គឺគ្មាន ។ កាលណាបើសិនពួក ហ៊ុយ ធ្វើដូច្នេះ វាត្រូវប្រតិកម្មដល់អ្នកទោសនៅក្នុងគុកហ្នឹងហើយ ។

ង.អ៖ សូមលោកបញ្ជាក់ថែមទៀត តើអ្នកទោសកន្លែងលោកយាមហ្នឹង មានដែលស្រែកយំអ្វីដែរទេ?

អ.ហ៖ អ្នកទោសហ្នឹងមានថ្ងូរដែរ មិនមែនអត់ទេ ។ ប៉ុន្តែ ពេលឮសូរថ្ងូរហ្នឹង ខ្ញុំទៅហៅពេទ្យព្រោះខ្លាចអ្នកទោសសម្លាប់នៅហ្នឹង គេចោទខ្ញុំថាខ្លាំង ។

ង.អ៖ តើលោកមានដែលជួបប្រទះអ្នកទោសសម្លាប់នៅពេលហ្នឹងទេ?

ញ.ហ៖ ខ្ញុំបានជួបដែរ អ្នកសួរមកយកអ្នកទោសពីអគារជាន់លើ ពេលអ្នកសួរប្រលែងដៃអ្នកទោស អ្នកទោសនោះលោតពីលើអគារសម្លាប់ ។ អាហ្នឹងខ្ញុំឃើញផ្ទាល់ភ្នែក ។

ស៊ី.ប៊ី៖ តើលោកជាអ្នកនាំអ្នកទោសចេញពីកន្លែងឃុំឃាំងទៅសួរចម្លើយ? ឬក៏មានក្រុមគេផ្សេង?

[១៣:៥៤:២៦]

ញ.ហ៖ ខ្ញុំគ្រាន់តែជាអ្នកចាក់សោ ហើយអ្នកសួរនោះគេស្គាល់មុខ គេយកអ្នកទោសនោះទៅតែម្តង ហើយពេលទៅនោះគ្រាន់តែអ្នកសួរ គេប្រលែងដៃបន្តិច ក៏អ្នកទោសលោតពីលើអគារ ។

ស៊ី.ប៊ី៖ ដូច្នេះ អ្នកសួរចម្លើយមកយកអ្នកទោសដោយផ្ទាល់ តើលោកអាចឲ្យឈ្មោះអ្នកដែលសួរចម្លើយទាំងនោះ ដែលមកយកអ្នកទោសបានទេ?

ញ.ហ៖ ខ្ញុំមិនអាចចាំឈ្មោះទេ ព្រោះខ្ញុំមិនហ៊ានសួរគេទេ ហើយអ្នកដែលមកនោះ គឺសុទ្ធតែពួកខាង ឌុច ទាំងអស់ ។

ស៊ី.ប៊ី៖ ទាក់ទងនឹង ឌុច តើលោកធ្លាប់មកមើលកន្លែងឃុំឃាំងញឹកញាប់ទេ?

ញ.ហះ ខ្ញុំយាមនឹង ឌុច ហ្នឹងមកញឹក តែមកជួបតែ ហ៊ា ទេ អត់បានមកតាមអគារទេ ។

ស៊ី.ប៊ីះ លោកមានប្រសាសន៍ថា ឌុច មកពិនិត្យគុកមកជួបត្រឹមតែ ហ៊ា ទេ ហើយ ហ៊ា ជាប្រធានរបស់លោក ។ បើតាមយោបល់របស់លោក តើ ឌុច ជាអ្នកណា?

ញ.ហះ ខ្ញុំនៅស-២១ គឺមានតែ ឌុច ហើយនិង ហ៊ា ទេ គឺ ឌុច ហ្នឹងប្រធានធំ ហើយ ហ៊ា ហ្នឹងអនុ ហើយនិងសមាជិក គឺ ហ៊ុយ នៅព្រៃស ។ ហ៊ុយ គឺខ្មៅ ហើយនិងខ្ពស់ ។

ស៊ី.ប៊ីះ លោកមានប្រសាសន៍ថា លោកស្គាល់ ឌុច, ហ៊ា និង ហ៊ុយ ក្រៅពីនេះទៀត តើលោកមានស្គាល់អ្នកណាផ្សេងទៀតទេ? ដូចជាប្រធានអ្នកយាមនៅខាងក្រៅ ។

ញ.ហះ ដែលនៅក្នុងស-២១ ហ្នឹងខ្ញុំមិនសូវចាំឈ្មោះអស់ទេ ។ ប៉ុន្តែ ខ្ញុំស្គាល់ឈ្មោះខ្លះ ដែលនៅខាងក្នុងដូចជា ប៉ូច នៅកងរយស-២១, ថៃ ប្រធានកងរយស-២១, ផូ ប្រធានកងរយស-២១ ហើយប្រធានកងហាមាន ស្រេង, អេង ហើយនិងស្រ៊ី ហើយប្រធានកងហាបីនាក់ទៀត ខ្ញុំភ្លេចអស់ហើយ ។ ប្រធានកងហាទាំងអស់មានប្រាំមួយនាក់ ដែលនៅខាងក្រៅមាន ហ៊ុយ, ម៉ាន, ស្រ៊ម និងខាងចាប់ចងចេញចូលនៅលើក្រុមហ្នឹងទាំងអស់ ។ ក្រុមនោះនៅកន្លែងលូទឹកស្អុយមកខាងលិច ហើយអ្នកសួរខ្ញុំ មិនសូវស្គាល់ ។

ង.អះ ក្នុងចំណោមឈ្មោះទាំងហ្នឹង លើកលែងតែ ហ៊ុយ ក្រៅពីហ្នឹងនៅរស់ដែរទេ?

ញ.ហះ អ្នកដែលមានឈ្មោះទាំងអស់ហ្នឹង សុទ្ធតែឈ្មោះខ្មោចទាំងអស់ លើកលែងតែ ហ៊ុយ ។

ស៊ី.ប៊ីះ តើលោកមានបងប្អូននៅធ្វើការនៅស-២១ ដែរទេ?

ញ.ហះ នៅក្នុងគុក ស-២១ ខ្ញុំមានប្អូនប្រុសនៅធ្វើការនៅក្នុងគុកហ្នឹងដែរ ឈ្មោះ ប៉េង ។

[១៣:៥៨:១៣]

ស៊ី.ប៊ីះ ប៉េង ធ្វើអ្វីដែរ?

ញ.ហះ ពេល ហ៊ុយ ចាប់អស់ទៅ ទើបប្អូនខ្ញុំឡើងប្រធានកងរយនៅជាមួយ ធី ។

ង.អះ នៅរស់ទេ ប៉េង ?

ញ.ហះ ស្លាប់ហើយ ។ ប៉េង ស្លាប់នៅបរប៉ៃលិននៅជាមួយ ឌុច ។ មានគេមកប្រាប់ថា ស្លាប់ហើយពេលធ្វើសង្គ្រាមក្រោយឆ្នាំ៧៩ ។

ង.អះ ស្លាប់ឆ្នាំណា?

ញ.ហះ ខ្ញុំមិនបានចាំទេ ។

ស៊ី.ប៊ី៖ តើលោកស្គាល់ឈ្មោះ ចាន់ ទេ?

ញ.ហ៖ ចាន់ ខ្ញុំប្រហាក់ប្រហែលដែរ បើអ្នកសួរទើបស្គាល់ ចាន់ តែម្តង ។

ង.អ៖ លោកធ្វើការនៅទីនោះ ធ្លាប់ចូលប្រជុំ ឬរៀនសូត្រនយោបាយពី ឌុច ទេ?

ញ.ហ៖ កាលខ្ញុំនៅស-២១ គឺធ្លាប់ទៅរៀន ទៅដោយសារគេផ្លាស់វេនយាម ។ ឌុច ហៅអ្នកយាមហ្នឹងទៅ ទៅសាលាគេទើបធ្វើហើយនៅជិតផ្ទះ ឌុច ហើយ ឌុច ណែនាំពីរឿងថា អ្នកយាមធ្វើម៉េចយ៉ាង យាមឲ្យជាប់ អ្នកណាឲ្យអ្នកទោសរត់រួច អ្នកនោះគឺស្លាប់ ហើយ ឌុច និយាយថា ឲ្យជឿជាក់លើបដិវត្តន៍កុំធ្វេសប្រហែសរឿងយាមកាមហ្នឹង ។ ឌុច និយាយផង ចង្អុលដៃផង និយាយច្រើន តែខ្ញុំមិនបានចាំ ។

ង.អ៖ លោកបានរៀនសូត្រប៉ុន្មានដងដែរ?

ញ.ហ៖ ខ្ញុំនៅក្នុងស-២១ បានប្រជុំតែម្តង ទៅប្រជុំនៅសាលាក្បែរផ្ទះ ឌុច ។

ង.អ៖ មានធ្លាប់ចូលរួមប្រជុំជាមួយអ្នកផ្សេងក្រៅពី ឌុច ទេ?

ញ.ហ៖ ខ្ញុំនៅស-២១ មិនដែលទេ ។ រឿងអ្នកធំមានតែពួក ហ៊ុយ និង ធី ទើបដឹងបាន ហើយពួកកងរយ កងហា តែស្លាប់ទើបដឹងបាន ។

ង.អ៖ សូមលោកបញ្ជាក់បន្តិចចំពោះឈ្មោះខាងលើ ដែលលោកមានប្រសាសន៍ លោកថា អ្នកទាំងអស់ហ្នឹងគេចាប់អស់ហើយ តើលោកមានដែលបានយាមអ្នកទាំងអស់នោះទេ?

ញ.ហ៖ ពួកដែល ហ៊ុយ ចាប់គេមិនដែលយកមកដាក់នៅអគារខាងជើងទេ ។ គេយកទៅដាក់អគារខាងត្បូង ។ ចាប់តាំងពីប្រធានក្រុមយុវជនស-២១ គេមិនដែលដាក់នៅខាងជើងទេ គេដាក់នៅអគារខាងត្បូងទាំងអស់ ។

[១៤:០១:២៨]

ង.អ៖ តើអ្នកណាជាអ្នកគ្រប់គ្រងនៅអគារខាងត្បូង?

ញ.ហ៖ ខ្ញុំមិនស្គាល់ឈ្មោះគេទេ ព្រោះអ្នកយាមទាំងអស់ រូបខ្ញុំក៏ដោយ តែយាមអគារណា គឺដឹងតែអគារមួយហ្នឹងទេ អាហ្នឹងច្បាប់របស់ ឌុច ។

ង.អ៖ តើការគ្រប់គ្រងខាងក្នុងហ្នឹង អ្នកយាមដូចគ្នាក៏មិនអាចទាក់ទងគ្នាបានដែរ?

ញ.ហ៖ អ្នកយាមទាំងអស់ គឺ ឌុច អត់ឲ្យទាក់ទងគ្នាទេ ព្រោះអ្នកយាមដែលនៅសេសសល់ គឺខ្សែខាង តាណាត ទាំងអស់ ។ ដូច្នេះ គេកម្រិតអត់ឲ្យទាក់ទងទេ កាលណាទាក់ទងគ្នា គឺអ្នកនោះខ្លាំង

តាមដានដឹង គឺយកដាក់គុកហើយ ។

ស៊ី.ប៊ី៖ អ្នកដែលធ្វើការនៅស-២១ ហ្នឹងមានការយកទៅសម្លាប់ច្រើន តើការសម្លាប់នោះដោយសារមូលហេតុអ្វី ដោយសារតែនៅខាង តាណាត ឬយ៉ាងណា?

ញ.ហ៖ នៅក្នុង ស-២១ អ្នកនៅខាងកងរយហ្នឹងជាខ្សែ តាណាត ហ្នឹងទាំងអស់ ហើយ ឌុច យកកម្លាំងរបស់ខ្លួនមកបន្ថែម ។ ដូច្នេះ ឌុច ហាមមិនឲ្យទាក់ទងជាមួយខ្សែ តាណាត ទេ ។

ង.អ៖ សូមលោកបញ្ជាក់បន្ថែម តើការចាប់ចង-- តើការចាប់កងរយនៅស-២១ ក្តីលោកសម្គាល់ឃើញ តើគេចាប់របៀបយ៉ាងម្តេច?

[១៤:០៣:១៥]

ញ.ហ៖ ខ្ញុំមិនបានដឹងថាចាប់ មិនចាប់ទេ ខ្ញុំគ្រាន់តែយាមនៅលើហ្នឹង ឈរមើលទៅឲ្យតែអ្នកកងរយប្រធានក្រុមអី តែគេហៅទៅកន្លែង ហ៊ុយ ទៅលូទឹកស្អុយ គឺចាប់ហើយ ពេលមកវិញតែហ៊ុមក្រមាមុខអី គឺដឹងតែជាប់ហើយ ។

ស៊ី.ប៊ី៖ តើ ហ៊ុយ មួយណា?

ញ.ហ៖ យូ ហ៊ុយ ហៅ ហ៊ឹម ហ៊ុយ ។

ង.អ៖ តើអ្នកណាជាអ្នកបញ្ជាឲ្យទៅជាមួយ ហ៊ុយ?

ញ.ហ៖ អ្នកណាដែលសម្រេចខ្ញុំមិនដឹងទេ ។

ស៊ី.ប៊ី៖ ក្នុងចំណោមអ្នកទោសទាំងអស់នៅស-២១ តើលោកធ្លាប់ឃើញអ្នកទោសបរទេសទេ?

ញ.ហ៖ កន្លែងខ្ញុំអត់មាន បើសិនកន្លែងគេ ខ្ញុំសង្ស័យថាមាន ព្រោះគេនៅអគារផ្សេង ។

ង.អ៖ ទាក់ទងខាងការឲ្យបាយអ្នកទោស តើក្នុងមួយថ្ងៃឲ្យអ្នកទោសប៉ុន្មានពេល? ហើយក្នុងមួយពេលមានរបបអ្វីខ្លះ?

ញ.ហ៖ កន្លែងដែលខ្ញុំយាមហ្នឹង គឺបីអម្រែក ដាក់ក្នុងធានកន្ទន់ធំៗ ហើយសម្លតែមួយអម្រែកទេ ហើយបានខ្ញុំយកកន្ទន់បាយដាក់តាមបន្ទប់មួយៗទុកឲ្យអ្នកទោសដួសយកដោយខ្លួនឯង រួចហើយនៅសល់ខ្ញុំទុកនៅក្រៅបន្ទប់ បើមានការខ្វះខាត ទើបខ្ញុំថែមតាមក្រោយ ។ ក្នុងមួយថ្ងៃ ខ្ញុំរៀបចំបាយឲ្យអ្នកទោសតែពីរពេលទេ ពេលថ្ងៃត្រង់និងពេលល្ងាច ។

ស៊ី.ប៊ី៖ សម្រាប់អ្នកទោសប៉ុន្មាននាក់?

ញ.ហ៖ កន្លែងខ្ញុំយាមមានអ្នកទោសប្រហែល៨០នាក់ ។

ស៊ី.ប៊ី៖ ទាក់ទងនឹងការបែងចែកម្ហូប តើអ្នកទោសមានចានរៀងខ្លួន ឬដាក់ចានធំរួម?

ញ.ហ៖ ចានបាយសម្រាប់អ្នកទោសមានគ្រប់គ្នា តែខ្ញុំរៀបចំសម្ល តែបីចានទេ សម្រាប់គ្នាម្ភៃនាក់ ។

ស៊ី.ប៊ី៖ តើលោកគិតថាគ្រប់គ្រាន់ដែរទេ?

ញ.ហ៖ ខ្លះក៏មិនគ្រប់ដែរ បើនិយាយពីបាយ ក៏វាខ្វះតែខ្វះមិនច្រើនទេ តែបើសម្លវាខ្វះច្រើន ។

ស៊ី.ប៊ី៖ និយាយរួមការហូបចុកនោះមិនគ្រប់គ្រាន់ទេ សម្រាប់អ្នកទោស?

ញ.ហ៖ ខ្ញុំថាគ្រប់ខ្លះ មិនគ្រប់ខ្លះ ព្រោះរបបគេតែប៉ុណ្ណឹង ។

[១៤:០៦:៤១]

ង.អ៖ ចំពោះអ្នកទោសផ្សេងទៀតក្រៅពីកន្លែងលោក តើរបបដូចគ្នាដែរ?

ញ.ហ៖ មានរបបដូចគ្នាទូទៅ ព្រោះចុងភៅ គេដួសបបរឲ្យយើងដូចគ្នា ។

ផ្អាកការស្តាប់ចម្លើយសាក្សីនៅម៉ោងដប់មួយ និងហាសិបនាទីព្រឹក ថ្ងៃខែឆ្នាំដដែល ។

ចាប់ផ្តើមការស្តាប់ចម្លើយសាក្សីនៅម៉ោងមួយ និងម្ភៃនាទីថ្ងៃត្រង់ ថ្ងៃខែឆ្នាំដដែល ។

ង.អ៖ ចុះចំពោះរបបហូបចុករបស់យុទ្ធជន ស-២១ វិញយ៉ាងម៉េចដែរ?

ញ.ហ៖ របបហូបចុករបស់យុទ្ធជនស-២១ ខាងសេដ្ឋកិច្ចគេរៀបចំឲ្យក្នុងមួយតុមានគ្នាដប់នាក់។

ង.អ៖ ក្នុងមួយថ្ងៃប៉ុន្មានពេល ហើយគ្រប់គ្រាន់ដែរឬទេ?

ញ.ហ៖ ក្នុងរបបហូបចុក ខាងកងការពារ ចួនកាលក៏ខ្វះ ចួនកាលក៏គ្រប់ទៅ ព្រោះស្ថិតនៅលើខាងកងសេដ្ឋកិច្ច ស-២១ របស់គេ ។

ង.អ៖ ពាក្យថាគ្រប់គ្រាន់តើបានប៉ុន្មានពេល?

ញ.ហ៖ ក្នុងរបបហូបចុកហ្នឹង គឺពីរពេលដូចគ្នា ថ្ងៃត្រង់ ហើយនិងពេលល្ងាច ។

ង.អ៖ តើលោកហូបចុករបៀបម៉េច? លោកអាចថែមថយបានដោយខ្លួនឯង?

ញ.ហ៖ មានតែមួយឆ្នាំងទេ ។

ង.អ៖ ហើយម្ហូបមានប៉ុន្មានមុខដែរ?

ញ.ហ៖ មានមួយមុខ ចួនកាលមានពីរមុខដែរ ។

ង.អ៖ បើប្រៀបធៀបជាមួយនឹងរបបអ្នកទោសដែលលោកបញ្ជាក់ព្រឹកមិញ តើមានភាពខុសគ្នាយ៉ាងដូចម្តេចដែរ?

ញ.ហ៖ របបអ្នកទោស ហើយនិងកងការពារ គ្រាន់តែខុសគ្នាបន្តិចៗទេ ។ របបអ្នកការពារ ចួន កាលបាយមិនឆ្អែត តែបានសម្លមួយមុខទៅហូបបានឆ្អែត ។

ង.អ៖ លោកថាអ្នកទោសភាគច្រើនស្គម ដោយសារហូបចុកមិនគ្រប់គ្រាន់?

ញ.ហ៖ អ្នកទោសហូបមិនសូវគ្រប់គ្រាន់ផង ហើយគេធ្វើទារុណកម្មផង ដូច្នេះអ្នកទោសស្គម។

ង.អ៖ តែអ្នកធ្វើការនៅស-២១ មិនស្គមដូចអ្នកទោសទេ?

ញ.ហ៖ អ្នកនៅស-២១ មិនសូវស្គមមកពីមិនមានអ្នកណាធ្វើទារុណកម្ម ។

[១៤:០៩:៥0]

ង.អ៖ ដូច្នេះ ការកត់សម្គាល់របស់លោក អ្នកទោសត្រូវតែទទួលរងទារុណកម្ម ឬយ៉ាងម៉េច?

ញ.ហ៖ ខ្ញុំសង្កេតមើលទៅ គឺថា ទារុណកម្មលើអ្នកទោសហ្នឹង គឺថាមួយរយភាគរយ។

ង.អ៖ លោកអាចបញ្ជាក់ពីការធ្វើទារុណកម្មលើអ្នកទោសថាតើមានអ្វីខ្លះ?

ញ.ហ៖ រឿងគេធ្វើទារុណកម្ម ខ្ញុំមិនបានដឹង ព្រោះខ្ញុំនៅឆ្ងាយពីគ្នា តែគ្រាន់ថា ខ្ញុំយាមនៅក្នុង គុកហ្នឹង គឺថា ពេលអ្នកទោសត្រលប់មកវិញ គឺមានស្នាមរំពាត់ ។

ង.អ៖ តើការរស់នៅរបស់អ្នកទោសតាមលោកសង្កេតឃើញ តើអ្នកទោសមានសម្លៀកបំពាក់ គ្រប់ៗគ្រាន់ដែរទេ?

ញ.ហ៖ អ្នកទោសដែលខ្ញុំយាម គឺចួនកាលគ្រប់គ្រាន់ ចួនកាលក៏មិនគ្រប់គ្រាន់ដែរ ។

ង.អ៖ លោកសម្គាល់ឃើញយ៉ាងណាចំពោះអ្នកទោសដែលមិនមានសម្លៀកបំពាក់គ្រប់គ្រាន់?

ញ.ហ៖ អ្នកទោសដែលខ្វះសម្លៀកបំពាក់មិនគ្រប់គ្រាន់ ដោយសារតែការធ្វើទារុណកម្ម វាយ ទៅរយះអាវក៏មាន ហើយអ្នកទោសក៏គ្មានអាវសម្រាប់ប្តូរដែរ ។

ង.អ៖ សរុបមកវិញ ឃើញថាអ្នកទោសខ្លះក៏អត់មានអាវពាក់ដែរ?

ញ.ហ៖ បាទ, ខ្ញុំសង្កេតនៅក្នុងយាមហ្នឹង គឺខ្លះដែលគេធ្វើទារុណកម្មខ្លាំង រហូតដល់រយះអាវ ខ្លះរយះអាវខ្លាំងក៏ដោះអាវហ្នឹងចោលក៏មាន ។

ង.អ៖ លោកដែលឃើញមានពេទ្យទៅព្យាបាលអ្នកទោសផ្ទាល់នៅនឹងកន្លែងលោកដែរឬទេ?

ញ.ហ៖ មានពេទ្យពីរនាក់ទៅព្យាបាលនៅក្នុងគុកកន្លែងខ្ញុំយាមនោះ ។

ង.អ៖ អំពីការធ្វើអនាម័យរបស់អ្នកទោស ពីការងូតទឹកសម្អាតខ្លួនអ្នកទោស តើយ៉ាងដូចម្តេច ដែរ?

ញ.ហ៖ ដែលខ្ញុំយាមអ្នកទោសនោះ គេមានម៉ូទ័រ គេក្រោម ហើយនិងទុយោ គេតទៅលើ សម្រាប់ងូតទឹកឲ្យអ្នកទោស គេមានសាប៊ូ មានអីគេត្រឹមត្រូវ ។

ង.អ៖ សូមលោកបញ្ជាក់ឲ្យបានច្បាស់ពីការងូតទឹកអ្នកទោសបន្តិច?

ញ.ហ៖ ខ្ញុំឲ្យអ្នកទោសនៅក្នុងបន្ទប់ហ្នឹង ងូតទឹកម្នាក់ម្តងៗ ហើយមានសាប៊ូមួយថង់ ពេលងូតរួចហើយ ទើបខ្ញុំយកទៅឲ្យអ្នកទោសបន្ទប់ផ្សេងងូតទៀត ។

ង.អ៖ លោកបាញ់ទុយោងូតទឹកឲ្យអ្នកទោស ឬអ្នកទោសងូតដោយខ្លួនឯង?

[១៤:១៣:១១]

ញ.ហ៖ ខ្ញុំរុញឲ្យគេងូតម្នាក់ម្តងៗ ។ ពេលងូតហើយទើបខ្ញុំដកទុយោទៅបន្ទប់ផ្សេងទៀត ។

ង.អ៖ ដូច្នេះជាកន្លែងដេកផង ហើយជាកន្លែងងូតទឹកផង?

ញ.ហ៖ កន្លែងងូតទឹកផង ដេកហ្នឹងផង ។ ពេលងូតទឹកហើយ ជូតឲ្យស្ងួតរួចហើយសម្រាកនៅហ្នឹងដែរទៅ ។

ង.អ៖ ងូតទឹកឲ្យអ្នកទោសប៉ុន្មានដងក្នុងមួយសប្តាហ៍?

ញ.ហ៖ អ្នកទោសដែលងូតទឹក គឺមួយថ្ងៃពីរដង ថ្ងៃត្រង់ និងល្ងាច ។

ង.អ៖ ចុះអ្នកទោសផ្សេងទៀតក្រៅពីអគាររបស់លោក តើអ្នកទោសនោះងូតទឹកដូចម្តេចដែរ ដូចគ្នាដែរទេ?

ញ.ហ៖ អគាផ្សេងទៀត គឺងូតទឹកដូចគ្នាទូទៅ ព្រោះច្បាប់គេក្នុងមួយថ្ងៃ គឺឲ្យងូតទឹកឲ្យអ្នកទោសពីរដងទូទៅគ្រប់កន្លែង ។

ង.អ៖ តើពេលណាលោកចេញពីស-២១?

ញ.ហ៖ ខ្ញុំចេញពីស-២១ ពេលបែកភ្នំពេញរត់ទៅជាមួយគ្នាទាំងអស់ រត់តាមក្រោយគុក រួចហើយមកជួបជុំគ្នានៅព្រៃស ហើយបានរត់ទាំងអស់គ្នាទៅអមលាំងកំពង់ស្ពឺ ។

ង.អ៖ សូមលោកបញ្ជាក់ពេលដែលរត់ចេញ អ្នកទោសដែលលោកការពារ តើគេចាត់ការយ៉ាងដូចម្តេចដែរ?

[១៤:១៥:០០]

ញ.ហ៖ អ្នកទោសដែលខ្ញុំការពារនោះ គឺពួក ហ៊ុយ គេដឹកចេញទាំងឡានៗ ។ មួយកងហាក្នាគេនោះ ខ្ញុំមិនដឹងគេដឹកយកទៅណាទេ ។

ង.អ៖ ដឹកក្នុងរយៈពេលប៉ុន្មានថ្ងៃទើបអស់អ្នកទោស?

ញ.ហ៖ ប្រហែលជាដប់ថ្ងៃទើបអស់អ្នកទោស ។

ង.អ៖ ដូច្នេះ ពេលដែលកងការពាររត់ចេញ គឺអ្នកទោសអស់ពីស-២១ ហើយ?

ញ.ហ៖ អស់ហើយ ទើបកងការពាររត់ចេញពីគុកតាមកន្លែងដាំបាយ ។

ស៊ី.ប៊ី៖ តើលោករត់ជាមួយប្អូនលោកទេ?

ញ.ហ៖ អត់ទេ ។ ខ្ញុំកងការពាររត់ជាមួយគ្នា អត់បានរត់ជាមួយប្អូនទេ ។

ង.អ៖ ពេលរត់ចេញលោកមានដែលបានជួបជាមួយ ឌុច ទេ?

ញ.ហ៖ អត់ ។ កាលរត់ចេញនោះ គឺមានគ្នាច្រើនណាស់ ហើយអត់ដែលរត់ជាមួយ ឌុច ទេ រត់តែខាងការពារទាំងអស់ គឺរត់មកព្រៃស ។

ង.អ៖ មានរូបអ្នកទោស គឺស្លាប់នៅទួលស្លែងតែម្តង *"រាត្រីអាហ្វដីខ្មែរក្រហម"* *(Night of the Khmer Rouge)* ទំព័រ ១០៤ តើលោកមានដឹងទេ ពីរឿងអ្នកទោសស្លាប់នៅទួលស្លែង?

ញ.ហ៖ អាហ្នឹងពួកអ្នកកងការពារយាមនៅអគារខាងត្បូង អាគារ "A"សម្លាប់អ្នកទោសនៅមុនពេលរត់ចេញទៅ ។

ង.អ៖ តែមិនមែនជាអគាររបស់លោកយាមទេ?

ញ.អ៖ មិនមែនទេ ។

ង.អ៖ ក្នុងរូបនេះ មានអ្នកទោសបាញ់សម្លាប់ខ្លួនឯង *រាត្រីអាហ្វដីខ្មែរក្រហម* ទំព័រ ១០២ ដោយលួចកាំភ្លើងបាញ់សម្លាប់ខ្លួនឯង ។

ញ.ហ៖ កន្លែងនោះគឺជាកន្លែង ហ៊ា ។ សួស ធី ក៏ស្គាល់ដែរ ។

ស៊ី.ប៊ី៖ តើលោកដឹងថា ហ៊ា នៅឯណាទេ?

ញ.ហ៖ ពេលរត់ទៅហ្នឹងវាបែកគ្នា ។ ហ៊ា រត់ទៅអមលាំង ខ្ញុំអត់ទៅទេ ។

ស៊ី.ប៊ី៖ តើលោកថាទៅអមលាំងដែរ?

ញ.ហ៖ កាលហ្នឹងខ្ញុំអត់បានឆ្លងទេ ។ កាលហ្នឹងផែនការរបស់គេ គេឲ្យទាំងអស់គ្នាឆ្លងផ្លូវជាតិលេខ៤ ទៅអមលាំង ពេលនោះវៀតណាមបាញ់ ខ្ញុំក៏អត់បានឆ្លងទៅ ។ ខ្ញុំរត់ទៅខាងលិច ទៅខេត្តផ្សេងទៀត ។

ស៊ី.ប៊ី៖ តើលោកមានដឹងថា ហ៊ា នៅឯណាទេបច្ចុប្បន្ននេះ?

ញ.ហ៖ ដែលខ្ញុំដឹង តែទើបតែដឹងនេះ ហ៊ា នេះគឺពួក ឌុច បាញ់ចោលហើយ ។

ង.អ៖ លោកមានអ្វីចង់បន្ថែម ដែលចង់បំភ្លឺឲ្យពួកខ្ញុំដឹងទេ?

ញ.ហ៖ ដែលខ្ញុំនិយាយទាំងអស់ គឺខ្ញុំនិយាយការពិត និយាយនេះគឺនិយាយអស់ពីខ្លួនហើយ ។ ខ្ញុំនិយាយនេះ ដោយខ្ញុំឃើញនឹងភ្នែក ឮនឹងត្រចៀក ។ ខ្ញុំនិយាយចេញពីក្រអៅបេះដូងតែម្ដង ដែលខ្ញុំធ្លាប់បានរស់នៅក្នុងស-២១ នោះ ។

ស៊ី.ប៊ី៖ បន្ទាប់ពីលោកចាកចេញពីស-២១ តើលោកមានដែលជួបប្អូនលោកទេ?

ញ.ហ៖ កាលដែលបែកហើយ ខ្ញុំមិនដែលបានជួបទេ-- ប្អូនខ្ញុំទេ ហើយខ្ញុំក៏មិនដឹងថា ប្អូនរបស់ខ្ញុំនៅកន្លែងណាដែរ ។ ដល់ពេលចរចារដ្ឋាភិបាលនិងពួកខ្មែរក្រហម បានពួកអ្នកនៅប៉ៃលិនគេត្រឡប់មកភូមិ ហើយឮគេប្រាប់ខ្ញុំ ។

បញ្ចប់ការស្ដាប់ចម្លើយសាក្សីនៅម៉ោងពីរ និងសែសិបពីរនាទីរសៀល ថ្ងៃខែឆ្នាំដដែល ។

យើងសង្ឃឹមថា ពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវការលោក សូមលោកជួយសហការបន្តទៀត ។

ឯកសារថតចម្លងនៃកំណត់ហេតុមួយច្បាប់ ត្រូវបានប្រគល់ឲ្យសាក្សីនេះ ។

អានឲ្យស្ដាប់ ហើយសាក្សីមិនមានជំទាស់អ្វីទេ ហើយសុខចិត្តចុះហត្ថលេខា ។

សាក្សី, ញេប ហូ ។"

**ប្រធានអង្គជំនុំ៖**

ក្រោយពីបានស្ដាប់នូវក្រឡាបញ្ជីសវនាការអាននូវកំណត់ហេតុ ស្ដីពីការស្ដាប់ចម្លើយសាក្សីដែលឈ្មោះ ញេប ហូ តើតំណាងសហព្រះរាជអាជ្ញាមានអ្វីកត់សម្គាល់លើខ្លឹមសារនៃចម្លើយសាក្សីរូបនេះដែរឬទេ?

**លោក យ៉េត ចរិយា៖**

អរគុណលោកប្រធាន ។ ចំពោះសក្ខីកម្មរបស់សាក្សី ញេប ហូ ដែលលោកក្រឡាបញ្ជីអានអម្បាញ់មិញនេះ តំណាងសហព្រះរាជអាជ្ញាពុំមានយោបល់កត់សម្គាល់ ឬតវ៉ាឡើយ ។

**ប្រធានអង្គជំនុំ៖**

ចុះខាងមេធាវីអ្នកតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី តើមានមតិយោបល់កត់សម្គាល់លើខ្លឹមសារនៃកំណត់ហេតុដែលអានដោយក្រឡាបញ្ជីអម្បាញ់មិញនេះដែរឬទេ?

**លោក អាឡាំង វែ៊នណឺ៖**

យើងខ្ញុំគ្មានមតិយោបល់អ្វីទេលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ចុះចំណែកឯមេធាវីការពារក្តីតើលោកមេធាវីមានមតិយោបល់កត់សម្គាល់អ្វីដែរទេ លើខ្លឹមសារនៃកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែលធ្វើដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលអានដោយក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ សាក្សីឈ្មោះ ញេប ហូ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ក្នុងនាមមេធាវីការពារ ខ្ញុំសូមធ្វើសេចក្តីសង្កេតដូចតទៅនេះ ។ ប្រហែលជាមានលក្ខណៈជាការសង្កេតទូទៅ ។ ពេលដែលអង្គជំនុំជម្រះបានសម្រេចមិនកោះហៅសាក្សីមួយចំនួនដើម្បីមកផ្តល់សក្ខីកម្មផ្ទាល់ទេ នេះជាសេចក្តីសម្រេចប្រកបដោយគតិបណ្ឌិត ដោយសារសេចក្តីនោះបានធ្វើរួចហើយនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ គឺថាមួយខែកន្លងទៅហើយ ជាងមួយខែកន្លងទៅហើយ ។

លោក ហូ នោះបញ្ជាក់ត្រឹមត្រូវហើយរវាងឆ្នាំ២០០៩ នោះ យើងបានស្តាប់សាក្សីមួយចំនួនចំពោះមុខតុលាការ ។

សំណួរដែលគួរតែសួរនៅថ្ងៃនេះនោះ គឺដូចតទៅនេះ ។ ក្នុងន័យដែលថា ព័ត៌មានរួមទទូទៅដែលសាក្សីបានផ្តល់ជូនតុលាការនោះ គឺចំណុចដែលពាក់ព័ន្ធទៅនឹងដែលថា ជនជាប់ចោទបានទទួលស្គាល់នូវអង្គហេតុ អ្វីដែលជាការចូលរួមនៅក្នុងចម្លើយដែលទើបតែបានអានអម្បាញ់មិញនេះ គឺជាព័ត៌មានបន្ថែមដែលផ្តល់នៅក្នុងចម្លើយនោះ ។ ខ្ញុំសូមគោរពនិងទាញអារម្មណ៍អង្គជំនុំជម្រះនូវមាត្រា៨៥ នៃវិធានផ្ទៃក្នុងដែលចែងថា៖

[១៤:២៣:៥៦]

“ក្រោយពីការពិគ្រោះយោបល់ជាមួយចៅក្រមនានារួចហើយ ប្រធានអង្គជំនុំជម្រះ អាចនឹង-- សវនាការអាចបដិសេធនូវរាល់នីតិវិធីដែលនាំឲ្យមានការពន្យារពេលដល់ការជំនុំជម្រះ ដែលមិនអាចនាំដល់ការស្វែងរកការពិតនោះទេ” ។ ដូចគ្នានេះដែរ គឺអាចអាននៅក្នុងវិធាន៨៧ ដែលវិធាននោះចែងថា៖ “អង្គជំនុំជម្រះអាចប្រកាសទទួលយកភស្តុតាងមួយចំនួន បើសិនជាខ្លួនយល់ថា មិនជាប់ពាក់ព័ន្ធ អាចនឹងច្រានចោលបាន” ។ នេះហើយជាចំណុចដែលយើងកំពុងប្រឈមមុខពេលនេះ ។ យើងមានជនជាប់

ចោទដែលបានទទួលស្គាល់នូវអង្គហេតុទាំងអស់ដែលបានចោទប្រកាន់ ។

សាក្សីមួយចំនួនដែលបានមកបង្ហាញ ហើយនិងផ្តល់សក្ខីកម្មនៅតុលាការនេះ ក៏បានបញ្ជាក់ទៅលើសម្តីអ្វីដែលជនជាប់ចោទបានបញ្ជាក់ ។ ខ្ញុំៗយល់ថា-- លោកប្រធាន លោក លោកស្រីចៅក្រមខ្ញុំយល់ថា នៅដំណាក់កាលនេះ នៅក្នុងដំណើរការនីតិវិធី នីតិវិធីដ៏ល្អនោះគប្បីតែស្នើសុំឲ្យសហព្រះរាជអាជ្ញាគប្បីតែកំណត់ដើម្បីជាផលប្រយោជន៍របស់អង្គជំនុំជម្រះ ថាតើអ្វីជាអង្គហេតុ ឬក៏ព័ត៌មានដែលអាចរកឃើញនៅក្នុងសក្ខីភាពមួយចំនួនដែលមិនទាន់បានអាននោះ ។ នៅក្នុងចំណុចដែលជនជាប់ចោទបានទទួលស្គាល់អង្គហេតុនោះ វាមានចំណុចមួយចំនួនតូចដែលគាត់មិនជំទាស់ តើយើងអាចសង្ឃឹមបានដែរឬទេថាសហព្រះរាជអាជ្ញា នឹងផ្តោតអារម្មណ៍ទៅលើចំណុចមួយចំនួននោះ គឺចំណុចដែលជនជាប់ចោទបានជំទាស់នោះ ថាតើសាក្សីទាំងឡាយដែលចង់ដាក់សក្ខីភាពមកតុលាការហ្នឹង ឬចង់ឲ្យមានការជំទាស់ ឬក៏ការតទល់ចំណុចណាពីជនជាប់ចោទនោះ?

ខ្ញុំបានបញ្ជាក់ពីខាងដើមហើយថា ប្រសិនបើនេះជាដំណើរការនីតិវិធីតាម *ខំម៉ិនឡ* ប្រសិនបើជនជាប់ចោទបានទទួលស្គាល់នូវការទទួលខុសត្រូវរបស់គាត់ហើយ ការជំនុំជម្រះនេះអាចនឹងបញ្ចប់ទៅហើយ។ ប៉ុន្តែ អ្វីដែលខ្ញុំរំឭកឡើងវិញនៅទីនេះនោះ គឺថា ប្រសិនបើយើងស្ថិតនៅក្នុងៗដំណើរការនីតិវិធីប្រព័ន្ធ *ស៊ីវិលឡ* ទាំងស្រុងនោះ សវនាការក៏គប្បីតែបញ្ចប់នោះផងដែរ ។

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំសូមបញ្ជាក់ថាយើងបានបញ្ជាក់ឡើងវិញដដែលៗដែលមិនចាំបាច់ ហើយខ្ញុំបានស្នើឡើងម្តងហើយម្តងទៀត គឺថាសហព្រះរាជអាជ្ញាគប្បីលើកឡើងនូវអង្គហេតុពាក់ព័ន្ធដែលតម្រូវឲ្យយើងពិនិត្យពិចារណាទៅលើការអាននូវចម្លើយសក្ខីភាពទាំងអស់នេះ ។ នេះជាសំណើរបស់ខ្ញុំ ។

[១៤:២៧:៥៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក អានីស អះមេដ៖**

សូមអរគុណលោក លោកស្រីចៅក្រម ដែលផ្តល់ឱកាសឲ្យខ្ញុំ ។ សហមេធាវីការពារក្តី គឺមិនបានយល់សំណួររបស់ប្រធាន នៅពេលដែលលោកប្រធានបានស្នើសុំឲ្យធ្វើការសង្កេតទាក់ទងទៅនឹងចម្លើយរបស់សាក្សីអម្បាញ់មិញនេះ ។ ប្រសិនបើមេធាវីការពារក្តីគាត់បដិសេធមិនដាក់បញ្ចូលចម្លើយ

នេះ គឺគាត់គួរតែនិយាយ ។ ដូច្នេះហើយ វាមិនមែនថាយើងត្រូវសម្រេចកោះហៅសាក្សីមកនៅក្នុងសវនាការ ឬក៏អត់នោះទេ ។ បញ្ហានេះគឺយើងបានពិភាក្សាគ្នានៅក្នុងកិច្ចប្រជុំរៀបចំសវនាការរួចហើយ យើងពិភាក្សាគ្នាពីរដង ហើយបញ្ជីដែលលោក លោកស្រីចៅក្រមទទួលបាននោះ គឺភាគីជាអ្នកផ្តល់ជូន ប៉ុន្តែចំណុចចុងក្រោយៗបញ្ជីដែលលោក លោកស្រីចៅក្រម បានសម្រេចចំពោះសាក្សីត្រូវចូលមកក្នុងសវនាការ គឺចៅក្រមជាអ្នកសម្រេច ហើយលោក លោកស្រីចៅក្រម បានសម្រេចកោះហៅសាក្សីមួយចំនួនជាក់លាក់ ហើយជនរងគ្រោះខាងដើមបណ្តឹងរដ្ឋប្បវេណី ក៏សម្រេចមិនកោះហៅសាក្សីជនរងគ្រោះមួយចំនួននោះដែរ ហើយលោក លោកស្រីចៅក្រមក៏បានសម្រេចមិនអានសក្ខីកម្មមួយចំនួនផងដែរ ។

ដូច្នេះ អង្គសវនាការបានអនុវត្ត និងចេញសេចក្តីសម្រេចយ៉ាងជាក់លាក់ថាតើសាក្សីណាដែលត្រូវកោះចូលមក ហើយសក្ខីកម្មណាដែលត្រូវអាននៅក្នុងសវនាការ ហើយសេចក្តីសង្ខេតណាដែលលោកលោកស្រីចៅក្រមនឹងយកទៅពិចារណា ។ យើងបានអនុវត្តហើយអស់ហើយ នៅពេលនេះគឺវាហាក់ដូចជាយឺតពេលហើយ ដែលថា យើងត្រឡប់ទៅនិយាយអំពីបញ្ជីសាក្សីឡើងវិញ ដែលលោកលោកស្រីចៅក្រមបានរៀបចំយ៉ាងល្អបំផុតជាមួយ ដោយមានការប្រឹក្សាជាមួយភាគីរួចហើយនោះ ។

[១៤:៣០:០០]

ដូច្នេះ ហើយនៅក្នុងរឿងក្តីយើងដែលធំដូច្នេះ ហើយមេធាវីការពារក្តីគាត់មានបទពិសោធន៍យ៉ាងច្រើននៅក្នុងសវនាការធំៗនេះ ។ ទោះបីយ៉ាងណាក៏ដោយ វាតែងតែមានការជាន់គ្នាហើយទៅលើសក្ខីកម្ម ។ ហើយដូចលោកលោកស្រីចៅក្រម បានឃើញហើយ សាធារណជនក៏គាត់យល់ដែរ សាក្សីទាំងឡាយគឺគាត់តែងតែយកធាតុផ្សំផ្សេងៗនិងអង្គហេតុផ្សេងៗជូនអង្គសវនាការ ហើយភាគីតាមការបង្គាប់របស់អង្គសវនាការ ក៏បានផ្តោតទៅលើអង្គហេតុដែលសាក្សីផ្តល់ឲ្យនោះដែរ ។

ដូច្នេះហើយខ្ញុំសូមដាក់ជូនថា មេធាវីការពារក្តីគួរតែបញ្ជាក់ថា តើគាត់ទទួលយកដែរឬទេចំពោះការអាននេះ ដោយមិនចាំបាច់កោះហៅសាក្សី? ហើយខ្ញុំសូមស្នើអង្គសវនាការ កុំឲ្យមេធាវីការពារក្តី ឬក៏ភាគីណាផ្សេងទៀតគាត់លើកឡើងបញ្ហានេះសាជាថ្មី ។

ដូច្នេះ ខ្ញុំសូមសរុប និងបញ្ជាក់ថានៅពេលនេះយើងមិនតវ៉ាទៅលើថាវាជាប្រព័ន្ធច្បាប់*ខំមិនឡូ* ឬក៏*ស៊ីវិលឡូ* នោះទេ យើងមានវិធានច្បាប់របស់យើង លិខិតបទដ្ឋានគតិយុត្តិ ហើយយើងមានលក្ខន្តិកៈទាំងអស់បានចែងទៅលើបញ្ហានេះហើយ ។

ដូច្នេះហើយ យើងត្រូវគោរពតាមទៅលើលិខិតបទដ្ឋានគិតយុត្តិរបស់យើង មិនចាំបាច់ពិភាក្សា

និងជជែកគ្នាទៅលើបញ្ហាច្បាប់*ខំមិនឡូ* ឬក៏*ស៊ីវិលឡូ* នោះទេ ។ ខ្ញុំសូមអរគុណច្រើន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ហ្វ្រង់ស្វ័រ រូ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន លោកលោកស្រីចៅក្រម នៅក្នុងករណីនេះ គឺយើងអាចបន្តទៅមុខទៀត ។ ដូចដែលអ្វីសហព្រះរាជអាជ្ញាបានលើកឡើង មេធាវីការពារក្តីស្នើសុំអនុវត្តវិធាន៨៥ នៃវិធានផ្ទៃក្នុងរបស់យើង ហើយមេធាវីការពារក្តីស្នើសុំអង្គសវនាការថា ឲ្យអង្គសវនាការ គឺពិភាក្សាជាមួយនឹងអង្គចៅក្រមផ្សេងៗឲ្យដកទៅលើសក្ខីកម្មទាំងឡាយដែលបានអានហើយ ឬក៏វាមានអង្គហេតុដូចគ្នាហើយនោះ ។ ដោយសារតែមេធាវីការពារក្តីជឿថា ចម្លើយទាំងអស់នោះ វានាំឲ្យអូសបន្លាយនីតិវិធីរបស់យើងយូរ ហើយដោយមិនជួយទៅដល់ការរកការពិតនោះទេ ។

ដូច្នេះហើយនេះគឺជាអ្វីដែលខាងមេធាវីការពារក្តី ខ្ញុំសូមដាក់ជូន ។ ហើយខ្ញុំសូមរំឭកនៅពេលនេះដែរថា អង្គសវនាការបានចេញសេចក្តីសម្រេចនៅថ្ងៃទី២៩ ខែមិថុនា ហើយៗមិនធ្វើការកោះហៅ ឬក៏ដេញដោលផ្ទាល់មាត់ទៅលើសាក្សីមួយចំនួននោះទេ ។

[១៤:៣២:៥៤]

ដូច្នេះហើយនៅថ្ងៃនេះ គឺយើងហាក់ដូចជាមានជំហរខុសពីថ្ងៃទី២៩ ខែមិថុនា ហើយអង្គសវនាការគាត់យល់ច្បាស់ អំពីសេចក្តីសម្រេចទាំងអស់នោះ ។ ដូច្នេះ ខ្ញុំស្នើសុំឲ្យដកបញ្ចេញដកចេញនូវឯកសារទាំងឡាយ ដែលវាស្របទៅនឹងវិធាន៨៥របស់យើង និងវិធាន៨៧ ។ ហើយប្រសិនបើឯកសារទាំងឡាយមិនពាក់ព័ន្ធ ឬក៏ឯកសារទាំងអស់នោះជាន់គ្នានោះ គឺខ្ញុំសុំឲ្យដកចេញ ។

សូមអរគុណច្រើន លោក លោកស្រីចៅក្រម ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា ។

**លោក អានីស អះមេដ៖**

លោក លោកស្រីចៅក្រម ខ្ញុំមិនតវ៉ាទៅលើមេធាវីការពារក្តី ទាក់ទងទៅនឹងចំណាយពេលយូរនោះទេ ។ ខ្ញុំគ្រាន់តែស្នើសុំដល់អង្គសវនាការ ខ្ញុំសូមលើកឡើងថា វិធាន៨៧.៣ គឺវាទាក់ទងទៅនឹងរយៈ

ពេលកំណត់ដែលមេធាវីបានលើកឡើង ។ វិធាន៨៧ ឱ្យអង្គសវនាការពិចារណាបញ្ហាទាំងឡាយ ដែលថាគួរតែធ្វើការសង្ខេប ឬក៏យើងអានវាដើម្បីយកជាភស្តុតាង ។ ហើយវាអាស្រ័យទៅលើការអនុញ្ញាតរបស់ប្រធានដែលឱ្យក្រឡាបញ្ជីអានសេចក្តីសង្ខេបនៃចម្លើយ ឬក៏មិនអានទាំងអស់តែម្តង ។

ដូច្នេះហើយ វាជាការពិចារណារបស់អង្គចៅក្រមទៅលើសាធារណជន ដើម្បីឱ្យគាត់យល់ថា វាជាដំណើរការមួយដែលវាដំណើរការទៅលឿន និងឆាប់រហ័ស ប៉ុន្តែយ៉ាងណាក៏ដោយ វាជាការគិតពិចារណា និងការអនុញ្ញាតពីអង្គសវនាការទៅលើបញ្ហាទាំងអស់នេះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រី ស្មួតហ្សិនស្តិ ។

**លោកស្រី ស៊ីលឃីស្មួត ហ្សិនស្តិ៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម ។ ខ្ញុំសូមធ្វើការជំទាស់ពាក្យសុំ ឬក៏សំណើរបស់មេធាវីការពារក្តី ។ តាំងពីមុនមក មកដល់ពេលនេះចម្លើយរបស់សាក្សីគឺវាទាក់ទងគ្នាទាំងអស់ ហើយយើងបានដឹងហើយថា យើងដកចេញពីបញ្ជីកោះហៅសាក្សី ។ ហើយអង្គសវនាការបានប្រកាសជាសធារណៈហើយថា នៅក្រោយពេលកិច្ចប្រជុំមួយរបស់យើងកាលពីលើកមុន អង្គសវនាការបានប្រកាសហើយនៅចុងខែមិថុនា បានលើកឡើងថា សាក្សីណាខ្លះដែលយើងចង់ដេញដោលក្នុងសវ-នាការ ហើយសាក្សីប្រភេទណាដែលយើងត្រូវអានតែចម្លើយតែប៉ុណ្ណោះ ។ ខ្ញុំមិនចង់និយាយឡើងវិញទេទៅលើចំណុចទាំងអស់នេះ ។

[១៤:៣៥:៥៩]

ហើយប្រសិនបើអនុញ្ញាតឱ្យខ្ញុំ ខ្ញុំត្រូវការប្រាំនាទី ដើម្បីលើកឡើងរំឭកទៅលើសាក្សីមួយចំនួន និងចម្លើយរបស់គាត់ដែលត្រូវអាន ប៉ុន្តែយ៉ាងណាក៏ដោយគឺខ្ញុំចងចាំថា លោក លោកស្រីចៅក្រម ជាពិសេសលោកស្រីចៅក្រម ខាតវ៉ាយច៍ បានជម្រាបហើយចំពោះចម្លើយដែលត្រូវអាន ។ ហើយខ្ញុំសូមបញ្ជាក់ផងដែរថា តើផ្នែកមួយណាដែលវាពិសេស ហើយវាពាក់ព័ន្ធនោះ ។

ដូច្នេះហើយ សាក្សីនោះគឺគាត់គួរតែយកមកធ្វើការដេញដោល ។ នេះជាអ្វីដែលខ្ញុំដាក់ជូន សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ហ្វ្រង់ស្វ័រ រូ ។ ហើយនេះជាលើកចុងក្រោយហើយ នៃការផ្តល់ឱកាសជូន

លោក ដើម្បីពាក់ព័ន្ធជាមួយនឹងបញ្ហានេះ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន សូមអរគុណលោកតំណាងសហព្រះរាជអាជ្ញា ចំពោះការស្នើសុំមានលក្ខណៈវិជ្ជមានរបស់គាត់ ទាក់ទងទៅនឹងសេចក្ដីសង្ខេបទៅលើចម្លើយ។ គឺខ្ញុំពេញចិត្ត ដើម្បីចៀសវាងការជាន់គ្នាទៅលើចម្លើយទាំងឡាយ ។ ដូច្នេះ ថាតើយើងអាចស្នើសុំខាងសហព្រះរាជអាជ្ញាឲ្យជម្រាបមកកាន់យើងទាំងអស់គ្នាទៅដែលថាអង្គហេតុ ឬធាតុផ្សំមួយណាដែលវាទាក់ទងនៅក្នុងចម្លើយទាំងអស់នោះ ។ ហើយអង្គហេតុណាដែលវាជាអង្គហេតុថ្មីចំពោះការដេញដោលរបស់យើង។ បើសិនបើសង្ខេបអ៊ីចឹងមែនគឺទទួលយកបាន ។ ប៉ុន្តែ សេចក្ដីសង្ខេបនោះគឺទាក់ទងទៅនឹងអង្គហេតុ និងធាតុផ្សំថ្មីដែលចំពោះការដេញដោលរបស់យើងតែប៉ុណ្ណោះ ដើម្បចៀសវាងកុំឲ្យយើងធ្វើការដេញដោលជាន់គ្នាដូចដែលមានចែងនៅក្នុងវិធាន៨៥ និង៨៧ នៃវិធានផ្ទៃក្នុងរបស់យើង ។

[១៤:៣៧:៥៦]

ដូច្នេះនេះជាការដាក់សេចក្ដីសន្និដ្ឋានរបស់ខ្ញុំ ។ ខ្ញុំសូមអនុវត្ត និងទទួលយកការដែលស្នើសុំរបស់សហព្រះរាជអាជ្ញាដែលមានលក្ខណៈវិជ្ជមាន បើសិនជាវាមានលក្ខណៈវិជ្ជមាន ដូចខ្ញុំលើកឡើងអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

អរគុណនូវមតិយោបល់របស់អស់លោក លោកស្រីតំណាងសហព្រះរាជអាជ្ញា មេធាវីហើយនិងមេធាវីការពារដែលបានកត់សម្គាល់នូវបញ្ហានេះ សុទ្ធតែគិតទៅសុទ្ធតែជាបំណងល្អដូចគ្នា គ្រាន់តែវិធីនៃការធ្វើប៉ុណ្ណោះ ។ បំណងដើម្បីដើម្បីស្វែងរកការពិត ហើយវិធី គឺមួយទាមទារយករហ័ស ហើយមួយទៀតទាមទារថា ច្បាស់លាស់ ។

អ៊ីចឹងមានន័យគឺវាទៅតែមួយទេ គ្រាន់តែវិធីនេះ ហើយអង្គជំនុំជម្រះនឹងយកទៅពិចារណាបន្ថែមទៀត ថាតើត្រូវធ្វើការសម្របសម្រួល ឬក៏កែសម្រួលយ៉ាងម៉េចនៅក្នុងនីតិវិធីប្រព្រឹត្តទៅមុខនៅក្នុងការអានឯកសារដែលជាកំណត់ហេតុសម្រាប់ ចំពោះសាក្សីដែលយើងសម្រេចចិត្តថា មិនយកមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ ដោយសារមូលហេតុឃើញថាសារសំខាន់នៃការសាក្សីទាំងនោះដែលបានផ្ដល់ភស្ដុតាងនៅចំពោះមុខអ្នកស៊ើបអង្កេត នៃអង្គអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតហើយ ហើយដោយសារគោលបំណងយើងគឺ ដើម្បីពន្លឿននូវដំណើរការសវនាការរបស់យើងបានឆាប់រហ័ស ។

ហើយជាកិច្ចបន្តនេះ គឺអង្គជំនុំជម្រះផ្តល់វេទិកាទៅជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់លើសក្ខីកម្មរបស់សាក្សី ញ៉េប ហូ ដែលបានអានដោយក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ។

សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ខ្ញុំពិតជាស្គាល់មិត្ត ញ៉េប ហូ ហៅ វ៉ាន់ នេះ កាលដែលនៅធ្វើការ ស-២១ ទាំងអស់គ្នា ។ ខ្ញុំតទៅទៀតនេះ ខ្ញុំសូមជូនអំពីអត្តចរិតរបស់មិត្ត វ៉ាន់ ហើយនិងមិត្ត ប៉េង ។ បងប្អូនទាំងពីរនាក់នេះមិនដូចគ្នាទេ ។ ហើយសក្ខីកម្មរបស់គាត់អំពីបញ្ហាអ្នកទោស ខ្ញុំមិនជឿងទាំងអស់ក៏ពិតមែន ក៏ប៉ុន្តែវាជាកញ្ចក់មួយសម្រាប់ជូនអង្គជំនុំជម្រះ លោកមេត្តាពិចារណាលើទិដ្ឋភាពផ្សេងៗនិយាយអំពីជីវភាពអ្នកទោសនៅក្នុងស-២១ ។ ខ្ញុំមានបញ្ហាតែប៉ុណ្ណេះដែលសូមបញ្ជាក់ជូន សូមគោរព។

[១៤:៤០:៥៩]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងត្រូវសម្រាក ។ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីរហូតដល់ម៉ោងបីយើងចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការរបស់យើង ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១៤:៤១នាទី ដល់ម៉ោង ១៥:២២នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ មុននឹងឲ្យក្រឡាបញ្ជីអាននូវកំណត់ហេតុស្តាប់សក្ខីកម្មសាក្សីបន្ត អង្គជំនុំជម្រះសូមប្រកាសនូវសេចក្តីសម្រេចតបទៅនឹងសំណើសុំរបស់មេធាវីការពារក្តី ដូចខាងក្រោម៖

អង្គជំនុំជម្រះ កត់សម្គាល់ឃើញថា សំណើដែលដាក់ដោយមេធាវីការពារក្តី ក្នុងការពិនិត្យឡើងវិញនូវបញ្ជីនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលត្រូវអាននៅក្នុងអំឡុងពេលសវនាការ អង្គជំនុំជម្រះនឹងត្រួតពិនិត្យឡើងវិញ នូវបញ្ជីនៃកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលកំណត់ហេតុស្តាប់ចម្លើយសាក្សី

ណាត្រូវអាននៅក្នុងសវនាការ ហើយកំណត់ហេតុស្តាប់ចម្លើយសាក្សីណាខ្លះ ដែលគ្រាន់តែត្រូវសង្ខេប ឬត្រូវកំណត់អត្តសញ្ញាណ ។ នៅក្នុងអំឡុងពេលនេះផងដែរ ជាការអនុវត្តអង្គជំនុំជម្រះនឹងបន្តការអាន នូវកំណត់ហេតុ ស្តាប់ចម្លើយសាក្សីពេញលេញទៅតាមកាលបរិច្ឆេទដែលបានកំណត់នៅរសៀលនេះ ។

ជាកិច្ចបន្ត ចាត់លោកស្រី សែ កុលវុឌ្ឍី អាននូវកំណត់ហេតុរបស់សាក្សី កំណត់ហេតុស្តាប់ចម្លើយសាក្សី គង់ ផៃ ដែលមានលេខ D28/1, D53, D54 និង D48/2 ។

[១៥:២៥:០១]

**លោកស្រី សែ កុលវុឌ្ឍី៖**

“ការិយាល័យសហចៅក្រមស៊ើបអង្កេត ។ សំណុំរឿងព្រហ្មទណ្ឌលេខ០០២ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦ ។ លេខស៊ើបសួរ០០១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ។

កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ។

ឆ្នាំពីរពាន់ប្រាំពីរ ខែធ្នូ ថ្ងៃទីម្ភៃប្រាំពីរ នៅវេលាម៉ោងប្រាំបួន និងសាមសិបនាទី នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

យើង ស៊ីម សុរិយ៉ា ជាអ្នកស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ ដែលត្រូវបានចាត់ដោយដីកាចាត់ឱ្យស៊ើបសួរជំនួសរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ ។

នៅថ្ងៃទីដប់ប្រាំបួន ខែធ្នូ ឆ្នាំពីរពាន់ប្រាំពីរ យើងបានជួបសាក្សីឈ្មោះ គង់ ផៃ នៅផ្ទះរបស់គាត់ ដោយគាត់ជាប់រវល់ គាត់សំណូមពរយើងសួរគាត់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទីម្ភៃប្រាំពីរ ខែធ្នូ ឆ្នាំពីរពាន់ប្រាំពីរវិញ ។

បានឃើញ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ។

បានឃើញ វិធាន២៤,២៨ និង៦០ នៃវិធានផ្ទៃក្នុង នៃអង្គជំនុំជម្រះវិសាមញ្ញ ។

បានកត់ត្រាយកចម្លើយពីឈ្មោះបច្ចុប្បន្ន គត់ ផៃ ជាសាក្សី ដែលបានផ្តល់ព័ត៌មានស្តីពីអត្ត-សញ្ញាណដូចខាងក្រោម៖

ឈ្មោះ គង់ ផៃ ឈ្មោះបដិវត្តន៍ គ្មាន កើតនៅថ្ងៃទី០៤ ខែ០៥ ឆ្នាំ១៩៦០ ។ ជននេះបានប្រកាសថាខ្លួនចេះអាន សរសេរ និងយល់ភាសាខ្មែរ។ ហេតុដូច្នេះ ច្បាប់ដើមនៃកំនត់ហេតុនេះ ត្រូវបានសរសេរជាភាសាខ្មែរ ។

យើងបានជូនព័ត៌មានរួចហើយដល់ជននេះថា ការស្តាប់យកចម្លើយនេះ នឹងត្រូវថតយកសំឡេង

ឬរូបភាព ។

ជននេះបានប្រាប់យើងពីទំនាក់ទំនងរបស់គេ ជាមួយនឹងជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ថា គ្មាន ។

ជនេះបានស្បថស្របតាមប្បញ្ញត្តិនៃវិធាន២៤ នៃវិធានផ្ទៃក្នុង នៃអង្គជំនុំជម្រះវិសាមញ្ញ ។

យើងបានប្រាប់ដល់ជននេះ អំពីសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ស្របតាមបញ្ញត្តិនៃវិធាន ២៨ នៃវិធានផ្ទៃក្នុង នៃអង្គជំនុំជម្រះវិសាមញ្ញ និងមានសិទ្ធិមានមេធាវីការពារផងដែរ ។

សួរ-ឆ្លើយ៖

ស.ស អក្សរកាត់របស់ឈ្មោះ សឹម សុរិយ៉ា ជាអ្នកស៊ើបអង្កេត នៃអង្គជំនុំជម្រះវិសាមញ្ញ ។

ស.ស៖ កាលពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ លោកនៅឯណា? ធ្វើអ្វី?

គ.ផ៖ ខ្ញុំនៅធ្វើការក្នុងអង្គភាពឈ្លប ឃុំពានីស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ ខ្ញុំដឹកស្បៀង ពីឃុំទៅសមរភូមិមុខ នៅស្ពានពោធិ៍ ។ ស្បៀងនេះ គឺខាងអង្គភាពឈ្លបឃុំ ជាអ្នកធ្វើស្រែបានផ្ទាល់ ។ មេឈ្លបឃុំឈ្មោះ តាពឿន ជាអ្នកស្រុកកំពង់ត្រឡាចដែរ មាន តាយឹម ជាប្រធានយោធាស្រុក ។ អ្នក ដែលខ្ញុំយកស្បៀងទៅឲ្យ គឺកម្លាំងឈ្លបឃុំដែរ តែជាអ្នកចាំវ៉ៃទាហាន លន់ នល់ ផ្តាច់មិនឲ្យកម្លាំង លន់ នល់ មានទំនាក់ទំនងគ្នា ។

[១៥:២៩:១០]

ស.ស៖ សូមលោករៀបរាប់ ពីការចេញដំណើរពីកំពង់ឆ្នាំងមកភ្នំពេញ ។

គ.ផ៖ ដើមឆ្នាំ១៩៧៦ ខ្ញុំចេញពីឃុំមកភ្នំពេញ មានគ្នាបីនាក់ មកពីឃុំដូចគ្នា ស្លាប់ម្នាក់ ម្នាក់ ទៀតរស់ឈ្មោះ សេត នៅភូមិក្រាំងតាឯក ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំ ។ សេត រៀននៅ សាលាហ្វឹកហ្វឺនតាខ្មៅដែរ តែមិនបានធ្វើការនៅស-២១ទេ ។ ខ្ញុំមិនដឹងអ្នកណាទៅយកខ្ញុំពីឃុំទេ ព្រោះ គេទៅយកពេលយប់ ។ ខ្ញុំរៀននៅសាលាតាខ្មៅអស់ពេលបីខែម្ភៃប្រាំបីថ្ងៃ ។ រៀនខាងយោធាមានប្រធាន ឈ្មោះ យ៉ែម ទទួលខាងបច្ចេកទេសយោធា ។

ស.ស៖ ពេលណាបានលោកមកដល់ស-២១?

គ.ផ៖ ខ្ញុំបានទៅនៅអង្គភាពយុទ្ធជននៅតាមដងទន្លេខាងត្បូងតាខ្មៅ អស់ពេលមួយប្រាំង ទើប ខ្ញុំមកនៅអតីតគុកព្រៃស នៅឆ្នាំ១៩៧៧ ។ ខ្ញុំនៅទីនេះ អស់មួយវស្សាដាំដូង ស្ទូងស្រូវនៅកងកុមារ មាន គ្នារាប់រយនាក់ ។ ខ្ញុំស្គាល់ឈ្មោះ ទ្រី ជាពេទ្យកុមារនៅព្រៃស ។ ឥឡូវមិនដឹងនៅឯណា ។ គាត់រាង

ដំបង សម្បុរជ្រះ ដំណើរដំរី សក់ស្គួត ។ ក្រោយមកខ្ញុំមកនៅបឹងទំពុន ស្រុកស្រែប្រាំង ដាំឆៃថាវ អស់មួយប្រាំង ។ មានប្រធានក្រុមឈ្មោះ ភន ពិការដៃម្ខាង បែកគ្នាតាំងពីវៀតណាមចូល ។ ក្រោយមកទៀត ខ្ញុំមកនៅថៃដំណាំ ដាំល្ពៅ សណ្តែកសៀង នៅខាងត្បូងពេទ្យឆ្កួត ។ នៅអគារថ្មបីជាន់ឃើញមានខ្នោះ មានឈាមប្រឡាក់ មានសាកសពក្នុងបរិវេណកប់ រួចហើមប្រេះដី មើលទៅដូចជាគុកដែលទើបតែឈប់ដំណើរថ្មីៗ តែមិនដឹងអ្នកទោសជាអ្នកណា ។ ខ្ញុំមិនចាំប្រធានធំនៅទីនេះទេ ។ ខ្ញុំនៅទីនេះ អស់ពេលមួយរដូវទឹកដោះផ្លែ ។

ស.សះ ក្រោយមកយ៉ាងម៉េចទៀត?

គ.ផះ ខ្ញុំមកនៅមន្ទីរស-២១ ឈ្មោះ ភន ដដែលនោះជាអ្នកទៅយកខ្ញុំមក ។ នៅពាក់កណ្តាល ១៩៧៧ ខ្ញុំមកស-២១ ដំបូងនៅក្រុមការពារតាមរបង មានប្រធានឈ្មោះ ម៉ូ កើតពិសស្លាប់ឆ្នាំ១៩៧៨ មានឈ្មោះ ហៀង ជាសហការីប្តូរវេនគ្នា ។ ឥឡូវមិនដឹងនៅឯណា កាលឆ្នាំ១៩៧៩ នៅរស់ ។ ប្រធានលើ ម៉ូ ឈ្មោះ ស្រ៊ី កាន់កងហា ។ ឥឡូវមិនដឹងនៅឯណា កាល១៩៧៩ នៅរស់ ។ ប្រធានបន្តមកទៀតខ្ញុំមិនចាំ ។ ប្រធានធំ គឺ ឌុច ។ ខ្ញុំមិនស្គាល់ ប៉ូច ទេ ។

[១៥:៣២:៥៦]

ស.សះ លោកនៅការពារខាងក្រៅឃើញអ្វីខ្លះ?

គ.ផះ ខ្ញុំឃើញគេនាំអ្នកទោសចេញចូល ។ ខ្ញុំអនុញ្ញាតបើកទ្វារ តាមការស្គាល់ចំណាំមុខអ្នកសួរចម្លើយដែលចេញចូល មានឈ្មោះ ទុយ រាងស ខ្ពស់ ដំណើរយោល ។ ឥឡូវមិនដឹងនៅឯណា កាល ១៩៧៩ នៅរស់ ។ ឆ្នាំ១៩៧៨ ខ្ញុំបានឃើញជនជាតិអាមេរិកបីនាក់ នាំចូលច្រកខ្ញុំយាមដែលជាច្រកខាងត្បូងច្រកចូលសព្វថ្ងៃ និងជាកន្លែងដាក់អ្នកទោសសំខាន់ៗ ។ ទាំងបីនាក់ដាក់នៅជាន់ទីពីរក្នុងបន្ទប់ខុសគ្នា ។ ខ្ញុំឃើញ ឌុច, ហ៊ី, ចាន់ សម្រេង ចូលមកសួរ ។ បន្ទាប់មក ខ្ញុំយកបាយទៅឲ្យអ្នកទោសម្នាក់ក្នុងចំណោមបីនាក់នោះ ។ ឃើញ ឌុច កំពុងសួរចម្លើយម្នាក់នោះ ប្រុសសក់ក្រហម រួញរែងដាបស្នាសម្បុរស មានរោមទ្រូង ស្លៀកខោខ្លី ។ មុន ឌុច សួរម្នាក់នេះពាក់អាវប៉ារ៉ាយឺតដៃខ្លី ។ ក្រោយមក ហៀង ដែលដូរវេនយាមយប់ ប្រាប់ខ្ញុំថា គេយកបីនាក់នេះចេញហើយ មិនដឹងទៅណាទេ ។ ហើយបាត់រហូតពេលខ្លះខ្ញុំបានយាមតាមបន្ទប់ ឃើញមានអ្នកទោសស្រីៗវៀតណាមចូលមក ខ្ញុំជាអ្នកយាម និងយកបាយទៅឲ្យ ។ ខ្ញុំដឹងតាមរយៈអ្នកសួរចម្លើយថា ស្ត្រីទាំងនេះជាស្រីខ្មចរបស់ទាហានវៀតណាមដែលខ្មែរក្រហមចូលទៅវាយបាន ហើយចាប់យកមក ។ ខ្ញុំបានឃើញបុរសទាហានវៀតណាមម្នាក់

ដែលខ្ញុំយាម ។ ក្រោយមកខ្ញុំមកយាមទ្វាររបងដដែល ។ មិនដឹងម្នាក់នេះទៅណា ខ្ញុំមិនស្គាល់ឈ្មោះអ្នកទោសធំៗដទៃទៀតទេ ។ ពេលខ្លះគេយកអ្នកទោសទាំងជាប់ដៃ ចងមុខ យកទៅសួរនៅកន្លែងផ្សេងខាងកើតកន្លែងខ្ញុំ ។

ស.សះ លោកនៅទីនេះ រហូត?

គ.ផះ ខ្ញុំនៅរហូតដល់បែក ១៩៧៩ ។

ស.សះ លោកដែលមានរៀនសូត្រ និងទទួលការណែនាំពី ឌុច ឬទេ?

គ.ផះ ខ្ញុំបានរៀនពីរដង ម្តងប្រហែលពីរបីថ្ងៃ ។ រៀនអំពីការការពារកុំឱ្យអ្នកទោសរត់ រៀនលក្ខន្តិកៈបក្ស សភាពការណ៍នយោបាយ និងសង្គ្រាម ។ ឌុច បង្រៀនផ្ទាល់ ។ គាត់ថាកុមារជាទំពាំងស្នងឫស្សីរបស់បក្ស ។

ស.សះ ឌុច និងហ៊ី ជាមនុស្សត្រូវគ្នាទេ?

គ.ផះ ខ្ញុំឃើញគាត់ធ្វើការជាមួយគ្នាធម្មតា ។ ឆេន នីរសាររបស់ ឌុច មានភិនភាគសម្បុរជ្រះមាឌដំបង មិនខ្ពស់មិនទាប រាងមូល ។ កាលនោះមិនទាន់មានប្រពន្ធ ស្រុកកំណើតនៅអមលាំង ។

ស.សះ អ្នកនៅជាមួយគ្នា លោកឃើញនរណាត្រូវចាប់ទេ?

គ.ផះ ខ្ញុំមិនដែលឃើញដឹងតែបែកគ្នាឆ្នាំ១៩៧៩ ។

ស.សះ លោកមានស្គាល់អ្នកណាផ្សេងទៀតទេ នៅផ្នែកណាខ្លះ?

គ.ផះ ធំជាងគេគឺ ឌុច ។ បន្ទាប់មក ហ៊ី ជាអនុ ។ ចាន់ សម្រែងជាសមាជិក ។ កងការពារកងសួរចម្លើយ កងចាប់ចង ពួកចុងភៅ អង្គភាពពេទ្យ ។ កន្លែងខ្ញុំយាមមានប្រធានឈ្មោះ ស៊្រុំ ។ កងចាប់ចងមានប្រធានឈ្មោះ ហ៊ុយ, ទាប និងប៉េង ។ កងនេះមានប្រើឡានម៉ាស៊ីនសូវៀត និងឡានចិនប្រហែលបួន ប្រាំគ្រឿងសម្រាប់ទៅចាប់តាមភូមិភាគ ។ ក្រៅពីនេះ ខ្ញុំភ្លេចអស់ហើយ ។

ស.សះ មានដែលឃើញគេបូមឈាមអ្នកទោស?

គ.ផះ មិនដែលទេ ។

ស.សះ មានដែលឃើញអ្នកសួរចម្លើយធ្វើទារុណកម្មអ្នកទោសទេ?

គ.ផះ ខ្ញុំឃើញផ្ទាល់ ឃើញអ្នកសួរចម្លើយវាយអ្នកទោសនឹងរំពាត់ ឆក់ខ្សែភ្លើង ឮសូរសំឡេងស្រែករបស់អ្នកទោស ឃើញពេទ្យមកព្យាបាលអ្នកទោសដែលមានរបួស ។ អ្នកសួរចម្លើយគ្រប់គ្នាសុទ្ធតែធ្វើទារុណកម្មលើអ្នកទោស ក្នុងនោះមាន ទុយ ដែលជាអ្នកសួរចម្លើយផងដែរ ។

[១៥:៣៨:១២]

ស.ស៖ គោលការណ៍ធ្វើទារុណកម្មនេះ ឌុច ជាអ្នកបញ្ជាឬ?

គ.ផ៖ បាទ គឺខ្ញុំធ្លាប់ដឹងពី ឌុច នៅកន្លែងសាលារៀន ពីប្រធានកងរយ ប្រធានកងហា ពួកគាត់ថាអ្នកទោស គឺជាខ្មាំង ។ ហើយបើមិនឆ្លើយអាចធ្វើទារុណកម្មបាន ។

ស.ស៖ ពេលរត់១៩៧៩ តើមានបញ្ជាពី ឌុច ឲ្យធ្វើយ៉ាងណាចំពោះអ្នកទោស?

គ.ផ៖ កន្លែងខ្ញុំយាម គឺមកដល់ពេលនោះពុំមានអ្នកទោសទៀតទេ ។ ប៉ុន្មានថ្ងៃមុន៧ មករា ១៩៧៩ ខ្ញុំក៏ត្រូវគេឲ្យមកយាមនៅខាងអគារធំ ។ កន្លែងច្រកចូលសព្វថ្ងៃដោយមានអ្នកទោសច្រើនពេក អ្នកទោសទាំងនេះ ត្រូវសម្លាប់នៅទួលស្លែង ខ្លះដឹកទៅជើងឯកខ្លះ គឺអស់រលីងមុនពេលពួកខ្ញុំរត់ ។ ខ្ញុំបានឃើញការសម្លាប់នេះដោយផ្ទាល់ ។ ខ្ញុំមិនបានឃើញ ឌុច នៅទីនោះទេ ។ តែបើគ្មានការចាត់តាំងរបស់គាត់គ្មានអ្នកណាហ៊ានធ្វើទេ ។

ស.ស៖ អរគុណច្រើន ។

អានឲ្យស្តាប់ចម្លើយសាក្សីមិនមានជំទាស់អ្វីទេ ហើយសុខចិត្តចុះហត្ថលេខា ។ ឯកសារថតចម្លងមួយច្បាប់ ឬឯកសារច្បាប់ដើមណាមួយក្នុងចំណោមឯកសារច្បាប់ដទៃទៀតនៃការថតត្រូវបានប្រគល់ឲ្យសាក្សីនេះ ។ កិច្ចនេះបញ្ចប់នៅវេលាម៉ោង ១២ និង២៦ នាទីថ្ងៃត្រង់នាថ្ងៃដដែល។

សាក្សី, គង់ ផៃ"

[១៥:០១:១៣]

"ការិយាល័យសហចៅក្រមស៊ើបអង្កេតសំណុំរឿងព្រហ្មទណ្ឌលេខ 00២ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២00៦ ។ លេខស៊ើបសួរ លេខ០០១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២00៧ ។

កំណត់ហេតុនៃការតទល់មុខគ្នា ។

ឆ្នាំពីរពាន់ប្រាំបី ខែកុម្ភៈ ថ្ងៃទីម្ភៃប្រាំបី នៅវេលាម៉ោងដប់ប្រាំមួយ និងប្រាំនាទី ។

យើង ម៉ាកសែល ឡឺម៉ង់ដ៍ ជាសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ ដោយមានលោក ហាម ហ៉ែល និងលោក លី ច័ន្ទតុលា ជាក្រឡាបញ្ជីអមផង ។

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ។

បានឃើញវិធាន ៥៨ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះ វិសាមញ្ញ ។

បានឃើញសេចក្តីសម្រេចផ្ទេរសិទ្ធិចុះថ្ងៃនេះ ដោយមានវត្តមានរបស់ អ៊ុំច ច័ន្ទណ្ឌារ៉ា និង តាន់

ប៉ាងដាវណ្ណ ជាអ្នកបកប្រែនៃអង្គជំនុំជម្រះវិសាមញ្ញដែលបានស្បថរួចហើយ ។

ជនត្រូវចោទ ដែលមានអត្តសញ្ញាណដូចខាងក្រោមបានចូលខ្លួននៅចំពោះមុខយើង ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ភេទ ប្រុស កើតថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ ត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ។

បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា ៥ មាត្រា៦ មាត្រា ២៩ថ្មី និងមាត្រា៣៩ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ។

សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញលោក រ៉ូបឺត ពើទីត និងអ្នកស្រី ជា លាង ត្រូវបានជូនដំណឹងត្រឹមត្រូវរួចហើយអំពីការសួរចម្លើយនេះ នៅក្នុងលិខិតជូនដំណឹងចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨។

អ្នកស្រី ជា លាង មានវត្តមាន ។ លោក រ៉ូបឺត ពើទីត ត្រូវបានតំណាងដោយលោក អាឡិច ប៊េត ជំនួយការជាន់ខ្ពស់សហព្រះរាជអាជ្ញា ។

លោកមេធាវី ការ សាវុត្ថ និងហ្វ្រង់ស្វ័រ រូ សហមេធាវីរបស់ជនត្រូវ ចោទ ត្រូវបានកោះអញ្ជើញនៅក្នុងដីកាកោះអញ្ជើញចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨ និងមានលទ្ធភាពបានពិនិត្យសំណុំរឿងតាំងពីពេលនោះមកមានវត្តមានទាំងពីរនាក់ ។

សាក្សី ហ៊ឹម ហ៊ុយ, ប្រាក់ ខន, សួស ធី, គង់ ផៃ, ម៉ម ណៃ, វ៉ាន់ ណាត និង សោម ម៉េត ដែលបានស្បថរួចហើយស្របតាមវិធាន២៤ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញមានវត្តមាន ។

ដើមបណ្តឹងរដ្ឋប្បវេណីលោក ជុំ ម៉ី និងសហមេធាវីរបស់គាត់លោកមេធាវី ហុង គឹមសួន ត្រូវបានកោះអញ្ជើញនៅក្នុងដីកាកោះអញ្ជើញចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨ និងមានលទ្ធភាពបានពិនិត្យសំណុំរឿងតាំងពីពេលនោះមកមានវត្តមាន ។

ដើមបណ្តឹងរដ្ឋប្បវេណីលោក ប៊ូ ម៉េង និងមេធាវីរបស់គាត់ លោកមេធាវី យ៉ុង ផានិត ត្រូវបានកោះអញ្ជើញនៅក្នុងដីកាកោះអញ្ជើញចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨ និងមានលទ្ធភាពបានពិនិត្យសំណុំរឿងតាំងពី ពេលនោះមកមានវត្តមាន ។

ច្បាប់ដើមនៃកំណត់ហេតុនេះត្រូវបានសរសេរជាភាសាខ្មែរ ។

[១៥:៤៤:៥៥]

ការតទល់មុខគ្នា ។ សំណួររបស់លោកសហចៅក្រមស៊ើបអង្កេតម៉ាសែល ឡឺម៉ុងដ៍ ។ កាលពី

ម្សិលមិញលោកទាំងអស់បានទៅទួលស្លែងជាមួយយើង ហើយបានផ្តល់ឲ្យយើងនូវព័ត៌មានទាក់ទងនឹងទីនោះ ។ តើលោកនៅតែអះអាងអ្វីដែលលោកបាននិយាយនៅទីនោះថា ជាការពិតដែរឬទេ?

សាក្សី គង់ ផៃ៖ បាទ, ខ្ញុំសូមបញ្ជាក់អះអាងដដែល ។

ឯកសារច្បាប់ដើមនៃការថតរូបនិងសំឡេងត្រូវបានបិទស្លាកបោះត្រានៅចំពោះមុខជនត្រូវចោទនេះ និងមេធាវីរបស់ជននេះ និងត្រូវបានចុះហត្ថលេខាដោយយើងក្រឡាបញ្ជីសហព្រះរាជអាជ្ញាជនត្រូវចោទ និងមេធាវីរបស់ជននេះ ។

ឯកសារច្បាប់ដើមមួយច្បាប់នៃការថតរូបភាពនិងសំឡេងត្រូវបានប្រគល់ឲ្យជនត្រូវចោទនេះ ។ ដោយសារមូលហេតុបច្ចេកទេសយើងមិនអាចប្រគល់នូវឯកសារច្បាប់ដើមមួយច្បាប់នៃការថតរូបភាពនិងសំឡេងទៅឲ្យសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីនៅពេលនេះទេ ។ ប៉ុន្តែ យើងប្រគល់ឲ្យពួកគេនូវច្បាប់ថតចម្លងមួយច្បាប់នៃកំណត់ហេតុនេះ ។

នៅវេលាម៉ោងដប់ប្រាំមួយ និងសាមសិបប្រាំនាទីល្ងាចយើងបានឲ្យក្រឡា បញ្ជីអានខ្លាំងៗ នូវកំណត់ហេតុនៃការតទល់មុខគ្នាទៅតាមអ្វីដែលបានកត់ត្រា ។ អានឲ្យស្តាប់ហើយ ជនត្រូវចោទសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមិនមានជំទាស់អ្វីទេ ហើយសុខចិត្តចុះហត្ថលេខា ។ សាក្សី, គង់ ផៃ"

[០៩:00:00]

"ការិយាល័យសហចៅក្រមស៊ើបអង្កេត ។ សំណុំរឿងព្រហ្មទណ្ឌលេខ០០២ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦ ។ លេខស៊ើបសួរ លេខ ០០១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ។

កំណត់ហេតុនៃការតទល់មុខគ្នា ។

ឆ្នាំពីរពាន់ប្រាំបី ខែកុម្ភៈ ថ្ងៃទីម្ភៃប្រាំបួន នៅវេលាម៉ោងប្រាំបួននិងម្ភៃនាទី ។

យើង យូ ប៊ុនឡេង និង ម៉ាសែល ឡឺម៉ុងដ៍ ជាសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ ដោយមានលោក ហម ហ៊ែល និង លោក លី ច័ន្ទតុលា ជាក្រឡាបញ្ជីអមផង ។

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញចុះ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ។

បានឃើញវិធាន៥៨ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ដោយមានវត្តមានរបស់ អ៊ូច ចាន់ណូរ៉ា និង តាន់ ប៊ិាងដាវណ្ណ ជាអ្នកបកប្រែនៃអង្គជំនុំជម្រះវិសាមញ្ញដែលបានស្បថរួចហើយ ។

ជនត្រូវចោទដែលមានអត្តសញ្ញាណដូចខាងក្រោមបានចូលខ្លួននៅចំពោះមុខយើង ។

ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ភេទប្រុស កើតថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ ត្រូវដាក់ឲ្យស្ថិត

នៅក្រោមការពិនិត្យពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ។

បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា ៥ មាត្រា៦ មាត្រា ២៩ថ្មី និងមាត្រា៣៩ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញចុះថ្ងៃទី២៧ ខែ តុលា ឆ្នាំ២០០៤ ។

សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញលោក រ៉ូបឺត ពេទីត និងអ្នកស្រី ជា លាង ដែលត្រូវបានជូនដំណឹងត្រឹមត្រូវរួចហើយអំពីការសួរចម្លើយនេះនៅក្នុងលិខិតជូនដំណឹងចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ២០០៨ ។

អ្នកស្រី ជា លាង មានវត្តមាន ។

លោក រ៉ូបឺត ពេទីត ត្រូវបានតំណាងដោយលោក អាឡិច ប៉េត ជំនួយការជាន់ខ្ពស់សហព្រះរាជអាជ្ញា ។

លោកមេធាវី ការ សាវុត្ថ និង ហ្វ្រង់ស្វ័រ រូ សហមេធាវីរបស់ជនត្រូវចោទ ត្រូវបានកោះអញ្ជើញនៅក្នុងដីកាកោះអញ្ជើញចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨ និងមានលទ្ធភាពបានពិនិត្យសំណុំរឿងតាំងពីពេលនោះមក មានវត្តមានទាំងពីរនាក់ ។

សាក្សីលោក ហ៊ឹម ហ៊ុយ, លោក ប្រាក់ ខន, លោក សួស ធី, លោក គង់ ផៃ, លោក ម៉ម ណៃ, លោក វ៉ាន់ ណាត, លោក ម៉ក់ ស៊ីធីម និងលោក សោម ម៉េត ដែលបានស្បថរួចហើយ ស្របតាមវិធាន ២៤ នៃវិធានផ្ទៃក្នុង នៃអង្គជំនុំជម្រះវិសាមញ្ញមានវត្តមាន ។

[១៥:៥០:៥៥]

ដើមបណ្តឹងរដ្ឋប្បវេណី លោក ជុំ ម៉ី និងមេធាវីរបស់លោកគាត់ លោកមេធាវី ហុង គីមសួន ត្រូវបានកោះអញ្ជើញនៅក្នុងដីកាកោះអញ្ជើញចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨ នឹងមានលទ្ធភាពបានពិនិត្យសំណុំរឿងតាំងពីពេលនោះមក មានវត្តមាន ។

ដើមបណ្តឹងរដ្ឋប្បវេណី លោក ប៊ូ ម៉េង និងមេធាវីរបស់គាត់ លោកមេធាវី យ៉ុង ផានិត ត្រូវបានកោះអញ្ជើញនៅក្នុងដីកាកោះអញ្ជើញចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨ នឹងមានលទ្ធភាពបានពិនិត្យសំណុំរឿងតាំងពីពេលនោះមក មានវត្តមាន ។

ច្បាប់ដើមនៃកំណត់ហេតុត្រូវបានសរសេរជាភាសាខ្មែរ ។

ការតទល់មុខគ្នា ។

សំណួររបស់លោកសហចៅក្រមស៊ើបអង្កេត ម៉ាសែល ឡឺម៉ុងដ៏៖ សាក្សីទាំងអស់ តើលោកមានដែលបានឃើញការសម្លាប់ជាឈុតនៅខែមករា ឆ្នាំ១៩៧៩ ដែរឬទេ?

សាក្សី គង់ ផៃ៖ ខ្ញុំទទួលស្គាល់អ្វីដែលខ្ញុំបាននិយាយនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ។ ខ្ញុំពិតជាបានឃើញការសម្លាប់នោះ ប្រហែលជាពីរ ឬបីថ្ងៃមុនថ្ងៃរំដោះ ៧ មករា ១៩៧៩ ។ ប៉ុន្តែ ខ្ញុំមិនបានចូលរួមក្នុងការសម្លាប់នោះទេ ។

សំណួររបស់លោកសហចៅក្រមស៊ើបអង្កេត ម៉ាសែល ឡឺម៉ុងដ៏៖ លោក គង់ ផៃ តើលោកបញ្ជាក់អះអាងអំពីអ្វីដែលលោកបានប្រកាសនៅចំពោះសហព្រះរាជអាជ្ញា កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៩ និងចំពោះមុខអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតនៅថ្ងៃ២៧ ខែធ្នូ ឆ្នាំ២០០៧ បានដែរឬទេ?

សាក្សី គង់ ផៃ៖ បាទ, ខ្ញុំសូមទទួលស្គាល់អ្វី ដែលខ្ញុំបាននិយាយ ។ ខ្ញុំនិយាយតែការពិតទេ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំបានឃើញ ឌុច សួរចម្លើយអ្នកទោស ប៉ុន្តែ ខ្ញុំមិនបានឃើញ ឌុច ធ្វើទារុណកម្មអ្នកទោសនោះទេ ។

សំណួររបស់លោកសហចៅក្រមស៊ើបអង្កេត ម៉ាសែល ឡឺម៉ុងដ៏៖ លោក គង់ ផៃ កាលពីពេលនៃការរៀបចំពិនិត្យឡើងវិញនៅទួលស្លែង លោកបានចង្អុលប្រាប់យើងថា លោកពិតជាបានឃើញថាមាន និងមានការប្រើប្រាស់អាងជ្រមុជទឹកដែលបានតាំងនៅសារមន្ទីរទួលស្លែងនោះ និងដែលត្រូវបានគូរដោយលោក វ៉ាន់ ណាត តើលោកនៅតែអះអាងថា លោកបានឃើញអាងនេះនៅខាងក្រៅបរិវេណទួលស្លែងដដែលឬ?

[១៥:៥៤:១៥]

សាក្សី គង់ ផៃ៖ បាទ ខ្ញុំបានឃើញអាងជ្រមុជទឹកនោះមែន នៅក្នុងគុកពិសេសដែលស្ថិតនៅខាងក្រៅបរិវេណទួលស្លែង ។

សំណួររបស់លោកសហចៅក្រមស៊ើបអង្កេត ម៉ាសែល ឡឺម៉ុងដ៏៖ នៅពេលរៀបចំពិនិត្យឡើងវិញនៅទួលស្លែង លោកបានប្រកាសថា លោកស្គាល់ក្តារខៀន ដែលមានសរសេរវិន័យសន្តិបាលទាំង ១០ ដែលមានតាំងជារូបថតនៅសារមន្ទីរនោះ ។ ចូរលោកពន្យល់ថា តើក្នុងលក្ខខណ្ឌដូចម្តេចដែលលោកបានឃើញក្តារខៀននោះ?

សាក្សី គង់ ផៃ៖ ក្តារខៀននោះ ត្រូវបានដាក់នៅជាន់ផ្ទាល់ដីនៃគុកពិសេសនៅជិតផ្លូវដើរ ដើម្បី

ឲ្យគ្រប់គ្នាគោរពតាម ។

ឯកសារច្បាប់ដើមនៃការថតរូបភាពនិងសំឡេងត្រូវបានស្លាកបោះត្រា នៅចំពោះមុខជនត្រូវចោទនេះ និងមេធាវីរបស់ជននេះ នឹងត្រូវបានចុះហត្ថលេខាដោយយើងក្រឡាបញ្ជីសហព្រះរាជអាជ្ញា ជនត្រូវចោទ និងមេធាវីរបស់ជននេះ ។

ឯកសារច្បាប់ដើមមួយច្បាប់នៃការថតរូបភាព និងសំឡេង ត្រូវបានប្រគល់ឲ្យជនត្រូវចោទនេះ ។ ដោយសារមូលហេតុបច្ចេកទេស យើងមិនអាចប្រគល់នូវឯកសារច្បាប់ដើមមួយច្បាប់នៃការថតរូបភាព និងសំឡេងទៅឲ្យសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីនាពេលនេះ ។ ប៉ុន្តែ យើងប្រគល់ឲ្យពួកគេនូវច្បាប់ថតចម្លងមួយច្បាប់នៃកំណត់ហេតុនេះ ។

នៅវេលាម៉ោងដប់ប្រាំពីរ និងម្ភៃប្រាំនាទីល្ងាច ។ យើងបានឲ្យក្រឡាបញ្ជីអានខ្លាំងៗនូវកំណត់ហេតុនៃការតទល់មុខគ្នាទៅតាមអ្វីដែលបានកត់ត្រា។

អានឲ្យស្តាប់ហើយ ជនត្រូវចោទ, សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមិនមានជំទាស់អ្វីទេ ហើយសុខចិត្តចុះហត្ថលេខា ។ សាក្សី, គង់ ផៃ"

[១៥:៥៦:៥៦]

"ការិយាល័យសហចៅក្រមស៊ើបអង្កេត សំណុំរឿងព្រហ្មទណ្ឌលេខ០០២ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦ ។ លេខស៊ើបសួរ លេខ០០១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ។

កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ ។

ឆ្នាំពីរពាន់ប្រាំបី ខែកុម្ភៈ ថ្ងៃទីម្ភៃប្រាំពីរ នៅវេលាម៉ោងប្រាំបីគត់ ។

បានឃើញការបើកការស៊ើបសួរ លើ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើសន្ធិសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ។

បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា៥ មាត្រា៦ មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ។

បានឃើញវិធាន៥៥.៨ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ។ បានឃើញដីកាចុះដល់ទីកន្លែង ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៨ ។

យើង យូ ប៊ុនឡេង និង ម៉ាសែល ឡឺម៉ុងដ៏ សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ

ក្នុងតុលាការកម្ពុជា ។

ដោយមានវត្តមានលោក ហាម ហែល និង លោក លី ចាន់តុលា ជាក្រឡាបញ្ជី និងលោក តាន់ ប៉ាងដាវណ្ណ និងលោក អ៊ូច ចាន់ណូរ៉ា និងលោក ជីន សាំរិបុល អ្នកបកប្រែនៃអង្គជំនុំជម្រះវិសាមញ្ញ ដែលបានស្បថរួចហើយ ។

យើងធ្វើដំណើរមកដល់បរិវេណនៃសារមន្ទីរទួលស្លែង រាជធានីភ្នំពេញ នៅទីនោះយើងឃើញមាន៖

លោកស្រី ជា លាង និងលោក រ៉ូប៊ីត ពើទីត សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះនៃវិសាមញ្ញ ។

កាំង ហ្គេកអ៊ាង ហៅ ឌុច និងមេធាវីរបស់ខ្លួន លោក ការ សាវុត្ថ និងលោក ហ្វ្រង់ស្វ័រ រូ ។

ជុំ ម៉ី ដើមរដ្ឋប្បវេណី និងមេធាវីរបស់ខ្លួនលោក ហុង គឹមសួន ។

ប៊ូ ម៉េង ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីរបស់ខ្លួនលោក យ៉ុង ផានិត ។

សាក្សី វ៉ាន់ ណាត, ម៉ម ណៃ, សួស ធី, ហ៊ីម ហ៊ុយ, សោម ម៉េត, ប្រាក់ ខន, គង់ ផៃ ។

អ្នកជំនាញ ហ្សូរ៉ង់ ឡឺស៊ិក ដែលត្រូវបានចាត់តាំងដោយដីកាចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៨ ក៏មានវត្តមាននៅទីនោះផងដែរ ។

ដើម្បីរៀបចំរបាយការណ៍របស់ខ្លួន ហើយបានថតរូបដែលមានជាប់នៅក្នុងឧបសម្ព័ន្ធនៃកំណត់ហេតុនេះ៖

១) ការហៅឈ្មោះអ្នកដែលមានវត្តមាន

ជនត្រូវចោទប្រកាសថា ស្គាល់ វ៉ាន់ ណាត, ប៊ូ ម៉េង, ជុំ ម៉ី, ម៉ម ណៃ, សួស ធី និង ហ៊ីម ហ៊ុយ ។

សាក្សី គង់ ផៃ ប្រកាសថា ស្គាល់ ឌុច, ម៉ម ណៃ និង ហ៊ីម ហ៊ុយ ។

[១៦:០១:១០]

សាក្សី គង់ ផៃ ពន្យល់ថា៖ បន្ទាប់ពីគាត់ឈប់ទទួលបន្ទុកយាមនៅខាងក្រោមក គាត់ត្រូវបានគេចាត់បញ្ជូនឱ្យទៅយាមនៅគុកពិសេសដែលស្ថិតនៅពីក្រោយអគារ “A” ។ គាត់និយាយថា គាត់បានឃើញ ឌុច មក និងសួរចម្លើយអ្នកទោសនៅគុកពិសេស ។ អ្នកយាមនៅទីនេះមិនអាចចូលទៅគុកពិសេសទេ ប៉ុន្តែ អ្នកយាមគុកពិសេសអាចចូលមកទីនេះបាន ។ គាត់មកយាមនៅអគារនេះជិតពេលវៀតណាមចូលមកដល់ ។ គាត់ថា មិនស្គាល់ឈ្មោះអ្នកសួរ

ចម្លើយទាំងអស់ទេ ។ គាត់ពិពណ៌នាអំពីរបៀបនៃការធ្វើទារុណកម្ម យកម្ពុលចាក់ក្រចកជើងអ្នកទោស ជ្រមុជអ្នកទោសក្នុងទឹកកក ។ បន្ទាប់ពីការសួរចម្លើយអ្នកទោសត្រូវបានបញ្ជូនចេញតែមិនដឹងទៅទីណាទេ ។

ទាក់ទិននឹងផ្ទាំងគំនូរដែលបង្ហាញពីអ្នកទោសដេកតម្រៀបជាជួរ វ៉ាន់ ណាត ពន្យល់ថា៖ គាត់ត្រូវបានគេឃុំនៅជាន់លើនៃអគារក្នុងបន្ទប់មួយដែលមានសភាពបែបនេះ ។ យោងទៅកថាខណ្ឌ៩.១ ខាងក្រោម៖

សាក្សី ប្រាក់ ខន និង គង់ ផៃ ទទួលស្គាល់ថា ពិតជាមានបន្ទប់របៀបនេះប្រាកដមែន ។

នៅចំពោះមុខអាងត្រាំទឹក សាក្សី ម៉ម ណៃ, សាក្សី ប្រាក់ ខន និងសាក្សី សួស ធីប្រកាសថា ពួកគេមិនដឹងថា មានអាងត្រាំទឹកនេះទេ ។

ផ្ទុយទៅវិញ សាក្សី គង់ ផៃ ពន្យល់ថា៖ គាត់បានឃើញអាងត្រាំទឹកបែបនេះ នៅខាងក្រៅបរិវេណគុក និងនៅក្នុងគុកពិសេស ។ គាត់បន្ថែមថា ធុងឈើដែលដាក់តាំងនៅជិតអាងត្រាំទឹកត្រូវបានបំពេញដោយទឹកកកត្រជាក់ ។

សាក្សីនានា ផ្តល់ជូននូវការបញ្ជាក់មួយចំនួនទាក់ទិននឹងការសម្លាប់ ។ គង់ ផៃ នៅតែអះអាងអំពីសេចក្តីប្រកាសរបស់ខ្លួនកន្លងមកដែលថា គាត់បានមានវត្តមាននៅក្នុងការសម្លាប់មួយនៅពេលយប់។ គាត់គូសបញ្ជាក់ថា អ្នកទោសដែលគេសម្លាប់ត្រូវបានកប់នៅជិតគុកពិសេសនៅក្នុងបរិវេណស-២១ នាសម័យកាលដែលកើតហេតុនោះ ។ ប៉ុន្តែនៅខាងក្រៅរបងនៃបរិវេណសព្វថ្ងៃនេះ ។

អ្នកចូលរួមទាំងអស់ចាកចេញពីទីកន្លែងរៀបចំនៅម៉ោងដប់ប្រាំពីរ និងដប់ប្រាំនាទីដោយមិនមានឧប្បត្តិហេតុណាមួយឡើយ ។

ការសម្តែងឡើងវិញនេះ ត្រូវបានថតជារូបភាព និងសំឡេង ហើយច្បាប់ថតចម្លងមួយច្បាប់នៃការថតរូបភាព និងសំឡេងត្រូវបានប្រគល់ឲ្យជនត្រូវចោទ ។

ច្បាប់ដើមនៃកំណត់ហេតុនេះ ត្រូវបានសរសេរជាភាសាខ្មែរ និងបារាំង និងបន្ទាប់មកបកប្រែជាភាសាអង់គ្លេស ។ ក្រឡាបញ្ជី លី ច័ន្ទតុលា, ហ៊ម ហែល ។”

**ប្រធានអង្គជំនុំ៖**

ក្រោយពីបានស្តាប់នូវការអានចម្លើយកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ។ កំណត់ហេតុនៃការសួរតទល់ ហើយនិងកំណត់ហេតុនៃការចុះពិនិត្យដល់កន្លែងកើតហេតុ ។

តើចំពោះសាក្សី គង់ ផៃ តើតំណាងសហព្រះរាជអាជ្ញា មានអ្វីចង់កត់សម្គាល់ដែរឬទេ?

សូមអញ្ជើញ ។

**លោក យ៉េត ចរិយា៖**

លោកប្រធាន ចំពោះសក្ខីកម្មរបស់សាក្សីឈ្មោះ គង់ ផៃ ដែលលោកស្រីក្រឡាបញ្ជីអានអម្បាញ់មិញនេះ ។ តំណាងអយ្យការ ពុំមានធ្វើអ្វីកំណត់សម្គាល់ ឬតវ៉ាឡើយ ។

**ប្រធានអង្គជំនុំ៖**

ចុះខាងក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី តើមានអ្វីធ្វើការកត់សម្គាល់ទេ នូវកំណត់ហេតុដែលបានអានដោយក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ?

[១៦:០៦:៤៦]

**លោក អាឡាំង វែនណឺ៖**

យើងខ្ញុំក៏អត់មានការជំទាស់ ឬក៏តវ៉ាដែរ ។

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្តី តើមានអ្វីចង់ធ្វើការកត់សម្គាល់ ឬក៏តវ៉ាទៅនឹងកំណត់ហេតុ ដែលបានអានដោយក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះទេ ចំពោះសាក្សីឈ្មោះ គង់ ផៃ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន មេធាវីការពារមានបញ្ហាត្រូវលើក ។ តើការិយាល័យសហព្រះរាជអាជ្ញាអាចជម្រាបតុលាការបានទេ ថាតើសាក្សីណាមួយ ឬក៏ចំណុចណាមួយដែលប្រាប់ការពិត?

សាក្សីនេះឆ្លើយផ្ទុយគ្នាទៅនឹងកំណត់ហេតុសក្ខីកម្មជាច្រើន ដែលជាសាក្សីរបស់អង្គជំនុំជម្រះដែលស្នើឡើងដោយសហព្រះរាជអាជ្ញា ។ ដូច្នេះ ខ្ញុំយោងទៅរកចំណុចមួយដែលសាក្សីនេះនិយាយថា ឌុច បានសួរចម្លើយអ្នកទោសដោយខ្លួនឯង ។ ប៉ុន្តែ សាក្សីរបស់សហព្រះរាជអាជ្ញានោះ គឺឆ្លើយខុសពីហ្នឹង ។ សាក្សីនេះនិយាយថា ហើយនិយាយផ្ទុយពីអ្វីៗដែលសាក្សីមុននោះបញ្ជាក់ ប៉ុន្តែអំពីវិធានសរសេរលើក្តារខៀននោះ គឺសាក្សីព្រឹកមិញនេះ គាត់ឆ្លើយផ្ទុយពីកំណត់ហេតុនេះ ។

នេះជាសំណួររបស់ខ្ញុំទៅការិយាល័យសហព្រះរាជអាជ្ញា ដើម្បីឲ្យមានតម្លាភាពក្នុងនីតិវិធី សូមលោកមេត្តាបញ្ជាក់ជូនអង្គជំនុំជម្រះ ថាតើសាក្សីមួយណារបស់លោកដែលប្រាប់ការពិតដើម្បីគាំទ្រការងាររបស់មេធាវីការពារ និងបញ្ជាក់ស្វែងរកនូវការពិតនៅក្នុងតុលាការ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក អានីស អះមេដ៖**

សូមគោរពលោក លោកស្រីចៅក្រម! យើបានឮអ្វីៗ ដែលជាមតិរបស់មេធាវីការពារដែលគាត់ជំទាស់ទៅនឹងសក្ខីភាពរបស់សាក្សីនេះ ដោយមិនចាំបាច់កោះមកតុលាការ ហើយលោកមេធាវីការពារមិនបានឆ្លើយតបទៅនឹងសំណើរបស់លោកប្រធានចៅក្រមទេ ។ ហើយព្រឹកមិញនេះ លោកមេធាវីបានលើកឡើងថា លោកចៅក្រម លោកស្រីចៅក្រម ជាចៅក្រមមានជំនាញ គឺថាមានជំនាញមានច្បាស់គឺការជំនុំជម្រះក្នុងកម្រិតនេះ មិនចាំបាច់កោះហៅសាក្សីគ្រប់ទាំងអស់មកផ្តល់សក្ខីកម្ម ដើម្បីមកអញ្ជើញមកផ្តល់សក្ខីកម្មឲ្យស៊ីសង្វាក់គ្នាទេ ដោយថាៗ លក្ខណៈជាមនុស្ស គឺត្រូវថាអាចហ្នឹងឆ្លើយ និងបញ្ជាក់ពីហេតុការណ៍អង្គហេតុតាមរបៀបខុសគ្នាៗ ។ អ៊ីចឹងហើយ គឺនៅក្នុងដំណាក់កាលនេះ នេះហើយជាចំណុចដែលលោក លោកស្រីចៅក្រម ត្រូវពិចារណា ហើយចំណុចនេះ រក្សាទុកនឹងផ្តល់លើកទឡ្ហីកម្មចុងក្រោយនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់របស់ភាគី ។

[១៦:១០:១៦]

អ៊ីចឹងហើយខ្ញុំសូមស្នើដោយគោរពថា គឺថានៅពេលនេះ ហាក់ដូចជាឆាប់ពេកដើម្បីបញ្ជាក់ថាតើសម្តីរបស់អ្នកណាខុស? អ្នកណាត្រូវ? ពិត ឬមិនពិតហ្នឹង? ហើយការងាររបស់លោក លោកស្រីដើម្បីថ្លឹងថ្លែងពីការពិតនៅលើរឿងនោះ ។ ហើយខ្ញុំក៏សូមស្នើទៅឲ្យខាងមេធាវីការពារឆ្លើយទៅលោកលោកស្រីចៅក្រម ថាតើលោកមានការជំទាស់ ឬក៏មិនជំទាស់ទៅលើសក្ខីកម្មរបស់សាក្សី ដែលទើបតែបានអានអម្បាញ់មិញនេះ? សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

មានអ្វីទេ លោក ហ្វ្រង់ស្វ័រ រូ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណ លោកប្រធាន ។

ជាក់ស្ដែងមេធាវីការពារមិនៗជំទាស់ មិនប្រកែក និងការដាក់សក្ខីភាពនេះ ដេញដោលនៅចំពោះតុលាការទេ ។ ប៉ុន្តែ អ្វីដែលយើងជំទាស់នោះ គឺថាសុំឱ្យសហព្រះរាជអាជ្ញាឆ្លើយទៅនឹងសំណួរដូចខ្ញុំលើកឡើងនោះ ។ ថាតើសាក្សីមួយណាដែលប្រាប់ការពិតដែលបញ្ជាក់ថា វាមានកំណត់ហេតុពីរដែលផ្ទុយគ្នាហ្នឹង?

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត គឺប្រគល់ឱកាសដល់ជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់ចំពោះកំណត់ហេតុការស្ដាប់ចម្លើយសក្ខីកម្មរបស់សាក្សី ដែលបានអានដោយក្រឡាបញ្ជី លោកស្រី សែ កុលវុឌ្ឍី អម្បាញ់មិញនេះ ប្រសិនបើលោកមានបំណង ។

[១៦:១២:២២]

**ជនជាប់ចោទ៖**

លោកប្រធាន ជាទីគោរព! សភាពការណ៍រួម ដែលនិយាយអំពីឧក្រិដ្ឋកម្មនៅស-២១ សក្ខីកម្មរបស់ គង់ ផៃ តិចតួចណាស់វាគ្រាន់តែជាផ្នែកមួយសម្រាប់ជូនអង្គសវនាការ ជូនជាតិប្រជាជនកម្ពុជាឱ្យយល់ប៉ុណ្ណឹង ។ ដោយឡែកបញ្ហាខ្លះ ដែលសាក្សី គង់ ផៃ លើកឡើង ដូចជានិយាយពីរឿងខ្ញុំបាទផ្ទាល់ទៅសួរចម្លើយអ្នកទោសមានអាងជ្រមុជទឹក ។ សក្ខីកម្មប្រភេទនេះ ហើយនិងមានអាគ្គារខៀនសរសេរវិន័យសន្តិបាលទាំងដប់ (ខ) នោះ ។ បញ្ហានេះអស់ក៏បានជជែកវែកនៅនឹងមុខអង្គសវនាការនេះយូរដែរហើយ ។ ហេតុផលទាំងសងខាងសុទ្ធតែបានលើកជូនអង្គជំនុំជម្រះរួចហើយ ។ ដូច្នេះ ខ្ញុំគិតថាសក្ខីកម្មរបស់សាក្សី គង់ ផៃ វាជាបញ្ហាមួយ បើសុភាសិតអង់គ្លេស គេនិយាយថា "ត្រចៀកកាំមួយមិនអាចធ្វើ ស្ពានិទាឃរដូវបានទេ" ។ ដូច្នេះ ខ្ញុំទុកបញ្ហានេះ ជូនអង្គជំនុំជម្រះលោកមេត្តាពិចារណាចុះខ្ញុំអត់មាននេះទេ គឺសូមជូនបញ្ហានេះ ព្រោះវាបានឆ្លងកាត់ការជជែកតវ៉ាជាមួយគ្នារួចហើយអស់ ។

ដោយឡែកតែពួកយុវជន និងក្មេងជំទង់ ដែលខ្ញុំទៅសុំមកពីខាងកំពង់ឆ្នាំង ខ្ញុំនិងសរុបជូនអង្គសវនាការនៅពេលណាដែលចប់ ក្រុមពួកក្មេងជំទង់ ដែលមកពីកំពង់ឆ្នាំងទាំងប៉ុន្មាន នៅស-២១ នៅក្នុងពេលនោះ ។ ខ្ញុំសូមគោរព រាយការណ៍ជូនប៉ុណ្ណេះ ដោយគោរព ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ពេលវេលារសៀលត្រូវផ្អាកសវនាការហើយ អ៊ីចឹងអង្គជំនុំជម្រះសាលាដំបូងប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការនឹងលើកទៅបន្តនៅថ្ងៃស្អែកចាប់ពីវេលា

ម៉ោងប្រាំបួនព្រឹក ។ ហើយនៅថ្ងៃស្អែកនេះ ខ្ញុំសូមជម្រាបជូនដល់ភាគី និងសាធារណជនឲ្យបានជ្រាបផងដែរ ថ្ងៃស្អែកនេះ គឺដល់ពេលសក្ខីកម្មចំពោះអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ ។ អ៊ីចឹងសូមភាគីទាំងអស់ជ្រាប ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំជនជាប់ចោទកាន់សាលសវនាការ នៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក ៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការផ្អាកនៅម៉ោង១៦:១៦ នាទី]*